**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ស្រាវជ្រាវចាប់ពីថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **តាំង ខ្មៃអៀង**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ**នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ តាំង ឡៃអៀង ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២២ មហាវិទ្យាល័យនីតិសាស្ត្រ នៃ សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវសេចក្តីកតញ្ញូចំពោះគុណបំបាច់ដ៏ធំធេងរបស់លោកឪពុក ចេង ទ្រី និង អ្នកម្តាយ សៅ ចន្ថា ដែលបានផ្តល់កំណើតដល់រូបខ្ញុំបាទ បានចិញ្ចឹមបីបាច់ថែរក្សាខ្លួនខ្ញុំ ប្រកបដោយព្រហ្មវិហារធម៌ជារៀងរហូតមក ។ ទន្ទឹមនឹងនេះ លោកទាំងទ្វេហាបានផ្តល់នូវការសិក្សារៀនសូត្រដល់រូបខ្ញុំ ចាប់តាំងតែពីថ្នាក់មត្តេយ្យសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រ ។ គុណបំបាច់ដ៏គាប់ប្រសើររបស់លោកទាំងពីរ ពុំមានអ្វីនឹងអាចយកថ្លាថ្លែងសម្តែងពាក្យសម្តីតាមរយៈសេចក្តីថ្លែងអំណរគុណនេះអស់នោះឡើយ ។

ខ្ញុំបាទសូមថ្លែងអំណរអរគុណជូនចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធិបុរស ព្រឹទ្ធិបុរសរង និង សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានគ្រប់គ្រងថែរក្សា និង បង្ហាត់បង្ហាញផ្ទេរនូវចំណេះដឹងដល់រូបខ្ញុំបាទ ក៏ដូចជានិស្សិតទាំងអស់នៃសាកលវិទ្យាល័យយើង ក្រៅតែអំពីការអប់រំចំណេះដឹងផ្នែកនីតិវិទ្យាដល់ពួកយើងជានិស្សិត លោកតែងតែអប់រំតម្រង់ទិសដៅនិស្សិតគ្រប់ឱ្យក្លាយជាកោសិកាដ៏មានតម្លៃរបស់សង្គមជាតិ ។

ជាពិសេសខ្ញុំបាទ សូមថ្លែងអំណរអរគុណ លោកបណ្ឌិត ព្រុំ រិទ្ធី ដែលជាសាស្ត្រាចារ្យដឹកនាំ និង ណែនាំកិច្ចការសារណាដល់រូបខ្ញុំបាទយ៉ាងខ្មីឃ្មាតជាទីបំផុត លោកតែងតែចំណាយពេលវេលាដ៏មានតម្លៃរបស់លោកផ្តល់ការណែនាំជាយោបល់ ជាកម្លាំងចិត្ត ជាគំនិត ដល់ខ្ញុំបាទគ្រប់ពេលវេលា ។ លោកបាន ជំរុញ និង លើកទឹកចិត្ត កែលម្អនូវចំណុចខ្វះខាត ព្រមការលះបង់នូវកម្លាំងកាយចិត្ត ដើម្បីជួយដល់រូបខ្ញុំបាទជាពន់ពេក ព្រមទាំងតម្រាយតម្រង់ផ្លូវដល់ខ្ញុំបាទជានិច្ចកាល រហូតដល់ការឈានចូលមកនៃការសម្រេច ក្នុងការតាក់តែងកិច្ចការសារណាស្តីអំពី "កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" នេះឡើង ។

ជាចុងបញ្ចប់ខ្ញុំបាទលើកហត្ថប្រណម្យបួងសួង សូមជូនពរដល់អស់លោកជាសាស្ត្រាចារ្យ និង គណៈគ្រប់គ្រប់សាលាគ្រប់ជាន់ថ្នាក់ ជាពិសេសលោកបណ្ឌិត ព្រុំ រិទ្ធី សូមបានជួបប្រទះទៅនឹងសេចក្តីសុខ សេចក្តីចម្រើន សុខសុភមង្គល សុខភាពមាំមួនល្អបរិបូរណ៍គ្រប់ទិនទិវាកាល និង បានជួបនូវចតុពុទ្ធិពរគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ ព្រមបដិភាណ កុំបីមានឃ្លាងឃ្លាតឡើយ ។

# អារម្ភកថា

ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធតាមរយៈកិច្ចសន្យា អាចថាជាប្រព័ន្ធគ្រប់គ្រងបេតិកភណ្ឌគ្រួសារមួយថ្មីរបស់ព្រះរាជាណាចក្រកម្ពុជា ដែលអាចសង្កេតឃើញមានក្នុងក្រម រដ្ឋប្បវេណីឆ្នាំ ២០០៧ ហើយត្រូវប្រកាសឱ្យប្រើនាឆ្នាំ ២០១១ ក្រោយពីការចូលជាធរមាននៃច្បាប់ស្តីពី "ការអនុវត្តក្រមរដ្ឋប្បវេណី" ។

ការគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធតាមរយៈកិច្ចសន្យា មានសារសំខាន់ និង សារប្រយោជន៍ខ្លាំងណាស់សម្រាប់ប្ដីប្រពន្ធ អាចកំណត់អំពីសិទ្ធិ និង ករណីយកិច្ចក្នុងកាតព្វកិច្ចបំណុលគ្រួសារបានថា សហព័ទ្ធម្ខាងណាមានសិទ្ធិអ្វី ឬ ករណីយកិច្ចគ្រួសារ ហើយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធមានគុណសម្បត្តិសម្រាប់ប្ដីប្រពន្ធដែលមានបំណង ចង់ធ្វើឯកជនភាពលើទ្រព្យសម្បត្តិរបស់ខ្លួន ។ បន្ទាប់ពីនេះបើភាគីនៃកិច្ចសន្យាមានសហព័ទ្ធម្ខាងជាពាណិជ្ជករ ដើម្បីអាចការពារអាចការពារទ្រព្យសម្បត្តិរបស់ខ្លួនពីហានិភ័យពាណិជ្ជកម្ម ហើយធ្វើឱ្យប៉ះពាល់ទ្រព្យសម្បត្តិរួម ។ បានធ្វើឱ្យទ្រព្យសម្បត្តិប្ដីប្រពន្ធ មានភាពជាក់លាក់ និង ច្បាស់លាស់ ហេតុនេះទំនាក់ទំនងទ្រព្យសម្បត្តិប្ដីប្រពន្ធ ក៏មានភាពច្បាស់លាស់ និង ជាក់លាក់ទៅតាមការព្រមព្រៀងរបស់សហព័ទ្ធផងដែរ ។

ដោយសង្កេតឃើញអំពីផលប្រយោជន៍ និង សារសំខាន់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចំពោះសហព័ទ្ធ ទើបខ្ញុំបាទ សម្រេចិត្តជ្រើសរើសយកប្រធានបទនេះ មកធ្វើការសិក្សាទៅលើលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា អានុភាពនៃកិច្ចសន្យា ព្រមទាំងការបញ្ចប់អានុភាពនៃកិច្ចសន្យានោះត្រលប់ទៅវិញ ។

កិច្ចការសារណា ដែលលោកអ្នក បានកំពុងកាន់ និង អាន នេះ គឺជាសមិទ្ធិផលនៃការសិក្សារយៈពេល ៤ ឆ្នាំ របស់ខ្ញុំបាទក្នុងនាមនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ។ ខ្ញុំបាទបានព្យាយាមសម្រិតសម្រាំងទៅលើកិច្ចការសារណានេះយ៉ាងយកចិត្តទុកដាក់បំផុត ខ្ញុំបាទនៅក៏តែជឿថាមិនអាចគេចផុតអំពីការកង្វះខាត និង មានកំហុសដែលមិនអាចជៀសវាងបាន ទៅលើអក្ខរាវិរុទ អត្ថន័យ ការប្រមូលពត៌មានបានគ្រប់ជ្រុងជ្រោយ ជាពិសេសទៅលើច្បាប់ ឬ បទដ្ឋានគតិយុត្តរបស់បរទេស ដែលត្រូវមកធ្វើជៀបបង្ហាញនៅក្នុងកិច្ចសារណាមួយនេះ ។ ខ្ញុំបាទមានតែលើហត្ថសំពះ សូមការខន្តីអភ័យទោសប្រសិនបើកិច្ចសារណាខ្ញុំបាទមិនមានលក្ខណៈគ្រប់គ្រាន់ ហេតុនេះខ្ញុំបាទសូមទទួលយកនូវការរិះគន់ទាំងប៉ុន្មាន ដែលអស់លោក - លោកស្រីធ្វើមូលវិចារណ៍មកកាន់ខ្ញុំបាទ ។

ខ្ញុំបាទសូមសង្ឃឹមថា កិច្ចសារណាមួយនេះ នឹងក្លាយទៅជាមិត្តជំនួយស្មារតីមិត្តអ្នកអានទាំងអស់ ជាពិសេស និស្សិតនីតិវិទ្យា ដែលធ្វើសិក្សាទៅលើប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធនៅក្នុងនីតិបេតិកភណ្ឌ និង គ្រួសារដែលជាផ្នែកមួយនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំបាទក៏សូមសង្ឃឹមថាកិច្ចសារណានេះ នឹងក្លាយជាជំនួយដ៏ល្អបំផុតសម្រាប់គូភាគី ក្នុងការស្វែងយល់អំពីការចរចាព្រមព្រៀងក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធឱ្យមានសុពលភាព ចាកជៀសពីវិវាទដែលកើតពីទំនាក់ទំនងទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

# មាតិកា

**ចំណងជើង** **លេខទំព័រ**

**សេចក្តីផ្តើម** ............................................ ១
**ជំពូកទី១ លក្ខខណ្ឌបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ............................................ ៤
ផ្នែកទី១ លក្ខខណ្ឌគ្រឹះក្នុងការបង្កើតកិច្ចសន្យា............................................ ៤
១.ការព្រមព្រៀងរបស់សហព័ទ្ធ............................................ ៤
២.សមត្ថភាពក្នុងបង្ហាញឆន្ទៈ............................................ ៦
២.១.ជនស្ថិតក្រោមហិតូបត្ថម្ភ ............................................ ៧
២.២.ជនស្ថិតក្រោមអាណាព្យាបាលទូទៅ ............................................ ៨
៣.កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ............................................ ៨
៣.១.កម្មវត្ថុនៃកិច្ចសន្យាដែលផ្ទុយនឹងបទប្បញ្ញាតិ ............................................ ៩
៣.១.១.ការមិនបំពានទៅលើសិទ្ធិលើភាគបម្រុង............................................ ៩
៣.១.២.ការមិនបំពានទៅលើសិទ្ធិទាមទារអាហារកាតព្វកិច្ច............................................ ១០
៣.១.៣.ការមិនបំពានទៅលើសណ្តាប់ធ្នាប់សាធារណៈ ............................................ ១២
៣.១.៤.មោឃភាពនៃកិច្ចសន្យា ............................................ ១២
៣.២.កម្មវត្ថុនៃកិច្ចសន្យាជាទ្រព្យសម្បត្តិ............................................ ១៣
៣.២.១.អចលវត្ថុ និង ចលវត្ថុ............................................ ១៣
៣.២.២.សិទ្ធិលើទ្រព្យសម្បត្តិមួយចំនួន ............................................ ១៣
៤.លក្ខខណ្ឌពិសេសនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............................................ ១៦
ផ្នែកទី២ លក្ខខណ្ឌទម្រង់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ............................................ ១៧
១.ភាពចាំបាច់នៃការសរសេរជាលាយល័ក្ខណ៍អក្សរ............................................ ១៧
២.ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............................................ ១៨
២.១.អំពីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............................................ ១៨
២.១.១.សញ្ញាណនៃការចុះបញ្ជី ............................................ ១៨
២.១.២.ស្ថាប័នចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............................................ ១៩
២.២.អំពីការកែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ............................................ ២០
២.៣.នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ............................................ ២១

២.៣.១.ទម្រង់នៃពាក្យសុំចុះបញ្ជី ........ ២១
២.៣.២.ប្រភេទនៃពាក្យសុំចុះបញ្ជី ........ ២២
២.៣.៣.ការចេញលិខិតបញ្ជាក់ ........ ២៦
**ជំពូកទី២ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ ២៨
ផ្នែកទី១ អានុភាពគតិយុត្តចំពោះភាគីជាប្តីប្រពន្ធ ........ ២៨
១.សិទ្ធិ និង ករណីយកិច្ចរបស់ភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ២៨
១.១.សិទ្ធិប្រើប្រាស់ និង អាស្រ័យនៅ ........ ២៨
១.២.សិទ្ធិចាត់ចែងទ្រព្យសម្បត្តិរួម ........ ២៩
១.៣.ការទទួលខុសត្រូវដោយសាមគ្គីភាព ........ ៣០
២.ការតតាំងទៅនឹងតតិយជនរបស់ភាគី ........ ៣០
ផ្នែកទី២ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិចំពោះតតិយជន ........ ៣១
**ជំពូកទី៣ ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ** ........ ៣២
ផ្នែកទី១ មូលហេតុដែលនាំឱ្យបញ្ចប់កិច្ចសន្យា ........ ៣២
១.ការរំលាយអាពាហ៍ពិពាហ៍ ........ ៣២
១.១.ការលែងលះ ........ ៣២
១.២.មរណៈភាព ឬ ការបាត់ខ្លួន ........ ៣៤
២.ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងករណីផ្សេងទៀត ........ ៣៥
២.១.មោឃភាព ឬ ការលុបចោលអាពាហ៍ពិពាហ៍ ........ ៣៥
២.២.ការបញ្ចប់កិច្ចសន្យាដោយឆន្ទៈភាគី ........ ៣៦
ផ្នែកទី២ អានុភាពនៃការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៣៧
១.អានុភាពបញ្ចប់កិច្ចសន្យាចំពោះគូភាគី ........ ៣៧
១.១.អានុភាពមិនប្រតិសកម្មនៃទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៣៧
១.២.ការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៣៨
២.អានុភាពនៃការបញ្ចប់ក្នុងករណីរំលាយកិច្ចសន្យាដោយឆន្ទៈភាគី ........ ៣៨
២.១.សហព័ទ្ធផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រង ........ ៣៨
២.២.ការបញ្ចប់កំជាប់ពាក្យ ........ ៣៩
៣.អានុភាពនៃការបញ្ចប់កិច្ចសន្យាចំពោះតតិយជន ........ ៣៩

៣.១.អានុភាពចំពោះម្ចាស់បំណុល ........................................................................ ៣៩
៣.២.អានុភាពចំពោះសន្តតិជន ........................................................................ ៣៩
**សេចក្តីសន្និដ្ឋាន និង អនុសាសន៍** ........................................................................ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

អាពាហ៍ពិពាហ៍ គឺជាការរួមរស់នៅជាមួយគ្នារវាង បុរសម្នាក់ និង នារីម្នាក់ ក្នុងនាមជាប្តីប្រពន្ធ ដែលត្រូវបានទទួលស្គាល់ដោយច្បាប់តាមរយៈការចុះសំបុត្រអាពាហ៍ពិពាហ៍ ។ អាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធ នឹងបង្កើតនូវសិទ្ធិ និង កាតព្វកិច្ចជាច្រើនរវាងគ្នា នឹង គ្នា ព្រមទាំងកូនផង ។ ហើយសិទ្ធិ និង កាតព្វកិច្ចដែលមាន គឺភាពសហការគ្នាក្នុងជីវភាពរស់នៅក្នុងនាមជាប្តីប្រពន្ធ រួមទាំងការថែរក្សា ស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក ព្រមទាំងត្រូវសង្គ្រោះគ្នាក្នុងករណីដែលសហព័ទ្ធជួបប្រទះនឹងការលំបាក ។ ក្រៅតែពីមនោសញ្ចេតនា និង ចំណងគតិយុត្ត នៃភាពជាប្តីប្រពន្ធរបស់សហព័ទ្ធហើយនោះ ចំណងមួយដ៏សំខាន់ដែលកើតឡើងចំពោះទំនាក់ទំនងប្តីប្រពន្ធ នោះគឺ ទំនាក់ទំនងទ្រព្យសម្បត្តិ ។ ក្នុងទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាទំនាក់ទំនងមួយដែលមានភាពស្មុគស្មាញជាងគេ ជាពិសេសនៅពេលសហព័ទ្ធ បានធ្វើការលែងលះគ្នា នោះនឹងមានវិវាទទ្រព្យសម្បត្តិកើតឡើងជាញឹកញយ ។ នៅពេលមានវិវាទទ្រព្យសម្បត្តិកើតឡើងសង្កេតឃើញថា សហព័ទ្ធទាំងសងម្ខាងតែងតែលើកឡើងអំពីទ្រព្យសម្បត្តិរបស់ខ្លួនដែលជាទ្រព្យសម្បត្តិរួម ហើយទាមទារចំណែកដែលច្រើនជាងគេ ។ ក្រៅពីនេះតាម រយៈទំនាក់ទំនងជីវភាពប្តីប្រពន្ធនេះ អាចឱ្យឃើញថា បើមានសហព័ទ្ធម្ខាងជា ពាណិជ្ជករ មានសហគ្រាសពាណិជ្ជកម្មនោះ ពាណិជ្ជកម្មអាចជួបប្រទះទៅនឹងហានិភ័យពាណិជ្ជកម្ម ។ តួយ៉ាងតាមរយៈទិដ្ឋភាពជាក់ស្តែងនៅប្រទេសកម្ពុជាយើង ក៏ដូចជាបណ្តាលប្រទេសដទៃទៀត នៅលើសកលលោក បានប្រទះនឹងហានិភ័យពាណិជ្ជកម្មនៅក្នុងអំឡុងពេលជំងឺរីករាលកូវីត១៩ បានធ្វើឱ្យសហគ្រាសពាណិជ្ជកម្មជាច្រើន ត្រូវប្រឈមមុខនឹងបំណុលដែលកើតពីការរក្សាលំនឹងពាណិជ្ជកិច្ចរបស់ខ្លួន ។[1] ទោះបីជាចាកចេញអំពីការជំងឺរីករាលដាលហើយក៏ដោយ ក៏សង្កេតឃើញព្យសនកម្មនៃបញ្ហានេះ បាននៅតែបន្តកើតឡើងជាពិសេសទៅសេដ្ឋកិច្ចរបស់ពលរដ្ឋតែម្តង ។ ហេតុនេះតម្រូវឱ្យសហព័ទ្ធ ត្រូវតែស្វែងរកដំណោះស្រាយអំពីការកើតឡើងនូវបញ្ហាលើទ្រព្យសម្បត្តិរបស់ខ្លួន ក៏ដូចជាការពារសិទ្ធិ និង ផលប្រយោជន៍របស់ខ្លួនឱ្យមានសុវត្ថិភាព ហើយធានាថានឹងមិនមានផលរំខានដល់ការប្រើប្រាស់ និង គ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ខ្លួនឡើយ ។

នៅបណ្តាលប្រទេសអឺរ៉ុប សង្កេតឃើញមានការប្រើប្រាស់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ តាមរយៈកិច្ចសន្យា ដើម្បីឱ្យសហព័ទ្ធមានលទ្ធភាពអាចកំណត់អំពីការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនទៅតាមការចង់បាន ។ ចំណែកឯច្បាប់ព្រះរាជាណាចក្រកម្ពុជា កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺទើបមានតែមានវត្តមាននៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ តែប៉ុណ្ណោះ ។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាកិច្ចសន្យាដែលមានទិសដៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ និងរបៀបរបបនៃការប្រើប្រាស់សម្បត្តិប្តីប្រពន្ធអាស្រ័យ

[1] សូមមើលតាមតំណភ្ជាប់ ៖ https://www.worldbank.org/km/country/cambodia/publication/main-findings-of-the-cambodia-country-economic-memorandum-cem , កាលបរិច្ឆេទចូលមើល ៖ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២២ ។

តាមការចង់បានរបស់គូភាគីជាសហព័ទ្ធ ។ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ មានអត្ថប្រយោជន៍ច្រើនណាស់សម្រាប់គូភាគីដែលមានសហព័ទ្ធជាពាណិជ្ជករ ក្នុងន័យមិនបានសេចក្ដីថា បើសហព័ទ្ធទាំងសងខាងមិនមែនជាពាណិជ្ជករ មិនអាចទទួលបានផលប្រយោជន៍ពីការតាក់តែងកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធបាននោះទេ ព្រោះកិច្ចសន្យាមួយនេះ មានអត្ថប្រយោជន៍សំដៅដល់ការជួយសម្រួលដល់ប្ដីប្រពន្ធ ក្នុងការប្រើប្រាស់សម្បត្តិរបស់សហព័ទ្ធទៅតាមការចង់បាន ការបង្ហាញច្បាស់លាស់អំពីទ្រព្យសម្បត្តិរួម និង ដោយឡែករបស់ប្ដីប្រពន្ធ ព្រមទាំងការតតាំងទៅនឹងតតិយជនជាដើម....។ នៅពេលដែលប្ដីប្រពន្ធបានកំណត់ច្បាស់ថា ទ្រព្យណាមួយជាទ្រព្យដោយឡែក ឬ ទ្រព្យរួម នោះទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធមានភាពច្បាស់លាស់ ពិសេសតម្លៃតបនៃទ្រព្យនោះ គឺមានការកំណត់បានយ៉ាងងាយស្រួល ម្យ៉ាងទៀតពេលមានតតិយជន អះអាងសិទ្ធិរបស់ខ្លួនលើទ្រព្យសម្បត្តិរួមនោះ សហព័ទ្ធមានអានុភាពក្នុងការតតាំងទៅនឹងតតិយជននោះប្រសិនបើបានចុះបញ្ជី ។

តើមានលក្ខខណ្ឌអ្វីខ្លះទើបអាចធ្វើការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបានដោយមានប្រសិទ្ធិភាព និងអានុភាពតតាំងទៅនឹងតតិយជន ? តើវត្ថុអ្វីខ្លះដែលអាចក្លាយជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ហើយនរណាខ្លះអាចជាភាគីនៃកិច្ចសន្យាប្រភេទនេះបាន ? ដើម្បីអាចចុះបញ្ជីទៅលើកិច្ចសន្យារបស់ខ្លួនបានត្រឹមត្រូវ តើភាគីត្រូវធ្វើអ្វីខ្លះ? តើការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ អាចធ្វើឡើងតាមវិធីណាខ្លះ ?

ការស្រាវជ្រាវទៅលើប្រធានបទនេះ គឺធ្វើឡើងក្នុងការសិក្សាឱ្យកាន់តែស៊ីជម្រៅអំពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និងការចុះបញ្ជីទៅលើកិច្ចសន្យាប្រភេទនេះ មាននីតិវិធីបែបណា ហើយភាគីនឹងត្រូវធ្វើដូចម្ដេចដើម្បីអាចចុះបញ្ជីរបស់ខ្លួនបានត្រឹមត្រូវ ។ ប្រធានបទនេះ នឹងក្លាយជាឯកសារជំនួយស្មារតីសម្រាប់គូភាគីទាំងជាសហព័ទ្ធ និង បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា ដើម្បីស្វែងយល់អំពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធឱ្យបានត្រឹមត្រូវ ជៀសវាងមានការទាមទារឱ្យមោឃៈភាព ឬ ទាមទារលុបចោលទៅលើកិច្ចសន្យារបស់ភាគី ។

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" គឺសិក្សាតែទៅលើលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាដែលរួមមានលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ ។ សិក្សាស្វែងយល់អានុភាពនៃកិច្ចសន្យា និង ការចុះបញ្ជីទៅលើកិច្ចសន្យាដែលជាករណីយកិច្ចរបស់ភាគី ព្រមទាំងការបញ្ចប់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ និងរបៀបដែលត្រូវលុបការចុះបញ្ជីក្រោយគូភាគីជាសហព័ទ្ធបានបញ្ចប់អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

ដោយបានយល់ឃើញអំពីគុណសម្បត្តិ ព្រមទាំងអត្ថប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិប្ដីប្រពន្ធតាមរយៈកិច្ចសន្យាចំពោះគូភាគីដែលជាសហព័ទ្ធក្នុងគ្រប់គ្រង និង ថែរក្សាទ្រព្យសម្បត្តិ ការសិក្សាស្រាវជ្រាវនឹងបង្ហាញអំពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវតាមរយៈ

បទប្បញ្ញត្តិដែលបានចារចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា និងបណ្តាលបទប្បញ្ញត្តិពិសេសដែលបានចារចែង ។ សារៈសំខាន់ចំពោះការស្រាវជ្រាវនេះផ្តោតចំពោះគូភាគីដែលមានបំណងចង់បង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ព្រោះប្រសិនបើគូភាគីមិនបានដឹងអំពីលក្ខខណ្ឌមួយចំនួនដែលត្រូវបានកម្រិតទេនោះ នាំឱ្យកិច្ចសន្យារបស់ភាគីអាចជួបប្រទះនឹងការលំបាកនៅពេលអនាគត ។ ក្រៅតែអំពីសារៈសំខាន់សម្រាប់គូភាគីដែលមានបំណងចង់បង្កើតកិច្ចសន្យាហើយនោះ ការស្រាវជ្រាវនេះអាចជាគតិក្នុងការសិក្សាពិចារណាសម្រាប់សិស្សនិស្សិតជាពិសេសផ្នែកនីតិសាស្ត្រនេះតែម្តង នឹងបានយល់កាន់តែស៊ីជម្រៅបន្ថែមទៀតអំពីការសិក្សាទៅលើនីតិបេតិកភណ្ឌ និង គ្រួសារ ។

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" គឺរួមមាន ៣ ផ្នែកធំៗដែលមានដូចជា ៖

**ជំពូកទី១ លក្ខខណ្ឌបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

**ជំពូកទី២ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

**ជំពូកទី៣ ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

# ជំពូកទី១

# លក្ខខណ្ឌបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាកិច្ចសន្យាដែលមានទិសដៅក្នុងការគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់សហព័ទ្ធ ជួយសម្រួលដល់ការប្រើប្រាស់ទ្រព្យសម្បត្តិប្ដីប្រពន្ធ តាមការចង់បានរបស់ប្ដីប្រពន្ធ និង តាមតម្រូវការជាក់ស្ដែងនៃជីវភាពរស់របស់សហព័ទ្ធ ។ ការប្រើប្រាស់ទ្រព្យសម្បត្តិប្ដីប្រពន្ធ មិនមានលក្ខណៈដូចគ្នានោះទេ ត្បិតថាវាមានការប្រែប្រួលទៅស្ថានភាពនៃជីវភាពរបស់ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នានៅថ្ងៃអនាគត ។ ហេតុនេះការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក៏អាចជាការសម្រួលដល់ការប្រើប្រាស់ទ្រព្យសម្បត្តិប្ដីប្រពន្ធផងដែរ ដោយកម្រិតអំពីការប្រើប្រាស់ទ្រព្យនោះដោយសមស្រប ។ ដើម្បីអាចឱ្យប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍នឹងគ្នាពេលអនាគត អាចធ្វើការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបាន តម្រូវឱ្យភាគី បំពេញនូវលក្ខខណ្ឌពីរធំៗ នោះគឺ លក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ ហើយអាចយកទៅតតាំងចំពោះតតិយជនបានលុះត្រាតែភាគីបានអនុវត្តតាមលក្ខខណ្ឌតតាំង ទៅនឹងតតិយជនដែលនឹងមានបង្ហាញក្នុងលក្ខខណ្ឌទម្រង់នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

## ផ្នែកទី១ លក្ខខណ្ឌគ្រឹះនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

លក្ខខណ្ឌគ្រឹះសម្រាប់បង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺជាលក្ខខណ្ឌដែលកើតចេញអំពីការបង្ហាញឆន្ទៈរបស់ភាគីជាសហព័ទ្ធនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ហើយការបង្ហាញឆន្ទៈរបស់ភាគីត្រូវប្រកបដោយ សមត្ថភាពទាំងខាងឆន្ទៈ និង សកម្មភាព ។ ក្រៅអំពីឆន្ទៈក្នុងការបង្កើតកិច្ចសន្យាហើយ លក្ខខណ្ឌដែលសហព័ទ្ធទាំងសង មិនអាចបំពានបានគឺ ខ្លឹមសារផ្ទុយទៅនឹងអត្ថបទច្បាប់ ព្រមទាំងសណ្ដាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ ប្រពៃណីល្អរបស់សង្គមជាតិផងដែរ ។ ឆន្ទៈរបស់ភាគី សំដៅដល់ការព្រមព្រៀងរបស់ភាគី ក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ឱ្យមានសុពលភាព ។ នៅក្នុងវិស័យកិច្ចសន្យា ភាគីដាច់ខាតត្រូវតែជាអ្នកមានសមត្ថភាពទាំងក្នុងការបង្ហាញឆន្ទៈ និង សមត្ថភាពក្នុងការធ្វើសកម្មភាព ទៅតាមការព្រមព្រៀងដែលខ្លួនបានចរចា ។[2]

### ១.ការព្រមព្រៀងរបស់ភាគី

ការបង្ហាញឆន្ទៈរបស់ភាគី គឺជាកត្តាសំខាន់ដែលជំរុញឱ្យមានការព្រមព្រៀងមួយប្រកបដោយភាពត្រឹមត្រូវ ។ ការព្រមព្រៀងរបស់ភាគី គឺជាកត្តាសំខាន់ដែលនាំឱ្យកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ អាចប្រព្រឹត្តទៅបាន

[2] មាត្រា ១៤ និង មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

ត្បិតថានៅពេលដែលសហព័ទ្ធ បានឆន្ទៈថានឹងបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នោះនឹងបង្កើតឱ្យមាននូវសិទ្ធិ និង ករណីយកិច្ចចំពោះគូភាគី ។[3] ប៉ុន្តែប្រសិនបើភាគីណាម្ខាង បានបង្ហាញឆន្ទៈព្រមព្រៀងដោយមានវិការៈនោះការព្រមព្រៀមដែលបង្កើតបានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរវាងអ្នកទាំងពីរ ក៏អាចត្រូវបានលុបចោលនូវកិច្ចសន្យានោះផងដែរ ។[4] ដូចគ្នាទៅនឹងកិច្ចសន្យាផ្សេងៗទៀតដែរ ព្រោះជាគោលការណ៍នៃការបង្កើតកិច្ចសន្យាជាដាច់ខាត ត្រូវតែកើតឡើងអំពីឆន្ទៈរបស់ភាគីទាំងសងខាង ទើបច្បាប់ទទួលស្គាល់ថាជាកិច្ចសន្យាដែលមានសុពលភាព ។[5] ម៉្យាងវិញទៀត នៅពេលដែលភាគីបានបង្ហាញឆន្ទៈដែលមិនពិតប្រាកដ ឬ ទទួលបានការគំរាមកំហែងពីភាគីម្ខាងទៀត ដើម្បីឱ្យបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នោះកិច្ចសន្យាបែបនេះ មិនត្រូវបានទទួលស្គាល់ឡើយ ហើយកិច្ចសន្យានោះនឹងឱ្យមាននូវគុណវិបត្តិទៅភាគីម្ខាងដែលមិនបានឆន្ទៈឱ្យបានត្រឹមត្រូវ ។ ផលវិបាកនៃការបង្ហាញឆន្ទៈមានវិការៈរបស់សហព័ទ្ធ អាចនឹងនាំឱ្យ សហព័ទ្ធបាត់បង់នូវផលប្រយោជន៍ ដែលខុសពីគោលបំណងនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គឺដើម្បីថែរក្សានូវផលប្រយោជន៍ដល់សហព័ទ្ធ ដូច្នេះប្រសិនបើគោលបំណងនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនបានផ្តល់ផលប្រយោជន៍ ឬ គុណសម្បត្តិដល់សហព័ទ្ធទេ សហព័ទ្ធមិនគួរ បង្កើតកិច្ចសន្យានោះឡើយ ។

ជាការពិតណាស់ដែលការបង្ហាញឆន្ទៈរបស់ប្តីប្រពន្ធ ក៏អាចនឹងត្រូវបានរំលោភបំពានសិទ្ធិ ដោយសារតែ ការយល់ដឹងអំពីការប្រើប្រាស់នូវ ទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក ព្រមទាំងសិទ្ធិមួយចំនួនទៀត ។ ការបង្ហាញឆន្ទៈរបស់ប្តីប្រពន្ធ អាចត្រូវបានរំលោភបំពានទៅលើស្ថានភាពមួយចំនួន ដូចជា ផ្នែកចំណេះដឹង ផ្នែកបញ្ញាស្មារតីជាដើម ព្រោះថាក្នុងសង្គមយើងនាពេលបច្ចុប្បន្ន ការសិក្សាស្វែងយល់អំពីចំណេះដឹងផ្នែកច្បាប់ ពិសេសទៅលើនីតិទ្រព្យសម្បត្តិ និង គ្រួសារនេះតែម្តង ហាក់បីដូចជាមិនទាន់ទទួលបានភាពទូលំទូលាយនៅឡើយទេ ហេតុនេះវិវាទដែលពាក់ព័ន្ធទ្រព្យសម្បត្តិគ្រួសារនៅកើតមានឡើងជារឿយៗ ។[6]

ឆន្ទៈរបស់ប្តីប្រពន្ធ ក្នុងការព្រមព្រៀងបង្កើតកិច្ចសន្យា ក៏អាចប្រឈមនឹងបញ្ហាទៅលើការបំពានសិទ្ធិដោយមិនដឹងខ្លួនលើភាគីនៅពេលចាប់ផ្តើមជីវិតអាពាហ៍ពិពាហ៍ ត្បិតថានៅគ្រាដំបូងដែលភាគីបានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាចមិនទាន់យល់អំពីគ្នាច្បាស់នៅឡើយ ហេតុនេះការព្រមព្រៀង អាចកើតឡើងនៅ

---

[3] សេចក្តីកំណត់ចំពោះមាត្រា ៣០៩ កថាខណ្ឌទី២ "ប្រភពនៃកាតព្វកិច្ច" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[4] មាត្រា ៣៥៨ "សកម្មភាពដែលអាចលុបចោលបាន" នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ និង និង សេចក្តីកំណត់ចំពោះមាត្រា ៣៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៩-២០១០ ។

[5] មាត្រា ៣១១ "និយមន័យនៃកិច្ចសន្យា" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[6] តំណភ្ជាប់ https://www.unicef.org/cambodia/education (ចូលមើលថ្ងៃ ២ កក្កដា ២០២២) បានអំពីការបោះបង់ការសិក្សារបស់សិស្សតាំងពីនៅមធ្យមសិក្សា នៅព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះប្រសិនបើភាគី បានបោះបង់ការសិក្សានៅក្នុងថ្នាក់មធ្យមសិក្សា នោះការសិក្សារបស់ពួកគេ អាចមិនទទួលចំណេះដឹងអំពីសិទ្ធិតាមផ្លូវច្បាប់បានពេញលេញឡើយ ហេតុនេះការបំពានអាចកើតឡើងទៅសហព័ទ្ធដែលមានលក្ខណៈជាការកេងចំណេញទៅលើផលប្រយោជន៍ ។

ពេលដែលភាគីជាប្តីប្រពន្ធ ចេះតែស្របទៅតាមគ្នាដោយសារក្តីស្រលាញ់ និង មនោសញ្ចេតនារវាងគ្នា នឹង គ្នា ដូច្នេះការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវទាមទារឱ្យប្តីប្រពន្ធជាភាគីទាំងសងខាងនៃកិច្ចសន្យា ត្រូវតែគិតឱ្យបានល្អិតល្អន់ជាមុនសិន បើមិនដូច្នេះទេវានឹងមានបញ្ហានៅពេលក្រោយទៀតជាក់ជាពុំខាន ។ ប៉ុន្តែក៏មិនមានបញ្ហាអ្វីធ្ងន់ធ្ងរច្រើនដែរ បើភាគីទាំងសងខាងបានសម្រេចចិត្តព្រមព្រៀងគ្នាម្តងទៀត នៅពេលក្រោយក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ថានឹងចង់កែប្រែនូវសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុក្នុងកិច្ចសន្យា ព្រោះនៅកម្ពុជាមានប្រព័ន្ធដែលអនុញ្ញាតឱ្យភាគីទាំងសងខាងអាចធ្វើកែប្រែកម្មវត្ថុជាទ្រព្យសម្បត្តិ និង របៀបប្រើប្រាស់ទ្រព្យនោះទៅតាមការចង់បានរបស់ភាគី ក្រោយការចុះបញ្ជីតែត្រូវឆ្លងកាត់ការពិចារណារបស់តុលាការជាមុនសិន ទើបតម្រូវយកទៅចុះបញ្ជីអំពីការកែប្រែ ឬ ផ្លាស់ប្តូរនេះម្តងទៀត។[7] មានន័យថា នៅដែលភាគីកិច្ចសន្យាបានព្រមព្រៀងទាំងមិនច្បាស់លាស់ ឬ សម្របទៅតាមគ្នា នៅពេលបង្កើតកិច្ចសន្យា ក្រោយមកមានបំណងចង់ធ្វើការកែប្រែលើកិច្ចសន្យានោះឡើងវិញ ភាគីអាចធ្វើបាន ប៉ុន្តែត្រូវមានការអនុញ្ញាតពីតុលាការជាមុនសិន ទោះបីភាគីបានព្រមព្រៀងគ្នាហើយក៏ដោយ ។[8]

ការបង្ហាញឆន្ទៈក្នុងបង្កើតកិច្ចសន្យាប្តីប្រពន្ធ គឺជាបង្ហាញនូវឆន្ទៈក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរួម ហេតុនេះ ក្រោយការបង្ហាញឆន្ទៈរួចរាល់ ភាគីត្រូវមានករណីយកិច្ចក្នុងការដាក់ទ្រព្យសម្បត្តិដែលបានព្រមព្រៀងជាទ្រព្យសម្បត្តិរួម ។[9] តែស្ថិតនៅក្នុងករណីខ្លះ សង្កេតឃើញថាមិនចាំបាច់ឱ្យភាគីសងខាង មានករណីយកិច្ចដាក់ទ្រព្យសម្បត្តិចំពោះគ្នានោះទេ គឺមានភាគីតែម្ខាងជាអ្នកដាក់ទ្រព្យសម្បត្តិ ហើយភាគីម្ខាងទៀតអាចនឹងមិនមានករណីយកិច្ចដាក់ទ្រព្យសម្បត្តិរបស់ខ្លួនសម្រាប់បញ្ចូលជាទ្រព្យសម្បត្តិរួម គឺដោយសារភាគីម្ខាងនោះជួបប្រទះកត្តាជីវភាពក្រីក្រជាដើម......។[10]

## ២.សមត្ថភាពក្នុងបង្ហាញឆន្ទៈ

ករណីដែលភាគីជាអនីតិជនមានបំណងរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ព្រោះនៅពេលដែលអនីតិជនបានរៀបអាពាហ៍ពិពាហ៍ហើយ អនីតិជននោះត្រូវបានក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ សន្មតថាជា នីតិជន ហេតុនេះការបង្ហាញឆន្ទៈរបស់សាមីភាគី ជាឆន្ទៈដែលមានសុពលភាព ។[11] ម្យ៉ាងទៀត

[7] សូមមើលមាត្រា ៣០ កថាខណ្ឌទី ១ "ការចុះបញ្ជីចំពោះការផ្លាស់ ជាអាទិ៍" នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ របស់ព្រះរាជាណាចក្រកម្ពុជា។

[8] ប្រការ ២០ នៃប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ របស់ក្រសួងយុត្តិធម៌ ។

[9] មាត្រា ៣១៤ "កាតព្វប្រគល់វត្ថុដែលបានកំណត់ជាក់លាក់" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[10] មាត្រា ៣ "គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។ ចំពោះបញ្ហានេះ គឺជាការយល់ព្រមដោយស្ម័គ្រចិត្តរបស់ភាគី ហេតុនេះបញ្ហានេះ មិនមែនកត្តាដែលរារាំងដល់ការបង្កើតកិច្ចសន្យាប្តីប្រពន្ធឡើយ ។

[11] សូមមើលមាត្រា ២១ កថាខណ្ឌទី ២, មាត្រា ២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រសិនបើអនីតិជន ត្រូវបានមើលឃើញថាខ្វះសមត្ថភាព និង មិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបានត្រឹមត្រូវទេ ករណីនេះអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល អាចត្រូវផ្តល់ការយល់ព្រម ដើម្បីជាជំនួយដល់ការបង្ហាញឆន្ទៈរបស់អនីតិជន ត្បិតថាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នឹងមានអានុភាពក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធនាពេលអនាគត ហេតុនេះត្រូវការមានជំនួយពីអ្នកតំណាងតាមការកំណត់របស់ច្បាប់ ជាការជួយដល់ការការពារអនីតិជនអំពីការបំពានផងដែរ ។[12] មកដល់ត្រឹមនេះតែងតែមានបញ្ហាមួយចំនួនកើតឡើងថា តាមរយៈក្រមរដ្ឋប្បវេណីបានអនុញ្ញាតឱ្យជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ អាចរៀបការបាន តើជនដែលត្រូវបានកម្រិតសមត្ថភាពទាំងពីរប្រភេទនេះ អាចធ្វើការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដែរឬទេ ?

**២.១.ជនស្ថិតក្រោមហិតូបត្ថម្ភ**

ជនស្ថិតក្រោមហិតូបត្ថម្ភ ក៏អាចធ្វើការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដែរ ព្រោះថាជនស្ថិតក្រោមហិតូបត្ថម្ភ មិនទាន់បានបាត់បង់នូវស្មារតីរបស់ខ្លួនទាំងស្រុងនៅឡើយទេ គ្រាន់តែអាចយល់ដឹងបានតិចតួច និង អាចវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ។[13] ហេតុនេះជនស្ថិតក្រោមហិតូបត្ថម្ភ គឺអាចបង្កើតកិច្ចសន្យាបាន ប្រសិនបើជនស្ថិតក្រោមហិតូបត្ថម្ភអាចបង្ហាញឆន្ទៈរបស់ខ្លួន តែត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ហើយត្រូវដាក់ពាក្យសុំទៅកាន់តុលាការដើម្បីធ្វើការចេញលិខិតអនុញ្ញាតឱ្យបង្កើតកិច្ចសន្យាជាមុនសិន ។[14] ការអនុញ្ញាតឱ្យជនស្ថិតក្រោមហិតូបត្ថម្ភ បង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឡើង គឺដើម្បីការពារដល់ជនដែលស្ថិតក្រោមរបបនេះ ឱ្យចាកឆ្ងាយអំពីការរំលោភបំពានពីសហព័ទ្ធម្ខាងទៀត ព្រោះជួនកាលសហព័ទ្ធម្ខាងដែលជាភាគីម្ខាងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចនឹងយកភាពទន់ខ្សោយរបស់ជនស្ថិតក្រោមហិតូបត្ថម្ភ មកធ្វើជាហេតុដើម្បីគ្រប់គ្រងលើទ្រព្យសម្បត្តិ ដោយអះអាងអំពីករណីយកិច្ចរួមរស់នឹងគ្នារបស់ប្តីប្រពន្ធ យកធ្វើការចាត់ចែងលើទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ ។ ម៉្យាងទៀតក្នុងករណីដែលសហព័ទ្ធម្ខាងនោះមានហានិភ័យលើពាណិជ្ជកម្មរបស់ខ្លួន បំណុលអាចនឹងកើតមានឡើង ហេតុនេះបើមិនបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហានិភ័យលើទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធនឹងកើតមាន

[12] ចំណុចនេះមានលក្ខណៈស្រដៀងទៅនឹងមាត្រា ២០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ដែលបង្ហាញអំពី ការអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្មបាន ប៉ុន្តែករណីអនីតិជនមិនអាចបំពេញកិច្ចនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាល អាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះ ។

[13] មាត្រា ២៨ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ និង សទ្ទានុក្រមផ្នែករដ្ឋប្បវេណី លេខ១៧១ រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ។

[14] មាត្រា ៣០ ចំណុច ញ "សិទ្ធិលុបចោលសកម្មភាព" នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ និង មាត្រា ៣ ចំណុច ញ នៃច្បាប់ស្តីពី នីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

ឡើង ។ ដូច្នេះដើម្បីការពារដល់សិទ្ធិ និង ផលប្រយោជន៍របស់ជនស្ថិតក្រោមហិតូបត្ថម្ភ ហិតូបត្ថម្ភកៈគួរពិចារណាក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះឡើង ។

### ២.២.ជនស្ថិតក្រោមអាណាព្យាបាលទូទៅ

ជនស្ថិតក្រោមអាណាព្យាបាលទូទៅ មានភាពពិបាកណាស់ក្នុងការសម្រេចណាស់ថាអាចមានលទ្ធភាពបង្ហាញឆន្ទៈរបស់ខ្លួន ហេតុនេះតម្រូវឱ្យមានការចូលរួមជាដាច់ខាតពីអ្នកអាណាព្យាបាលទូទៅ ក្រៅពីនេះការត្រូវមានការចូលរួមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅផងដែរ ។ ត្បិតថាជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ស្ទើរតែគ្មានសមត្ថភាពខាងឆន្ទៈទាល់តែសោះ ប៉ុន្តែក្រមរដ្ឋប្បវេណីបានអនុញ្ញាតឱ្យជនដែលស្ថិតនៅក្នុងក្រោមអ្នកអាណាព្យាបាលទូទៅរៀបការបាន បើបានមានសមត្ថភាពបង្ហាញឆន្ទៈក្នុងខ្លួនក្នុងកម្រិតមួយជាអប្បបរមា ដោយមិនបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ ។[15] ចំណុចមានលក្ខណៈលំបាកនឹងធ្វើការពិចារណាថា តើពេលណាដែលជនស្ថិតក្រោមអាណាព្យាបាលទូទៅបានបង្ហាញឆន្ទៈ? ប៉ុន្តែយ៉ាងណាក៏ដោយបើជននោះបានបង្ហាញឆន្ទៈ ថាខ្លួនបានស្រលាញ់ទៅហើយ គឺអាចឲ្យពិចារណាថា អាចរៀបការបាន ។[16] ទោះបីគ្មានបទបញ្ញត្តិណាមួយដែលទាមទារឱ្យអ្នកអាណាព្យាបាលទូទៅ និង អ្នកត្រួតពិនិត្យអាណាព្យាបាលទូទៅត្រូវដាក់ពាក្យសុំទៅកាន់តុលាការក៏ដោយ ដើម្បីការពារសិទ្ធិរបស់ជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ គួរពិចារណាស្នើសុំតុលាការដើម្បីសម្រេចអំពីបញ្ហានេះ ព្រោះការស្នើសុំទៅកាន់តុលាការគឺជាទំនុកចិត្តមួយដល់ភាគីព្រមទាំងការធានានូវសុវត្ថិភាពលើកិច្ចសន្យានោះផងដែរ អាចនឹងមិនអាចមាននរណាអាចបំពារបំពានទៅថ្ងៃអនាគត ។[17] ការបង្កើតឱ្យមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទៅដល់ជនស្ថិតក្រោមអាណាព្យាបាល គឺជាការការពារសិទ្ធិមួយដល់ជនដែលស្ថិតក្រោមរបបនេះដូចជា ហានិភ័យដែលកើតពីពាណិជ្ជកម្មរបស់ភាគីម្ខាងទៀតជាដើម...។

## ៣.កម្មវត្ថុនៃកិច្ចសន្យាជាទ្រព្យសម្បត្តិ

កម្មវត្ថុនៃកិច្ចសន្យា គឺអាចបង្ហាញអំពីប្រភេទ និង ចំណងនៃកិច្ចសន្យា ឬ គោលបំណងនៃការបង្កើតកិច្ចសន្យា តួយ៉ាងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏មានលក្ខណៈដូចគ្នានឹងវិធានកិច្ចសន្យាផ្សេងៗទៀតផងដែរ គឺ

[15] មាត្រា ៩៥៤ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា

[16] មាត្រា ៩៥៤ វាក្យខ័ណ្ឌទី១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

[17] ចំពោះចំណុចនេះសូមមើលមាត្រា ៣០ ចំណុច ញ "សិទ្ធិលុបចោលសកម្មភាព" នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។ តាមពិតទៅមាត្រានេះ ចែងឡើងដើម្បីធ្វើការគ្រប់គ្រងទៅលើសកម្មភាពរបស់ជនដែលស្ថិតក្រោមហិតូបត្ថម្ភ ប៉ុន្តែសូមធ្វើការពិចារណាថា ជនស្ថិតក្រោមហិតូបត្ថម្ភនៅពេលចង់ធ្វើសកម្មភាពពិសេសណាមួយតម្រូវឲ្យទៅស្នើសុំពីតុលាការ ដើម្បីការពារសិទ្ធិ ប៉ុន្តែជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅបែរគ្មានបញ្ញត្តិណាមួយដែលតម្រូវឲ្យភាគីដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឬ ពាក្យសុំបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។ ហេតុនេះដើម្បីអាចការពារសិទ្ធិរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ គួរគប្បីទៅដាក់ពាក្យសុំពីតុលាការជាមុនសិន ឬសរសេរបញ្ជាក់ក្នុងពាក្យសុំប្រកាសរបបអាណាព្យាបាលទូទៅតែម្តងក៏បាន ។

មានកម្មវត្ថុដែលជាខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធសំដៅដល់ ការប្រើប្រាស់ របៀបគ្រប់គ្រងទៅលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ។ កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាទូទៅត្រូវបានស្គាល់ថាជាប្រភេទនៃការដាក់បញ្ចូលទ្រព្យសម្បត្តិដោយឡែករបស់ប្តី ឬ ប្រពន្ធ ទៅជាទ្រព្យសម្បត្តិរួមគ្នារបស់ប្តីប្រពន្ធ ឬក៏ សហព័ទ្ធ បានសម្រេចធ្វើការកែប្រែ ឬ ផ្លាស់ប្តូរទៅលើកម្មវត្ថុនៃកិច្ចសន្យាប្តីប្រពន្ធទៅរបៀបដែលសហព័ទ្ធចង់គ្រប់គ្រង ឬ ប្រើប្រាស់ ។ ក្រៅពីតែការដាក់បញ្ចូលនូវកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ភាគីនៃកិច្ចសន្យានេះក៏អាចធ្វើការកំណត់អំពីទំនាក់ទំនងកាតព្វកិច្ចបានផងដែរ ។ ប៉ុន្តែភាគីជាសហព័ទ្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា ត្រូវធានាថាខ្លឹមសារដែលជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មិនមានលក្ខណៈដែលផ្ទុយទៅនឹងបទប្បញ្ញត្តិច្បាប់ ។

### ៣.១.កម្មវត្ថុនៃកិច្ចសន្យាដែលផ្ទុយទៅនឹងបទប្បញ្ញត្តិ

ស្ថិតក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ ដែលបានចារចែងពីទ្រព្យសម្បត្តិរួមប្តីប្រពន្ធតាមរយៈកិច្ចសន្យា បានលើកឡើងអំពី ការចែងកិច្ចសន្យាដែលមានខ្លឹមសារផ្ទុយទៅនឹងភាគបម្រុង និង អាហារកាតព្វកិច្ច ។[18] ក្រៅអំពីការមិនអនុញ្ញាតឱ្យមានការចារចែងខ្លឹមសារដែលឈានដល់ការប៉ះពាល់ទៅលើសិទ្ធិទាមទារភាគមប្រុងរបស់សន្តតិជននៃសហព័ទ្ធ និង សិទ្ធិទាមទារអាហារកាតព្វកិច្ចនៃញាតិរបស់សហព័ទ្ធ ក្រមរដ្ឋប្បវេណីនេះ បានលើកឡើងអំពី ភាពមោឃភាព និង ការលុបលើចោលលើខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបំពានទៅលើសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់ខ្មែរផងដែរ ។

#### ៣.១.១.ការមិនបំពានទៅលើសិទ្ធិលើភាគបម្រុង

សិទ្ធិលើភាគបម្រុង ជាសិទ្ធិក្រៅបេតិកភណ្ឌមួយបែបដែលច្បាប់បានបញ្ញត្តិឡើងដើម្បីសង្គ្រោះដល់ផលប្រយោជន៍ អនាគត ជីវភាព និង សិទ្ធិតាមផ្លូវច្បាប់របស់សន្តតិជនម្នាក់ៗ ។ សន្តតិជនម្នាក់ដែលមិនបានទទួលនូវចំណែកមត៌ក ឬ ទទួលបានចំណែកមត៌កតិចតួចពេកដែលមិនបានស្មើនឹងចំនួនភាគបម្រុង មានសិទ្ធិទាមទារឱ្យផ្តល់នូវភាគបម្រុងពីសន្តតិជនផ្សេងទៀត ក្នុងចំណែកមួយជាអប្បបរមា ដែលត្រូវបានធានាដោយច្បាប់ជាធរមាន ។[19]

ករណីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ច្បាប់បានហាមឃាត់នូវរាល់ការផ្តាច់សិទ្ធិលើភាគបម្រុងរបស់ភាគី ដូច្នេះភាគីមិនអាចធ្វើការព្រមព្រៀង ឬ កំណត់ក្នុងកិច្ចសន្យាអំពីការផ្តាច់សិទ្ធិលើភាគបម្រុងបានឡើយ ។[20] ការហាមឃាត់ ចំពោះការចារខ្លឹមសារបំពានទៅលើភាគបម្រុង គឺដើម្បីឱ្យជនដែលអាចទទួលបានភាគបម្រុង

[18] មាត្រា ៩៦៩ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

[19] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគទី៣ ផ្នែកទី៣ ប្រធានបទ "ភាគបម្រុង" រៀបរៀងដោយក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈ ។

[20] មាត្រា ៩៦៩ កថាខ័ណ្ឌទី១ វាក្យខ័ណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

អាចបាននូវសិទ្ធិ និង ផលប្រយោជន៍របស់ខ្លួន តាមផ្លូវច្បាប់ ដែលជាគោលបំណងនៃការបង្កើតឡើងនូវប្រព័ន្ធភាគបម្រុង ។

**ឧទាហរណ៍ថា** ៖កាលពីថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០២២ កញ្ញា ឧម៉ា បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមានខ្លឹមសារនៃការព្រមព្រៀងថា "បើភាគីណាម្ខាងបានទទួលមរណៈភាព ភាគីម្ខាងដែលនៅរស់ អាចទទួលចំណែកមត៌កទាំងអស់របស់ភាគីម្ខាងទៀត" ។ ឃ្លាដែលបានបង្ហាញខាងលើនេះ គឺលោកវិស្ណុ និង អ្នក ឧម៉ា បានបំពានទៅលើសន្តិជនរបស់សហព័ទ្ធម្ខាង ដូច្នេះខ្លឹមសារបែបនេះ មិនបានគោរពតាមលក្ខខណ្ឌរបស់ច្បាប់ឡើយ ហេតុនេះនៅពេលដែលភាគីទៅធ្វើការចុះបញ្ជីនឹងមានការទាមទារឱ្យធ្វើការកែប្រែនូវខ្លឹមសារនៃការព្រមព្រៀងបែបនេះឡើងវិញ ។

ចំពោះកិច្ចសន្យាដែលបានធ្វើឡើងមុនកាលបរិច្ឆេទចូលជាធរមាននៃក្រមរដ្ឋប្បវេណី នឹងត្រូវតម្រូវឱ្យលុបចោលកិច្ចសន្យានោះតែម្តង ឬ ឃ្លាដែលបានព្រមព្រៀងក្នុងការផ្តាច់សិទ្ធិលើភាគបម្រុង ឬ អាចឱ្យភាគីម្ខាងដែលត្រូវបានផ្តាច់សិទ្ធិ ទាមទារឱ្យភាគីម្ខាងទៀតធ្វើការព្រមព្រៀងសាជាថ្មីចំពោះបញ្ហានេះ ។[21]

**ឧទាហរណ៍ថា** ៖ លោក វិស្ណុ និង នាង ឧម៉ា ជាប្តីប្រពន្ធ ។ នៅក្នុងឆ្នាំ ២០០៣ បានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលមានខ្លឹមសារថា "ករណីដែលភាគបម្រុងត្រូវបានបំពាន ដោយសារអច្ច័យទាន ឬ ប្រទានកម្ម ឬ ផលប្រយោជន៍ពិសេសដែលប្តីបានឱ្យទៅប្រពន្ធ អ្នកមានសិទ្ធិលើភាគបម្រុង មិនអាចមកធ្វើការកាត់បន្ថយពីផលដែលប្រពន្ធទទួលបានឡើយ " ។

ដោយកាលបរិច្ឆេទនៃការបង្កើតកិច្ចសន្យានេះ ត្រូវបានធ្វើឡើងមុនការចូលធរមាននៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ និង ប្រកាសស្តីពី "នីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ ហេតុនេះនៅពេលក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ បានចូលជាធរមានហើយ កិច្ចសន្យារបស់លោកវិស្ណុ និង អ្នកនាង ឧម៉ា តម្រូវទាមទារឱ្យគោរពតាមលក្ខខណ្ឌដែលក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ បានកំណត់វិញទើបមានអានុភាព និង អាចធ្វើការចុះបញ្ជីបាន ។

### ៣.១.២.ការមិនបំពានទៅលើសិទ្ធិទាមទារអាហារកាតព្វកិច្ច

សិទ្ធិទាមទារអាហារកាតព្វកិច្ច ដែលតម្រូវឱ្យបុគ្គលម្នាក់ ឬ ច្រើននាក់ត្រូវផ្តល់នូវប្រាក់ ឬ ទ្រព្យធនជាស្បៀងអាហារ ជាសម្លៀកបំពាក់ កន្លែងស្នាក់នៅ ការសិក្សារៀនសូត្រ ឬ ការព្យាបាលទៅដល់បុគ្គលដែលមានទំនាក់ទំនងញាតិនឹងគ្នា ដោយកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬ តាមសេចក្តីសម្រេចរបស់តុលាការ ។[22]

[21] មាត្រា ៥ កថាខ័ណ្ឌទី ៣ នៃច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ២០១១ ។

[22]សេចក្តីផ្តើម នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី និង សេចក្តីកំណត់ចំពោះមាត្រា ១១៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ រៀបចំដោយ ក្រសួងយុត្តិធម៌ ក្នុងឆ្នាំ២០០៩-២០១០ ។

ការហាមប្រាមមិនឱ្យបំពានទៅលើសិទ្ធិទាមទារអាហារកាតព្វកិច្ច គឺដើម្បីជួយដល់ភាគីម្ខាងទៀតដែលកំពុងជួបប្រទះនូវការលំបាកក្នុងជីវិតរស់នៅ ឱ្យមានជីវភាពរស់នៅបានសមរម្យ ហើយក៏អាចភាគីដែលត្រូវជាអ្នកផ្តល់នូវអាហារកាតព្វកិច្ចបានអនុវត្ត នូវកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវក្នុងនាមជាប្តីប្រពន្ធ គឺ កាតព្វកិច្ចសង្គ្រោះគ្នាក្នុងនាមជាគ្រួសារ [23] ។ ម្យ៉ាងវិញទៀតបើធ្វើការសង្កេតតាមជីវិតរបស់ប្រជាពលរដ្ឋខ្មែរជាក់ស្តែង គឺសង្កេតឃើញថា នៅពេលដែលសហព័ទ្ធរបស់ខ្លួន ឬ ក៏គ្រួសាររបស់សហព័ទ្ធនោះ ជួបប្រទះនឹងការលំបាក ដូចជា បញ្ហាសេដ្ឋកិច្ច បញ្ហាសុខភាព ជាអាទិ៍នោះ សហព័ទ្ធម្ខាងទៀតតែងតែធានាខ្លួន ជួយសង្គ្រោះគ្នាក្នុងនាមជាប្តីប្រពន្ធនឹងគ្នា ។ លើសពីនេះទៅទៀត ការជួយសង្គ្រោះគ្នាក្នុងនាមជាប្តីប្រពន្ធ ក្នុងសង្គមខ្មែរគឺជា សីលធម៌រវាងប្តី និង ប្រពន្ធ ដែលមិនអាចខ្វះបាន ។ ហេតុដែលនាំឱ្យការសង្គ្រោះគ្នានេះមិនអាចខ្វះបានព្រោះថា ពេលសហព័ទ្ធម្ខាងជួបទុក្ខលំបាក សហព័ទ្ធម្ខាងទៀតបដិសេធមិនជួយ វាហាក់បីដូចជា គ្មានមនុស្សធម៌ក្នុងខ្លួនទាល់តែសោះ ។ បើសង្កេតក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ ក៏បានតម្រូវឱ្យជនដែលមានលទ្ធភាព ត្រូវបានកាតព្វកិច្ចក្នុងការជួយផ្គត់ផ្គង់ដល់ញាតិដែលស្ថិតក្នុងលំបាក ដើម្បីអាចទ្រទ្រង់ជីវភាពរស់នៅបាន ។ ដូច្នេះប្រសិនបើភាគី បានចែងខ្លឹមសារនៃកិច្ចសន្យាដែលមិនផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺមានការប្រាសចាកអំពីច្បាប់ ។

អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ [24] ជាសិទ្ធិក្រៅបេតិកភណ្ឌ ដែលតម្រូវឱ្យភាគីជាប្តីប្រពន្ធត្រូវចេះសហការ និង សង្គ្រោះគ្នាទៅវិញទៅមកដូចជាការផ្តល់នូវប្រាក់ ឬ ទ្រព្យធននៅពេលដែលសហព័ទ្ធម្ខាងទៀតជួបប្រទះនៅការលំបាកដែលមិនអាចរ៉ាប់រងនូវបញ្ហាសេដ្ឋកិច្ច និង បញ្ហាផ្សេងៗរបស់ខ្លួន ហេតុនេះសហព័ទ្ធម្ខាងទៀតត្រូវសង្គ្រោះដល់សហព័ទ្ធម្ខាងដែលកំពុងជួបប្រទះការលំបាកនោះ ។ នៅពេលបង្កើតកិច្ចសន្យាភាគីមិនអាចចែងនូវខ្លឹមសារណាមួយដែល នាំឱ្យផ្តល់មានផលប៉ះពាល់ដល់អាហារកាតព្វកិច្ចរវាងសហព័ទ្ធបានឡើយ ទោះក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ក្តី ឬ ក្រោយអាពាហ៍ពិពាហ៍ក្តី [25] ។ ក្នុងប្រព័ន្ធអាហារកាតព្វកិច្ចនេះទៀតសោត បានសង្កេតឃើញថាមានប្រភេទនៃអាហារកាតព្វកិច្ចរវាងឪពុក-ម្តាយចំពោះកូនជាអនីតិជន និង អាហារកាតព្វកិច្ចចំពោះញាតិ ។[26]

---

[23]មាត្រា ៩៦៦ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ដែលទាមទារឲ្យប្តីប្រពន្ធត្រូវរួមរស់នឹងគ្នា សហការគ្នា និង សង្គ្រោះគ្នាទៅវិញទៅមក ។

[24]មាត្រា ១១៤០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[25] ក្នុងករណីនេះសំដៅលើការលែងលះអាពាហ៍ពិពាហ៍ដោយសារ មរណៈភាពភាគីម្ខាង ក្នុងករណីនេះម្ខាងភាគីនៅរស់ត្រូវផ្តល់អាហារកាតព្វកិច្ច បើមានការស្នើសុំ សូមមើលមាត្រា ១១៤០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[26] មាត្រា ១១៤០ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

**៣.១.៣.ការមិនបំពានលើសណ្តាប់ធ្នាប់សាធារណៈ**

កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវតែធានាថាមិនមានផលប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អ វប្បធម៌ប្រពៃណីដ៏ផូរផង់របស់សង្គមជាតិ ដូចជាការប្រើប្រាស់កម្មវត្ថុនៃកិច្ចសន្យាជាគ្រឿងញៀន ចំការដំណាំកញ្ឆា ម៉ា អាភៀន ការអនុញ្ញាតឱ្យមានការប្រើប្រាស់អំពើហិង្សាគ្រួសារ ការអនុញ្ញាតឱ្យមានទ្វេពន្ធភាព ជាដើម....។

ប្រសិនកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចអនុញ្ញាតឱ្យមានខ្លឹមសារដែលនាំឱ្យមានលក្ខណៈបំពារបំពានទៅលើសណ្តាប់ធ្នាប់សាធារណៈបែបនេះ តើសង្គមជាតិនឹងមានភាពចលាចលយ៉ាងណា? បើសហព័ទ្ធម្ខាងៗ មានសិទ្ធិប្រព្រឹត្តអំពើដែលប្រាសចាកអំពើទំនៀមទម្លាប់សង្គមហើយនោះ ។ ម្យ៉ាងវិញទៀតប្រសិន កម្មវត្ថុកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានអនុញ្ញាតឱ្យមានខ្លឹមសារ ឬ កម្មវត្ថុដែលលក្ខណៈផ្ទុយទៅនឹងទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ធៀបបាននឹងកំពុងតែជំរុញឱ្យសង្គមជាតិឈានទៅរកភាពអសន្តិសុខ ។ តួយ៉ាងក្រមរដ្ឋប្បវេណីបានលើកឡើងអំពីការមិនទទួលស្គាល់លើខ្លឹមសារនៃកិច្ចសន្យាទាំងឡាយ ដែលមានបានព្រមព្រៀងគ្នា មានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងទំនៀមទម្លាប់ល្អរបស់សង្គមជាតិផងដែរ ។

**៣.១.៤.មោឃភាពនៃកិច្ចសន្យា**

ការបំពានលើខ្លឹមសារដែលប្បញ្ញត្តិដោយច្បាប់ នឹងត្រូវបានមោឃភាព ព្រោះជាការបំពានទៅលើ សិទ្ធិទាមទារលើភាគបម្រុង សិទ្ធិទាមទារអាហារកាតព្វកិច្ច និង ខ្លឹមសារនៃកិច្ចសន្យាមានភាពផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទម្លាប់របស់សង្គមជាតិខ្មែរ ព្រមទាំងប្រពៃណីវប្បធម៌ផងដែរ ។[27] សហព័ទ្ធត្រូវធានាឱ្យបានថា រាល់ខ្លឹមសារ និង កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ របស់សាមីភាគីមិនត្រូវមានចំណុចណាមួយដែលមានអត្ថន័យដល់ការបំពានលើសិទ្ធិទាមទារភាគបម្រុង សិទ្ធិទាមទារអាហារកាតព្វកិច្ច និងសណ្តាប់ធ្នាប់សាធារណៈឡើយ បើមិនដូច្នេះកិច្ចសន្យានេះនឹងគ្មានសុពលភាពឡើយ ប៉ុន្តែចំពោះករណីនេះមិនត្រូវបានមោឃភាពទាំងស្រុងទៅលើ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទេ គឺអាចត្រូវមោឃភាពត្រឹមផ្នែកដែលបានសហព័ទ្ធបានព្រមព្រៀងគ្នា ហើយធ្វើឱ្យដល់ខ្លឹមសារដែលត្រូវបានច្បាប់ហាមឃាត់តែប៉ុណ្ណោះ ។[28] ដូចគ្នាដែរ ប្រសិនបើភាគីយកទៅធ្វើការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរបស់ខ្លួន នឹងត្រូវមន្ត្រីត្រួតពិនិត្យលើការចុះបញ្ជី បង្វែរកិច្ចសន្យានោះត្រឡប់មកវិញដើម្បីធ្វើការកែតម្រូវលើខ្លឹមសារនោះ ។[29]

[27] មាត្រា ៣៥៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ។

[28] មាត្រា៣៥៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ។

[29] ប្រការ ៣២ នៃប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ របស់ក្រសួងយុត្តិធម៌ ។

**៣.២.កម្មវត្ថុនៃកិច្ចសន្យាជាទ្រព្យសម្បត្តិ**

ជាទូទៅកិច្ចសន្យាណាក៏ដោយ ក៏មានកម្មវត្ថុរបស់ខ្លួន ដូចជាកិច្ចសន្យាលក់ទិញមាន អចលវត្ថុ ឬ ចលវត្ថុ ជាកម្មវត្ថុ ។ តួយ៉ាងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏មានកម្មវត្ថុរបស់ខ្លួនផងដែរសម្រាប់ធ្វើការអនុវត្ត ហើយកម្មវត្ថុដែលអាចប្រើប្រាស់អាចប្រើប្រាស់បានក្នុងប្រភេទនៃកិច្ចសន្យាមួយនេះ រួមមានដូចជា ចលវត្ថុ អចលវត្ថុ និង សិទ្ធិលើទ្រព្យសម្បត្តិមួយចំនួនទៀតដែលអនុញ្ញាតឱ្យធ្វើអនុប្បទានបាន ឬ បានកំណត់ថាអាចយកធ្វើជាកម្មវត្ថុនៃកិច្ចសន្យាបាន ។

**៣.២.១.អចលវត្ថុ និង ចលវត្ថុ**

ជាទូទៅអចលវត្ថុ ឬ ចលវត្ថុ បានក្លាយជាកម្មវត្ថុ ដ៏ពេញនិយម នៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ព្រោះថា វត្ថុទាំងពីរនេះមានរូបរាងច្បាស់លាស់ និងទទួលបាន ការទទួលស្គាល់ច្រើនពីសំណាក់ពលរដ្ឋដែលចូលចិត្តបង្កើតកិច្ចសន្យាផ្សេងៗ ដោយវាមានភាពងាយស្រួលក្នុងរក្សាទុក និង ការពារ ជាងកម្មវត្ថុផ្សេងទៀត ។ ប៉ុន្តែមុននឹងយកមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យា ភាគីត្រូវដឹងពីសាវតានៃវត្ថុជាមុនសិន ព្រោះវត្ថុនោះអាចនឹងក្លាយជាប្រាតិភោគនៃបំណុល ឬ ជាទ្រព្យដែលជាប់បំណុល មុននឹងក្លាយជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិរបស់សហព័ទ្ធ ។ ហេតុនេះសហព័ទ្ធ គួរតែធ្វើការសិក្សាពីសាវតានៃវត្ថុ ឬ ធ្វើការព្រមព្រៀងគ្នាឱ្យបានល្អិតល្អន់លើបញ្ហានេះ ជៀសវាងនឹងមានវិវាទនៅថ្ងៃក្រោយ ។

**៣.២.២.សិទ្ធិលើទ្រព្យសម្បត្តិមួយចំនួន**

សិទ្ធិលើទ្រព្យសម្បត្តិមួយចំនួនអាចមានជាទូទៅ សិទ្ធិប្រើប្រាស់ អាស្រ័យនៅ និង អាស្រ័យផល សិទ្ធិចាត់ចែង សិទ្ធិលើសេវភាព សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិកាន់កាប់ សិទ្ធិលើផលុបភោគ ជាដើម..។ សិទ្ធិលើទ្រព្យសម្បត្តិបានរៀបរាប់ខាងលើ គឺជាសិទ្ធិដែលកើតឡើងតាមរយៈតាមសិទ្ធិប្រត្យក្សរបស់សហព័ទ្ធ ដែលសិទ្ធិទាំងនេះនឹងក្លាយជាកម្មវត្ថុនៃកិច្ចសន្យានានាដែលបានចែងក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ។ តួយ៉ាងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏មាននូវកម្មវត្ថុដែលជាសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះដែរ ។ ក្រៅតែអំពី កម្មវត្ថុជា អចលវត្ថុ ឬ ចលវត្ថុហើយ កម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលអាចជាសិទ្ធិលើទ្រព្យសម្បត្តិ [30] ផ្សេងទៀតដូចជា សិទ្ធិជួលអចិន្ត្រៃយ៍ សិទ្ធិលើផលុបភោគ និង សិទ្ធិលើបំណុល ។ ចំណែកឯសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតដូចជា សិទ្ធិលើសេវភាព សិទ្ធិប្រើប្រាស់ អាស្រ័យនៅ និង អាស្រ័យផល សិទ្ធិកាន់កាប់ នឹងក្លាយជាសិទ្ធិភ្ជាប់មកជាមួយនៅពេលសហព័ទ្ធទាំងសងខាងបានព្រមគ្នាយកសិទ្ធិជួលអចិន្ត្រៃយ៍ និង សិទ្ធិលើផលុបភោគ ។

[30] ប្រកាសស្តីពី "នីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ ត្រង់ឯកសារភ្ជាប់នៃពាក្យសុំ ដែលតម្រូវឲ្យភាគីត្រូវដាក់វិញ្ញាបនបត្របញ្ជាក់អំពីព័តមានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជីដីធ្លី ។

**ក.សិទ្ធិជួលអចិន្ត្រៃយ៍**

សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅលើសិទ្ធិជួលអចលវត្ថុដែលមានរយៈពេលវែងចាប់ពី ១៥ ឆ្នាំ[31] ឡើងទៅ ៥០ ឆ្នាំ [32] ។ ភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ យកអាចសិទ្ធិជួលអចិន្ត្រៃយ៍មកធ្វើកម្មវត្ថុនៃកិច្ចសន្យាបាន ដោយសារ សិទ្ធិអចិន្ត្រៃយ៍បានលើកឡើងអំពី ការធ្វើអនុប្បទានទៅលើសិទ្ធិជួលអចិន្ត្រៃយ៍ ហើយសិទ្ធិនេះយកធ្វើជាកម្មវត្ថុនៃសន្តតិកម្មបានដូចគ្នា ។[33] ដើម្បីអាចឱ្យភាគីម្ខាងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចប្រើប្រាស់ និង អាស្រ័យផលលើសិទ្ធិជួលអចិន្ត្រៃយ៍ ភាគីម្ខាងដែលជាអ្នកជួលអចិន្ត្រៃយ៍ គួរតែជូនដំណឹងអំពីការយកសិទ្ធិនេះ ទៅធ្វើជាកម្មវត្ថុនៃកិច្ចសន្យាជាមុនសិន ។[34] ភាគីម្ខាងដែលជាអ្នកជួលអចិន្ត្រៃយ៍ អាចធ្វើការចុះកិច្ចសន្យាជួលអចិន្ត្រៃយ៍ ដោយកំណត់អំពីបញ្ហានេះ ក៏បានដែរ ។

**ឧទាហរណ៍ ៖** លោក មន្នី បានធ្វើកិច្ចសន្យាជួលអចិន្ត្រៃយ៍ទៅលើដីចំការមួយកន្លែង ពី លោក មុនិន ។ ក្រោយមកលោក មន្នី បានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាមួយនឹងភរិយា ដោយយកសិទ្ធិជួលអចិន្ត្រៃយ៍ធ្វើជាកម្មវត្ថុទ្រព្យរួម ។

**ខ.សិទ្ធិលើផលុបភោគ**

ផលុបភោគ ជាសិទ្ធិប្រើប្រាស់ និង អាស្រ័យផលទៅលើអចលវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ដោយការយល់ព្រម មានរយៈពេលកំណត់មិនលើសពីមួយជីវិតរបស់ផលុបភោគី ។ [35] តាមរយៈសិទ្ធិលើផលុបភោគបានអនុញ្ញាតឱ្យផលុបភោគីជាភាគីម្ខាងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចធ្វើអនុប្បទានលើផលុបភោគនេះទៅឱ្យនរណាក៏បានដោយយកថ្លៃ ឬ មិនយកថ្លៃ ។ [36] ដូច្នេះភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចយកសិទ្ធិលើផលុបភោគមកធ្វើជាកម្មវត្ថុបាន ។ មុនពេលដែលភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បានយកសិទ្ធិផលុបភោគជាកម្មវត្ថុនៃកិច្ចសន្យាគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន ភាគីក៏គួរតែដឹងអំពីការរំលត់នៃផលុបភោគីផងដែរ ព្រោះថា ផលុបភោគី អាចនឹងត្រូវបានរំលត់នៅពេលដែលផលុបភោគីដំបូងដែលជាភាគីម្ខាងនៃកិច្ចសន្យាទ្រព្យសម្បត្តិបានទទួលមរណៈភាព ឬ ផលុបភោគនោះត្រូវរលត់ដោយអំឡុងពេលដែលបានកំណត់ក្នុងកិច្ច

[31] មាត្រា ២៤៤ "និយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[32] មាត្រា ២៤៧ កថាខណ្ឌទី ១ "អំឡុងពេលដែលសិទ្ធិអចិន្ត្រៃយ៍មានអត្ថិភាព" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[33] មាត្រា ២៥២ កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ "អនុប្បទាន ជាអាទិ៍ នូវសិទ្ធិជួលអចិន្ត្រៃយ៍"នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[34] មាត្រា ២៥៥ និង មាត្រា ៦១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។ ចំណុចនេះ ភាគី ត្រូវជូនដំណឹងអំពីការយកសិទ្ធិជួលអចិន្ត្រៃយ៍ ទៅដាក់ជាកម្មវត្ថុ(ទ្រព្យរួម) ទៅកាន់កម្មសិទ្ធិករនៃវត្ថុឱ្យបានដឹងអំពីបញ្ហានេះ ។

[35] មាត្រា ២៥៦ កថាខណ្ឌទី ១ ស្តីពី និយមន័យនៃផលុបភោគ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ព្រះរាជាណាចក្រកម្ពុជា ។

[36] មាត្រា ២៦៣ "អនុប្បទាន ជាអាទិ៍ នូវផលុបភោគ" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

សន្យាផលុបភោគ ។[37] ក្រៅពីនេះភាគីម្ខាងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាផលុបភោគី ក៏ត្រូវធ្វើការជូនដំណឹងទៅកាន់កម្មសិទ្ធិករ ចំពោះការណ៍ដែលផលុបភោគី យកផលុបភោគទៅធ្វើជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដើម្បីជាការគោរពទៅដល់កម្មសិទ្ធិករ និងឱ្យស្របនឹងសិទ្ធិរបស់កម្មសិទ្ធិករ ជៀសវាងនឹងមានការទាមទារឱ្យរំលត់ផលុបភោគ ។[38]

**ឧទាហរណ៍ ៖** លោក រដ្ឋា ជាផលុបភោគី នៃដីដែលជាផលុបភោគរបស់ លោក វិចិត្រ ។ ក្រោយមកលោក រដ្ឋា បានរៀបអាពាហ៍ពិពាហ៍នឹង អ្នកនាង នីតា បានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយយកដីដែលជាផលុបភោគមកធ្វើជាកម្មវត្ថុ ដោយជូនដំណឹងទៅលោក វិចិត្រ ក៏បានយល់ព្រម ។

**គ.សិទ្ធិលើបំណុល**

ភាគីជាសហព័ទ្ធនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចយកកម្មវត្ថុជាសិទ្ធិលើបំណុលដែលភាគីមានទៅដាក់ជាកម្មវត្ថុនៃកិច្ចសន្យារបស់ខ្លួនបាន ព្រោះក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ផ្តល់សិទ្ធិឱ្យម្ចាស់សិទ្ធិលើបំណុលអាចធ្វើអនុប្បទានសិទ្ធិលើបំណុលរបស់ខ្លួន ទៅនរណាក៏បានដោយសេរី ឱ្យតែបានទទួលការយល់ព្រមពីកូនបំណុល ព្រោះបើកូនបំណុលមិនបានបង្ហាញឆន្ទៈយល់ព្រមចំពោះការអនុប្បទាន សហព័ទ្ធដែលជាអនុប្បទានិក មិនអាចតតាំងនឹងកូនបំណុល និង តតិយជនបានឡើយ ។[39]

**ឧទាហរណ៍ថា ៖** លោក សម្បត្តិ ជាកម្មសិទ្ធិករនៃដី L មួយកន្លែងបានជួលអចិន្ត្រៃយចំនួន ៥០ ឆ្នាំ ទៅលោក មេត្តា ។ ហេតុនេះលោក សម្បត្តិ ជាម្ចាស់បំណុលដែលអាចទទួលប្រាក់ឈ្នួលអចិន្ត្រៃយ៍ពីលោក មេត្តា ។ ក្នុងករណីនេះប្រសិនបើលោក សម្បត្តិ បានរៀបអាពាហ៍ពិពាហ៍ ហើយចង់យកសិទ្ធិលើបំណុលខ្លួនទៅដាក់ជាកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ(ទ្រព្យរួម) គឺអាចប្រព្រឹត្តទៅបាន ហើយដើម្បីអាចឱ្យសហព័ទ្ធលោក សម្បត្តិ អាចតតាំងចំពោះកូនបំណុលដែលជា លោក មេត្តា នោះលោក សម្បត្តិ ត្រូវជូនដំណឹងនេះទៅកាន់លោក មេត្តា ជាមុនសិន ។

ការអនុញ្ញាតឱ្យគូភាគីជាសហព័ទ្ធ អាចយកសិទ្ធិលើបំណុរបស់ខ្លួនមកធ្វើជាកម្មវត្ថុនៃកិច្ចសន្យា គឺដោយសារតែ សិទ្ធិលើបំណុល ម្ចាស់បំណុលអាចធ្វើអនុប្បទាននូវសិទ្ធិលើទ្រព្យសម្បត្តិរបស់ខ្លួនបានដោយសេរី ហេតុនេះប្រសិនបើសហព័ទ្ធម្ខាងមានឆន្ទៈបង្ហាញអំពីការអនុប្បទានសិទ្ធិលើបំណុលនេះមួយផ្នែក ឬ ទាំងស្រុងទៅឱ្យសហព័ទ្ធរបស់ខ្លួន ដូច្នេះការអនុប្បទានអាចប្រព្រឹត្តទៅបានតាមរយៈគោលការណ៍ស្វ័យភាពនៃបុគ្គលឯក

[37] មាត្រា ២៥៨ , មាត្រា ២៦៧ និង មាត្រា ២៦៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[38] មាត្រា ២៦៦ "ករណីយកិច្ចជូនដំណឹងរបស់ផលុបភោគី" និងមាត្រា ២៦៧ "ការទាមទារឱ្យរំលត់ផលុបភោគ"នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[39] មាត្រា ៥០២ និង មាត្រា ៥០៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

ជន ប៉ុន្តែត្រូវធានាថាសិទ្ធិលើបំណុលដែលសហព័ទ្ធធ្វើអនុប្បទាននោះត្រូវស្របតាមការអនុញ្ញាតរបស់ច្បាប់ ហើយសិទ្ធិនោះមានលក្ខណៈអាចអនុប្បទានបាន ។[40]

### ៤.លក្ខខណ្ឌពិសេសនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យភាគីជាប្ដីប្រពន្ធ អាចបង្កើត កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបានទាំងមុន ឬ ក្រោយអាពាហ៍ពិពាហ៍ ។[41] ហេតុនេះលក្ខខណ្ឌនៃការតម្រូវការ ចំពោះបញ្ហានេះ ក៏មានអញ្ញាត្រកម្មទៅតាមការអនុវត្តដែរ ។ ភាគីដែលបានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ត្រូវបង្ហាញអំពីកាលបរិច្ឆេទនៃអាពាហ៍ពិពាហ៍ ព្រមទាំងសំបុត្រ អាពាហ៍ពិពាហ៍ ហើយចំពោះភាគីជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាចបង្កើតកិច្ចសន្យាទ្រព្យ សម្បត្តិប្ដីប្រពន្ធ និងធ្វើការចុះបញ្ជីបានដូចគ្នា ។

សំបុត្រអាពាហ៍ពិពាហ៍ ឬ សំបុត្រអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ គឺជាលក្ខខណ្ឌពិសេសដែល ត្រូវកំណត់ដោយវិធានគតិយុត្តដទៃទៀតដែលចែងពីប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមរយៈកិច្ចសន្យា គឺ ប្រកាស ស្ដីពី "នីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ២០១៣ ។ ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវបាន តម្រូវឲ្យចុះបញ្ជីអត្រានុកូលដ្ឋានស្ដីពីអាពាហ៍ពិពាហ៍ ដើម្បីឱ្យបញ្ជាក់អំពីភាពជាឯកព័ន្ធនៃសហព័ទ្ធ និង ត្រូវបាន ធានានូវសិទ្ធិ និងកាតព្វកិច្ចក្នុងនាមជាប្ដីប្រពន្ធ ហើយបើប្ដីប្រពន្ធមិនបានធ្វើការចុះបញ្ជីអត្រានុកូលដ្ឋាននេះទេ នាំឲ្យបាត់បង់នូវសិទ្ធិតាមផ្លូវច្បាប់ដែលអាចទទួលបាន ។ ដូចគ្នានេះដែរ ប្ដីប្រពន្ធដែលរៀបអាពាហ៍ពិពាហ៍ ដោយមិនចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជា ប្ដីប្រពន្ធអនីតិសង្វាស ហើយប្ដីប្រពន្ធដែលគ្មានសំបុត្រ អាពាហ៍ពិពាហ៍ក៏មិនអាចធ្វើការចុះបញ្ជីបានដែរ ។ តួយ៉ាងករណីព្រះរាជាណាចក្រថៃ ប្ដីប្រពន្ធដែលបង្កើត កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ(Prenuptial agreement) ត្រូវតែយកទៅចុះក្នុងបញ្ជីអាពាហ៍ពិពាហ៍ នៅពេល ដែលភាគីទៅធ្វើចុះបញ្ជីអាពាហ៍ពិពាហ៍ បើមិនដូច្នេះទេកិច្ចសន្យានឹងត្រូវចាត់ទុកជាមោឃៈ ។[42] ច្បាប់នៃប្រទេស ថៃបានកម្រិតទៅលើចំណុចនេះយ៉ាងច្បាស់អំពីការចុះបញ្ជីអាពាហ៍ពិពាហ៍ ដូច្នេះបើភាគីបង្កើតកិច្ចសន្យា ហើយ អាចមានអានុភាពយកទៅអនុវត្តបាន លុះត្រាតែសាមីភាគីទៅធ្វើចុះសំបុត្រអាពាហ៍ពិពាហ៍ដែរ ក្រៅពីនេះក៏ កំណត់នូវលក្ខខណ្ឌមួយចំនួនទៀតផងដែរដូចជា សាក្សីនៃកិច្ចសន្យា ជាដើម...។ [43] ចំណែកករណីនៅ សាធារណៈរដ្ឋសង្គមនិយមវៀតណាមវិញ បានលើកឡើងថា ប្ដីប្រពន្ធ ដែលបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដី

[40] មាត្រា ៥០១ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ បានបញ្ញត្តិអំពីការមិនអនុញ្ញាតឱ្យធ្វើអនុប្បទានសិទ្ធិលើបំណុលក្នុង ស្ថានភាពមួយចំនួនដូចជា សិទ្ធិលើបំណុលនៃអាហារកាតព្វកិច្ច ។

[41] មាត្រា ៩៦៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ របស់ព្រះរាជាណាចក្រកម្ពុជា ។

[42] សូមមើលមាត្រា ១៤៦៦ នៃក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម នៃព្រះរាជាណាចក្រថៃ ។

[43] សូមមើលមាត្រា ១៤៦៦ នៃក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម នៃព្រះរាជាណាចក្រថៃ ។

ប្រពន្ធត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ត្រូវមានលិខិតបញ្ជាក់[44] អំពីកិច្ចសន្យានោះ ហើយកិច្ចសន្យានេះនឹងមានអានុភាព នៅពេលដែលប្តីប្រពន្ធចុះសំបុត្រអាពាហ៍ពិពាហ៍ ។ ត្រង់ចំណុចនេះច្បាប់ស្តីអំពី អាពាហ៍ពិពាហ៍ និង គ្រួសារឆ្នាំ ២០១៤ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម បានបង្ហាញយ៉ាងច្បាស់អំពីសារៈសំខាន់នៃសំបុត្រអាពាហ៍ពិពាហ៍ ព្រោះថា បើភាគីដែលបានបង្កើតកិច្ចសន្យា មិនបានទៅធ្វើការចុះសំបុត្រអាពាហ៍ពិពាហ៍ទេ នោះអានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរបស់ភាគី ក៏មិនអាចកើតឡើងបានដែរ ត្បិតបានប្រាសចាកពីគោលបំណងនៃកិច្ចសន្យានេះ ដែលត្រូវបង្កើតឡើងសម្រាប់ភាគីជាប្តីប្រពន្ធស្របតាមវិធានគតិយុត្ត មិនមែនបង្កើតឡើងសម្រាប់ប្រព័ន្ធអនីតិសង្វាសនោះទេ ។

## ផ្នែកទី២ លក្ខខណ្ឌទម្រង់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

នៅពេលភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលជាសហព័ទ្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានបំពេញនូវលក្ខខណ្ឌគ្រឹះនៃកិច្ចសន្យារួចរាល់ហើយ ភាគីត្រូវតម្រូវឱ្យ មានករណីយកិច្ចបន្តបំពេញនូវលក្ខខណ្ឌទម្រង់បន្តទៀត ។ លក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ រួមមានលក្ខខណ្ឌតតាំងទៅនឹងតតិយជនដែលជាប្រព័ន្ធនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ការលាយល័ក្ខណ៍អក្សរ ។

### ១.ភាពចាំបាច់នៃការសរសេរជាលាយល័ក្ខណ៍អក្សរ

ប្រព័ន្ធកិច្ចសន្យាសរសេរជាលាយល័ក្ខណ៍អក្សរ ត្រូវបានក្លាយជាលក្ខខណ្ឌដ៏សំខាន់ ក្នុងការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ក៏បានទាមទារឱ្យភាគីត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាចាំបាច់ ព្រោះកិច្ចសន្យានេះនឹងមានឥទ្ធិពលទៅលើសិទ្ធិ និង ករណីយកិច្ចលើទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ និង ក្រោយពេលអាពាហ៍ពិពាហ៍ ។[45] ការកំណត់ជាដាច់ខាតដែលតម្រូវឱ្យភាគីនៃកិច្ចសន្យាត្រូវតែសរសេរជាលាយល័ក្ខណ៍អក្សរ គឺដើម្បីការពារដល់សិទ្ធិ និងធានាឲ្យបាននូវកាតព្វកិច្ចរបស់ភាគី ជៀសវាងមានការក្លែងបន្លំដោយប្រការណាមួយ ។ ការក្លែងបន្លំក្នុងករណីនេះសំដៅទៅលើការកែប្រែទៅលើខ្លឹមសារណាមួយនៃកិច្ចសន្យាដោយភាគីម្ខាង ហើយភាគីម្ខាងទៀតមិនបានដឹង

[44] នៅត្រង់ចំណុចនេះ សាធារណៈរដ្ឋសង្គមវៀតណាម ហាក់បីដូចជាមានការខុសប្លែកពីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង ថៃ បន្តិច ព្រោះក្នុងច្បាប់នៃប្រទេសមិនបានបង្ហាញពីការចុះបញ្ជីទេ តែបានបង្ហាញពីលិខិតបញ្ជាក់អំពីកិច្ចសន្យាទៅវិញ ដោយយោងតាមមាត្រា ៤៧ វាក្យខណ្ឌទី១ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ២០១៤ លេខ 52/2014/QH13 ។ បើតាមអត្ថន័យវាក្យខ័ណ្ឌនៃមាត្រានេះ អាចឲ្យយល់បានថា កិច្ចសន្យានេះត្រូវធ្វើលិខិតយថាភូត ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃកិច្ចសន្យានេះ ។

[45] លក្ខខណ្ឌនៃការសរសេរជាលាយល័ក្ខណ៍អក្សរ សូមមើលមាត្រា ៩៧០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ។

អំពីការកែប្រែនេះ ក្រៅពីការពារទៅលើភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ការកំណត់ជាដាច់ខាតឱ្យសរសេរជាលាយល័ក្ខណ៍អក្សរ ក៏ជាការការពារទៅលើតតិយជនផងដែរ ព្រោះប្រសិនបើអនុញ្ញាតិឱ្យភាគីធ្វើការព្រមព្រៀងដោយផ្ទាល់មាត់ នោះនឹងភាពច្របូកច្របល់កើតឡើងជាក់ជាមិនខាន ត្បិតនៅពេលដែលតតិយជន អាចជាម្ចាស់បំណុលមកទាមទារបំណុលលើភាគី ភាគីអាចមានឱកាសគេចវេចពីកាតព្វកិច្ច ដោយលើកឡើងអំពីការសន្យាផ្ទាល់មាត់របស់ភាគីជាដើម ។ ក្នុងករណីដែលភាគីមិនបានសរសេរជាលាយល័ក្ខណ៍អក្សរនោះទេ គឺកិច្ចសន្យានោះ គ្មានអានុភាពចំពោះភាគី និង តតិយជនឡើយ ដូច្នេះភាគីត្រូវតម្រូវឱ្យអនុវត្តប្រព័ន្ធទ្រព្យសម្បត្តិតាមរយៈការកំណត់របស់ច្បាប់វិញ ។[46] ឯករណីសាធារណៈរដ្ឋសង្គមនិយមវៀតណាម គូភាគីត្រូវកម្រិតឱ្យបានតម្រូវឲ្យសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវយកបញ្ជាក់ពីសារការីផងដែរ ។[47] ដូចគ្នានេះដែរ ក្នុងករណីព្រះរាជាណាចក្រថៃ គឺសរសេរជាលាយល័ក្ខណ៍ និង ត្រូវតម្រូវឱ្យមានសាក្សី ២ នាក់ថែមទៀតផង ហើយទើបមកទៅចុះក្នុងបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ជាក្រោយ ។[48]

## ២.ការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពុំមែនជាលក្ខខណ្ឌចាប់បង្ខំទៅលើភាគីនោះទេ ប៉ុន្តែជាលក្ខខណ្ឌដែលភាគីគួរតែអនុវត្តផងដែរ ដើម្បីអាចទទួលបាន ការទទួលស្គាល់ពីច្បាប់ ហើយអាចធានាបានថាកិច្ចសន្យារបស់ភាគីបានធ្វើឡើងជាសាធារណៈ ព្រមទាំងជាលក្ខខណ្ឌតតាំងទៅនឹងតតិយជនផងដែរ ។[49]

### ២.១.អំពីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

#### ២.១.១.សញ្ញាណនៃការចុះបញ្ជី

ការចុះបញ្ជីទៅកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានក្លាយជា លក្ខខណ្ឌក្នុងការតតាំងទៅនឹងតតិយជន និង ត្រូវបានការការពារពីច្បាប់មិនថាសម្រាប់ភាគីនៃកិច្ចសន្យា ឬ តតិយជននោះទេ[50] ។ សហព័ទ្ធ ឬ បុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍នឹងគ្នា អាចធ្វើការចុះបញ្ជីបានត្រូវគោរពតាមលក្ខខណ្ឌដែលបានធ្វើការកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ និង ត្រូវគោរពតាមលក្ខខណ្ឌមួយចំនួនទៀតដូចជា អនុវត្តទម្រង់ពាក្យសុំចុះបញ្ជីដែលបានកំណត់នៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពី "នីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ ។

---

46 កថាខណ្ឌទី ២ មាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណី ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ។

47 មាត្រា ៤៧ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ២០១៤ នៃសាធារណៈសង្គមនិយមវៀតណាម ។

48 មាត្រា ១៤៦៦ នៃក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម នៃព្រះរាជាណាចក្រថៃ ។

49 មាត្រា ៩៧០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ។

50 មាត្រា ៩៧០ នៃក្រមរដ្ឋប្បវេណី ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រព័ន្ធនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានកំណត់ជាទូទៅ មិនថានៅក្នុងករណីព្រះរាជាណាចក្រថៃ ករណីព្រះរាជាណាចក្រជប៉ុន និងបណ្តាលប្រទេសមួយចំនួននៅអឺរ៉ុប [51] ប៉ុន្តែក្នុងករណីសាធារណៈរដ្ឋសង្គមនិយមវៀតណាម មានលក្ខណៈដូចគ្នាទៅសាធារណៈរដ្ឋបារាំងដែរ គឺត្រូវបង្គាប់ឲ្យធ្វើជាលិខិតយថាភូត ដោយប្រព្រឹត្តទៅនៅចំពោះមុខសារការី ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃកិច្ចសន្យានោះ ប៉ុន្តែសង្កេតឃើញថាមិនមានការលើកឡើងអំពីការចុះបញ្ជីនោះទេ។ [52] ក្នុងករណីច្បាប់នៃព្រះរាជាណាចក្រថៃវិញ បានបង្ហាញពីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅពេលទៅចុះសំបុត្រអាពាហ៍ពិពាហ៍ក្នុងពេលតែមួយតែម្តង ។[53] ឯព្រះរាជាណាចក្រកម្ពុជាវិញ ការចុះបញ្ជីគឺអាចធ្វើនៅមុនពេល ឬ ក្រោយអាពាហ៍ពិពាហ៍បាន ព្រោះក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ បានអនុញ្ញាតឱ្យធ្វើបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទាំងមុនពេល ឬក្រោយពេលអាពាហ៍ពិពាហ៍បាន ដូច្នេះការចុះបញ្ជីត្រូវតម្រូវឱ្យធ្វើទៅតាមពេលវេលាក្រោយបញ្ចប់ការព្រមព្រៀង និង បានតាក់តែងកិច្ចសន្យារួចរាល់ ព្រមទាំងភាគីត្រូវចុះហត្ថលេខា និង ផ្តិតស្នាមម្រាម ដើម្បីទទួលស្គាល់លើការព្រមព្រៀង ។ ម្យ៉ាងទៀត ករណីកម្ពុជាអាចធ្វើការពិចារណាបាន ប្រសិនបើកិច្ចសន្យានោះបានបង្កើតមុនពេលដែលក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចូលជាធរមាន យ៉ាងណាក្តីបញ្ហានេះ មិនមែនជាភាពស្មុគស្មាញឡើយ ព្រោះតាមគោលការណ៍ នៃបទបប្បញ្ញតិច្បាប់ស្តីពី "ការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១" បានដើរតួនាទីក្នុងការសង្គ្រោះកិច្ចសន្យាប្រភេទនេះបាន គឺមានវិសាលភាពក្នុងការអនុវត្តគោលការណ៍សមធម៌ ចំពោះបញ្ហាដែលកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្ត ក្នុងករណីពុំមានបទដ្ឋានគតិយុត្ត ឬ បញ្ញតិទំនៀមទម្លាប់ ដែលកំណត់អំពីបញ្ហានេះ ឬ ក្នុងករណីមិនដឹងច្បាស់ថាមានបញ្ញតិទំនៀមទម្លាប់ ។[54]

### **២.១.២.ស្ថាប័នចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ**

សមត្ថកិច្ចនៃការចុះបញ្ជីក្នុងករណីព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានតម្រូវទៅលើនាយកដ្ឋានកិច្ចការចុះបញ្ជី និងតម្កល់ នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌ ។[55] ចំពោះការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មាននូវបញ្ហាគតិយុត្តមួយបានកើតឡើង ដែលតម្រូវឱ្យត្រូវធ្វើការពិចារណាអំពី វិវាទនៃការចុះបញ្ជីចំពោះការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និង ជនបរទេស ដែលមានទីលំនៅ ឬ ទីកន្លែងទ្រព្យ

---

[51] តំណភ្ជាប់ ៖ https://thecolumnofcurae.wordpress.com/2020/05/20/different-models-of-matrimonial-property-followed-across-the-world/ . (ចូលមើលថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០២២) ។

[52] មាត្រា ៤៧ នៃច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ របស់សាធារណៈរដ្ឋសង្គមនិយមវៀតណាម និង មាត្រា ១៣៩៤ នៃក្រមរដ្ឋប្បវេណីបារាំង ។

[53] មាត្រា ១៤៦៦ នៃក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម របស់ព្រះរាជាណាចក្រថៃ ។

[54] មាត្រា ៥ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ ។

[55] មាត្រា ២៦ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១, មាត្រា ២៨ នៃអនុក្រឹត្យស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ និង ប្រការ ៤ នៃប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ។

សម្បត្តិដែលនឹងក្លាយជាកម្មវត្ថុនៃកិច្ចសន្យា នៅពេលធ្វើការចុះបញ្ជីនោះវិវាទអំពីទីកន្លែងនៃទ្រព្យសម្បត្តិដែលជាអចលវត្ថុនឹងកើតមានឡើង ។

នៅក្នុងបទប្បញ្ញត្តិនៃរបស់ព្រះរាជាណាចក្រកម្ពុជា ពុំទាន់សង្កេតឃើញអំពីបញ្ហានេះ ត្រូវបានដោះស្រាយនៅឡើយទេ អាចបណ្ដាលមកពីនៅកម្ពុជា ពុំទាន់មានការជួបប្រទះនឹងបញ្ហានេះក៏អាចថា ។ ប៉ុន្តែកម្ពុជាគួរតែត្រៀមខ្លួនជាស្រេចក្នុងការរៀបចំបញ្ហានេះ ដើម្បីកុំឱ្យមានវិវាទនៅពេលក្រោយ ព្រោះបើសហព័ទ្ធ មិនបានឃើញមានច្បាប់ ឬ ក៏ដំណោះស្រាយអំពីការចុះបញ្ជីទេ សហព័ទ្ធនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក៏អាចមិនចង់ជ្រើសរើសប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមរយៈកិច្ចសន្យា ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដែរ ។ ត្បិតនៅពេលមានកិច្ចសន្យា ហើយកម្មវត្ថុ គឺនៅលើទឹកដីបរទេស នោះកិច្ចសន្យានេះ អាចមិនមានអានុភាពទេលើទឹកដីបរទេសនោះទេ ។[56]

### ២.២.អំពីការកែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ អាចធ្វើការកែប្រែ ឬ ផ្លាស់ប្ដូរបានតាមការព្រមព្រៀងរបស់ភាគីជាប្ដីប្រពន្ធ ប៉ុន្តែត្រូវធានាថាការផ្លាស់ប្ដូរនោះនឹងមិននាំឱ្យមានផលប៉ះពាល់ ឬ បំពារបំពានទៅលើផលប្រយោជន៍របស់តតិយជនដែលមានភាពសុចរិត ។ ដូច្នេះទើបការផ្លាស់ប្ដូរ ឬ កែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវតម្រូវឱ្យមានការសម្រេចពីតុលាការជាមុនសិន[57] ។

ហេតុដែលនាំឱ្យមានការអនុញ្ញាតឱ្យធ្វើផ្លាស់ប្ដូរ ឬ កែប្រែកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺដើម្បីជួយសម្រួលដល់ភាគីក្នុងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនឱ្យកាន់តែងាយស្រួល និង មានប្រសិទ្ធិភាពបន្ថែមទៀត ព្រោះនៅពេលខ្លះ ទាល់ភាគីបានរួមរស់នៅជាមួយគ្នា ទើបដឹងថាការប្រើប្រាស់សម្បត្តិនឹងមានលក្ខណៈបែបណា ដូច្នេះការបង្កើតមានការកែប្រែទៅលើទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺមានសារៈសំខាន់ឱ្យភាគីអាចធ្វើការគ្រប់គ្រងរបស់ខ្លួនតាមការប្រាថ្នា ។ ចំពោះការឆ្លងកាត់ការសម្រេចក៏ជាការតម្រូវដើម្បីឱ្យតុលាការអាច ត្រួតពិនិត្យទៅលើទំនាក់ទំនងគតិយុត្តរបស់សហព័ទ្ធ ជាមួយនឹងគ្នាតតិយជន ជៀសវាងនឹងមានការលំបាកនៅពេលក្រោយ ព្រោះក្រោយចេញសេចក្ដីសម្រេច នឹងមានការអនុញ្ញាតឱ្យធ្វើការប្ដឹងទៅលើសេចក្ដីសម្រេចនោះ ប្រសិនបើតតិយជនត្រូវបានបំពានសិទ្ធិរបស់ខ្លួនតាមរយៈការផ្លាស់ប្ដូរ ឬ ការកែប្រែលើខ្លឹមសារនៃកិច្ចសន្យា ម៉្យាងទៀតសេចក្ដីសម្រេចរបស់តុលាការគឺ ត្រូវបានធ្វើឡើងជាសាធារណៈ ហេតុនេះធៀបបានថា ការកែប្រែ ឬ ផ្លាស់ប្ដូរខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធរបស់សហព័ទ្ធត្រូវបានធ្វើឡើងជាសាធារណៈ ។

[56] សូមមើលសៀវភៅមេរៀនស្ដីពី នីតិអន្តរជាតិឯកជន របស់លោកស្រីសាស្ត្រាចារ្យ ស្រី វណ្ណធី គន្លឹះទី១ ជំពូកទី ១ ផ្នែកទី ២ កថាខណ្ឌទី ២ ទំព័រ ៤៤ ឆ្នាំ ២០១១ ។

[57] មាត្រា ៣០ កថាខណ្ឌទី ១ នៃច្បាប់ស្ដីពី ការអនុវត្តក្រមរដ្ឋប្បវេណី និង ប្រការ ២០ នៃប្រកាសរបស់ក្រសួងយុត្តិធម៌ស្ដីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ។

### ២.៣.នីតិវិធីក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ដើម្បីអាចចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិ ឬ អ្នកតំណាងដែលនឹងមកធ្វើការចុះបញ្ជីត្រូវសរសេរពាក្យសុំចុះបញ្ជី ឱ្យបានត្រឹមត្រូវតាមទម្រង់នៃពាក្យសុំដែលបានកំណត់នៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ស្ដីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ឆ្នាំ ២០១៣ ព្រមទាំងភ្ជាប់នូវឯកសារដែលជាការតម្រូវរបស់ពាក្យសុំនីមួយៗ ។

#### ២.៣.១.ទម្រង់នៃពាក្យសុំចុះបញ្ជី

ពាក្យសុំចុះបញ្ជីរបស់ភាគី ត្រូវតែពាក្យសុំដែលបានគោរពតាមការបញ្ញត្តិនៅក្នុងប្រកាសស្ដីពី "នីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ" ឆ្នាំ ២០១៣ ។ ពាក្យសុំចុះបញ្ជី ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ហើយភាគីត្រូវធ្វើឡើងរួមគ្នា តែត្រូវលើកលែងចំពោះពាក្យសុំមួយចំនួន ដែលអាចអនុញ្ញាតិឱ្យ ភាគីម្ខាងបាន ឬ ឱ្យអ្នកតំណាងធ្វើពាក្យសុំឲ្យក៏បាន ។ នៅក្នុងប្រការ ១៦ នៃប្រកាសនេះ បានបង្ហាញពីទិដ្ឋភាពរួមនៃពាក្យសុំបញ្ជី ដែលតម្រូវឲ្យពាក្យសុំ ត្រូវមានសរសេរអំពី បាវចនាជាតិនៃព្រះរាជណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី កម្មវត្ថុនៃការចុះបញ្ជី អត្តសញ្ញាណភាគី(ឈ្មោះភាគី អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ) ។ សម្រាប់ភាគីដែលមានអ្នកតំណាងចុះបញ្ជី តម្រូវឱ្យបញ្ជាក់អំពីអត្តសញ្ញាណនៃអ្នកតំណាងឲ្យបានច្បាស់លាស់ដូចភាគីដែរ រួមមានទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង ហើយត្រូវចុះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំព្រមទាំងត្រូវគោរពចូលមករដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ ។[58] ក្រៅពីនេះ ភាគី ឬ អ្នកតំណាងត្រូវសរសេរគោរពតាមលក្ខខណ្ឌផ្សេងទៀត ដែលពាក្យសុំចុះបញ្ជីនីមួយៗបានកំណត់ ។

នៅពេលដាក់ពាក្យសុំ ភាគីត្រូវភ្ជាប់ជាមួយនឹងឯកសារមួយចំនួនទៀតដូចជា កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ សំបុត្រអាពាហ៍ពិពាហ៍ វិញ្ញាបនបត្រអំពីអចលវត្ថុដែលជាកម្មវត្ថុកិច្ចសន្យា លិខិតប្រគល់សិទ្ធិតំណាង អត្តសញ្ញាណប័ណ្ណភាគី ឬ លិខិតឆ្លងដែន ។ ចំពោះឯកសារដែលភ្ជាប់មកជាមួយភាគីអាចដាក់ពាក្យសុំទាមទារឱ្យប្រគល់ឯកសារមួយចំនួនត្រឡប់វិញដូចជា កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ សំបុត្រអាពាហ៍ពិពាហ៍ អត្តសញ្ញាណប័ណ្ណភាគី ឬ លិខិតឆ្លងដែន វិញ្ញាបនបត្រអំពីអចលវត្ថុដែលជាកម្មវត្ថុកិច្ចសន្យា ។ល។ ប៉ុន្តែត្រូវយកសេចក្ដីចម្លងនៃឯកសារ ព្រមសេចក្ដីបញ្ជាក់ទៅដាក់នៅក្នុងក្រូណូចុះបញ្ជីវិញ ។[59]

[58] ប្រការ ១៦ នៃប្រកាសស្ដីពី "នីតិវីធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ឆ្នាំ ២០១៣ ។

[59] ប្រការ ១៧ និង ប្រការ ១៨ នៃប្រកាសស្ដីពី "នីតិវីធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ឆ្នាំ ២០១៣ ។

**២.៣.២.ប្រភេទនៃពាក្យសុំចុះបញ្ជី**

នៅក្នុងករណីកម្ពុជាមានពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដូចជា ពាក្យសុំចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំកែតម្រូវ ពាក្យសុំកែប្រែ ឬ ផ្លាស់ប្តូរខ្លឹមសារកិច្ចសន្យា ពាក្យសុំលុបចោលការចុះបញ្ជី និង ពាក្យសុំពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី ។

**ក.ពាក្យសុំចុះបញ្ជីលើកិច្ចសន្យា**

ភាគីជាប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា ឬ អ្នកតំណាង[60] ត្រូវទៅយកពាក្យសុំពីនាយកដ្ឋានចុះបញ្ជី និង តម្កល់ នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី រួចត្រូវបំពេញពាក្យសុំឱ្យបានត្រឹមត្រូវតាមការកំណត់ក្នុងទម្រង់ពាក្យសុំចុះបញ្ជី[61] ឬ គំរូពាក្យសុំ ដែលមាននៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យប្តីប្រពន្ធ" ។

- **ខ្លឹមសារនៃពាក្យសុំ**

ដោយគោរពតាមទម្រង់ពាក្យសុំនៃប្រកាសរបស់ក្រសួងយុត្តិធម៌ អំពី "នីតិវិធីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ " ឆ្នាំ ២០១៣ រួចមក ភាគីត្រូវសរសេរបន្ថែមនូវខ្លឹមសារមួយចំនួនដូចជា[62] ៖

– អត្តសញ្ញាណនៃភាគី (នាម-គោត្តនាម និងអាសយដ្ឋានគូភាគីកិច្ចសន្យា)
– គោលបំណងនៃការចុះបញ្ជី
– មូលហេតុ និង កាលបរិច្ឆេទ (ថ្ងៃខែឆ្នាំនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)
– ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
– កាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ (ករណីភាគីបានរៀបអាពាហ៍ពិពាហ៍)

- **ឯកសារភ្ជាប់នៃពាក្យសុំ**

បន្ទាប់ពីបំពេញបែបបទពាក្យរួចរាល់ហើយភាគី ត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា ៖

– កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
– សំបុត្រអាពាហ៍ពិពាហ៍ (ករណីដែលភាគីបានរៀបអាពាហ៍ពិពាហ៍)
– វិញ្ញាបនប័ត្របញ្ជាក់ពត៌មាននឹងទាក់នឹងដីធ្លី (ករណីដែលភាគីបានដាក់កម្មវត្ថុ ជាអចលវត្ថុ ឬ សិទ្ធិណាមួយដូចជា សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ជាដើម )
– លិខិតប្រគល់សិទ្ធិតំណាង (ករណីមាន)

[60] ចំណុចនេះគួរមានការពិចារណាទៅលើអ្នកតំណាង ត្បិតអាចមានក្រុមហ៊ុន ឬ ភ្នាក់ងារឯកជនដែលនឹងទទួលសេវាកម្មចុះបញ្ជីដល់ភាគី ។

[61] ប្រការ ១៦ "ទម្រង់នៃពាក្យសុំចុះបញ្ជី" នៃប្រកាសស្តីពីនីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរបស់ក្រសួងយុត្តិធម៌ ។

[62] ប្រការ ១៩ នៃប្រកាសរបស់ក្រសួងយុត្តិធម៌ស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ២០១៤ ។

– អត្តសញ្ញាណប័ណ្ណរបស់ភាគី ឬ លិខិតឆ្លងដែន[63]

ជាករណីពិសេស របស់បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា បើបង្កើតកិច្ចសន្យា និង បានធ្វើការចុះបញ្ជីរួចរាល់ហើយនោះ ក្រោយមកបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាហើយនោះ ភាគីត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍[64] ដើម្បីបញ្ជាក់អំពីអានុភាពនៃកិច្ចសន្យានោះ ។

**ខ.ពាក្យសុំកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

ប្រសិនបើភាគីបានធ្វើការចុះបញ្ជីកិច្ចសន្យារួចរាល់ហើយ តែបានពិនិត្យពិនិត្យឃើញអំពីកំហុសទៅលើការចុះបញ្ជីដូចជា ខុសលើខ្លឹមសារនៃកិច្ចសន្យាជាដើម ខុសកាលបរិច្ឆេទកំណើត ខុសអាសយដ្ឋាន ខុសអក្ខរាវិរុទ្ធលើនាម-គោត្តនាម ឬ ខកខានមិនបានចុះបញ្ជីទៅលើទ្រព្យសម្បត្តិណាមួយរបស់ខ្លួនដែលបានព្រមព្រៀងភាគីអាចធ្វើដាក់ពាក្យសុំកែតម្រូវបាន ។

- **ខ្លឹមសារនៃពាក្យសុំ**

អនុលោមតាមទម្រង់ពាក្យសុំចុះបញ្ជីដែលមានក្នុងប្រការ ១៦ នៃប្រកាសរបស់ក្រសួងយុត្តិធម៌ អំពី "នីតិវិធីការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិ " ឆ្នាំ ២០១៣ ដើម្បីអាចសរសេរពាក្យសុំកែតម្រូវលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ[65] ភាគីតម្រូវឲ្យត្រូវបន្ថែមនូវ៖

– គោលបំណង

– មូលហេតុ និង កាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែរួចរាល់)

– ចំណុចដែលត្រូវកែតម្រូវ ( អត្តសញ្ញាណនៃភាគី កាលបរិច្ឆេទអាពាហ៍ពិពាហ៍ ឬ ខ្លឹមសារនៃកិច្ចសន្យាជាដើម)

- **ឯកសារភ្ជាប់នៃពាក្យសុំ**

ក្រោយបំពេញបែបបទរួចរាល់ត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនទៀតរួមមាន៖

– កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

– សំបុត្រអាពាហ៍ពិពាហ៍

– លិខិតបញ្ជាក់អាសយដ្ឋាន

– វិញ្ញាបនបត្របញ្ជាក់អំពីពត៌មានដែលបានក្លាយកម្មវត្ថុកិច្ចសន្យា

– លិខិតប្រគល់សិទ្ធិតំណាង (ករណីមាន)

---

[63] ភាគីម្ខាងអាចជា ជនបរទេសហើយគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហេតុនេះអាចអនុញ្ញាតិឲ្យភាគីជាជនបរទេសអាចប្រើប្រាស់លិខិតឆ្លងដែន ។

[64] ប្រការ ២៨ នៃប្រកាសស្ដីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ឆ្នាំ ២០១៣ របស់ក្រសួងយុត្តិធម៌ ។

[65] ប្រការ ២១ នៃប្រកាសស្ដីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" ឆ្នាំ ២០១៣ របស់ក្រសួងយុត្តិធម៌ ។

– អត្តសញ្ញាណប័ណ្ណរបស់ភាគី ឬ លិខិតឆ្លងដែន

**គ.ពាក្យសុំចុះបញ្ជីអំពីផ្លាស់ប្តូរខ្លឹមសារកិច្ចសន្យា**

នៅក្នុងករណីដែលភាគីប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវបានរៀបអាពាហ៍ពិពាហ៍ បានព្រមព្រៀងគ្នាអំពីការផ្លាស់ប្តូរខ្លឹមសារកិច្ចសន្យាហើយនោះ ភាគីត្រូវបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី និងត្រូវដាក់ពាក្យស្នើសុំទៅនាយកដ្ឋានចុះបញ្ជី និង តម្កល់ ដើម្បីធ្វើការផ្លាស់ប្តូរកិច្ចសន្យា ។

- **ខ្លឹមសារនៃពាក្យសុំ**

ភាគីត្រូវសរសេរតាមទម្រង់ពាក្យសុំចុះបញ្ជី ហើយភាគីតម្រូវឲ្យត្រូវបន្ថែមនូវចំណុចដូចជា[66] ៖

– អំពីអត្តសញ្ញាណនៃភាគីកិច្ចសន្យា

– គោលបំណងនៃការចុះបញ្ជី

– មូលហេតុដែលធ្វើការចុះបញ្ជី និង កាលបរិច្ឆេទនៃការផ្លាស់ប្តូរ

– ចំណុចដែលភាគីបានកែប្រែ និង ផ្លាស់ប្តូរ (ខ្លឹមសារថ្មីនៃការព្រមព្រៀង)

- **ឯកសារភ្ជាប់នៃពាក្យសុំ**

បើបានបំពេញបែបបទរួចរាល់ហើយ ត្រូវភ្ជាប់ជាមួយឯកសារមួយចំនួនដូចជា ៖

– កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី

– សាលក្រម ឬ ដីកាសម្រេចផ្លាស់ប្តូរ

– លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន (ករណីដែលភាគីបានផ្លាស់ប្តូរអាសយដ្ឋាន)

– វិញ្ញាបនបត្របញ្ជាក់អំពីពត៌មានដែលបានក្លាយកម្មវត្ថុកិច្ចសន្យា

– លិខិតប្រគល់សិទ្ធិតំណាង (ករណីមាន)

– អត្តសញ្ញាណប័ណ្ណរបស់ភាគី ឬ លិខិតឆ្លងដែន

**ឃ.ការទទួល ការពិនិត្យសុំចុះបញ្ជី និងការបង់ពន្ធពាក្យសុំ**

**ឃ.១.ការទទួល និង ការពិនិត្យចុះបញ្ជី**

នៅពេលដែលភាគីបានបំពេញបែបបទរួចរាល់ ត្រូវដាក់ជូនទៅមន្ត្រីចុះបញ្ជី នឹងត្រូវពិនិត្យទៅលើពាក្យសុំ និង ឯកសារភ្ជាប់ បន្ទាប់មកមន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះ នូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ព្រមទាំងហត្ថលេខាបំព្រួញ និងមន្ត្រីចុះបញ្ជីនោះ ។ បើរកឃើញមានវិមតិសង្ស័យនោះ មន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះ ហើយ

[66] ប្រការ ២០ នៃប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ របស់ក្រសួងយុត្តិធម៌ ។

មន្ត្រីចុះបញ្ជី អាចចេញលិខិតបង្គាប់កែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹងទៅអ្នកពាក្យសុំ ក្នុងករណីដែលបានពិនិត្យឃើញថា ៖

- ពាក្យសុំធ្វើឡើងមិនត្រឹមត្រូវ ឬ មិនអនុលោមតាមលក្ខខណ្ឌនៃប្រកាសនេះ ឬ ច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធ
- ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រកាស
- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី
- ពុំបានបង់សោហ៊ុយ

បើហួសអំឡុងពេលដែលបានកំណត់ ហើយភាគី ឬ អ្នកតំណាងមិនកែតម្រូវតាមការណែនាំទេ មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតលើកចោលពាក្យសុំចុះបញ្ជីនោះ ហើយជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ។ នៅពេលដែលបានលើកចោល ឬ ដកពាក្យសុំ មន្ត្រីចុះបញ្ជី មានករណីយកិច្ចប្រគល់ត្រឡប់នូវឯកសារភ្ជាប់ទៅអ្នកដាក់ពាក្យសុំវិញ បើភាគីបានស្នើសុំ តែក្នុងករណីខ្លះ ទោះបីជាភាគីមិនបានស្នើសុំ ក៏ត្រូវបង្វែត្រឡប់ទៅវិញ គឺនៅពេលភាគីបានដាក់ឯកសារភ្ជាប់ជាសំណុំឯកសារដើមដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ។ ភាគីនៃកិច្ចសន្យា ឬ អ្នកតំណាងមានសិទ្ធិអាចពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលនូវពាក្យសុំចុះបញ្ជីរបស់ខ្លួន ដោយដាក់ពាក្យសុំនេះទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នឹងត្រូវរង់ចាំសេចក្តីជូនដំណឹងអំពីពាក្យសុំនោះ ។

**ឃ.២.ការបង់ពន្ធលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

ភាគី ត្រូវបានតម្រូវឱ្យបង់ពន្ធលើដំណើរនៃការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយគោរពទៅតាមប្រកាសរបស់ប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពី "ការផ្តល់សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ ដែលមានកម្រងសេវាសាធារណៈលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដូចជា ៖

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | ៣០០.០០០ | ១៥ ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | ការចុះបញ្ជីផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តប្តីប្រពន្ធ | ១០០.០០០ | ១៥ ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣ | ការចុះបញ្ជីកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តប្តីប្រពន្ធ | ១០០.០០០ | ១៥ ថ្ងៃ | អចិន្ត្រៃយ៍ |
| ៤ | ការចុះបញ្ជីអំពីការលុបចោលកិច្ចសន្យាទ្រព្យសម្បត្តប្តីប្រពន្ធ | ១០០.០០០ | ១៥ ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥ | ការចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ១០០.០០០ | ១៥ ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦ | ការចេញលិខិតបញ្ជាក់ | ១០០.០០០ | ៣ថ្ងៃ | ៦ ខែ[67] |

### ២.៣.៣.ការចេញលិខិតបញ្ជាក់

#### ក.ពាក្យដាក់ពាក្យសុំចេញលិខិតបញ្ជាក់

ក្រោយពីបានធ្វើការចុះបញ្ជីបានជាស្ថាពរ ភាគី ឬ បុគ្គលណាក៏ដោយ ក៏អាចដាក់ពាក្យស្នើសុំឱ្យនាយកដ្ឋានចុះបញ្ជី និងតម្កល់ចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានដែរ ហើយកត្តាដែលនាំឱ្យនីតិនិពន្ធ បានបញ្ជាក់អំពី ការអនុញ្ញាតិឱ្យបុគ្គលណាក៏ដោយមានសិទ្ធិក្នុងដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ ព្រោះការអនុវត្តបែបនេះនឹងនាំឲ្យតតិយជនអាចដឹងអំពីទ្រព្យសម្បត្តិរបស់ភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មុននឹងការផ្តើមទំនាក់ទំនងគតិយុត្តណាមួយជាមួយភាគី ។

- **ខ្លឹមសារនៃពាក្យសុំ**

ពាក្យសុំ ត្រូវបានតម្រូវឱ្យធ្វើឡើងជា លាយល័ក្ខណ៍អក្សរ និងត្រូវគោរពតាមទម្រង់នៃពាក្យចុះបញ្ជីដែររួមមាន បាវចនាជាតិនៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី អត្តសញ្ញាណភាគី(នាម-គោត្តនាម និងអាសយដ្ឋានភាគី) អត្តសញ្ញាណអ្នកតំណាង(ក្នុងករណីភាគីមានអ្នកតំណាង) ព្រមកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃនៃអ្នកដាក់ពាក្យសុំ ។ ត្រូវសរសេរនូវចំណុចមួយចំនួនដូចជា ៖

– គោលបំណងនៃពាក្យសុំ (អាចសរសេរថា "ស្នើសុំចេញលិខិតបញ្ជាក់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ"

[67] ដកស្រង់ទាំងស្រុងពីប្រកាសអន្តរក្រសួងដែលចេញដោយក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ ស្តីពី "ការផ្តល់សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ ។

- អត្តសញ្ញាណនៃអ្នកដាក់ពាក្យសុំ (អាចជាភាគី ឬ បុគ្គលដែលមានបំណងចង់ដឹងពីទំនាក់ទំនងទ្រព្យសម្បត្តិ)
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល (ករណីដែលអ្នកដាក់ពាក្យសុំជានីតិបុគ្គល)
- ចំណុចដែលត្រូវធ្វើការបញ្ជាក់[68]
- ចំនួននៃលិខិតបញ្ជាក់[69]
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ

**ខ.ការចេញលិខិតបញ្ជាក់**

ក្រោយពីបានទទួលនូវពាក្យសុំរបស់អ្នកដាក់សុំ និងធ្វើការពិនិត្យថាបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យសុំតាមរយៈប្រការ ១៦ និង ប្រការ៤៨ នៃប្រកាសស្តីពី "នីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ រួចរាល់ហើយ ក្រសួងយុត្តិធម៌ ដែលមាននាយកដ្ឋានចុះបញ្ជី និងតម្កល់ជាអ្នកទទួលបន្ទុកក្នុងការចេញលិខិតបញ្ជាក់ នឹងធ្វើការចេញលិខិតបញ្ជាក់អំពីកិច្ចសន្យា ឬ កម្មវត្ថុ ឬ ខ្លឹមសារណាមួយដែលភាគីនៃកិច្ចសន្យាព្រមព្រៀង ដោយគ្មានការយឺតយូរមិនឱ្យលើសពី ៣ ថ្ងៃ ។[70]

[68] ឧទាហរណ៍ ៖ អ្នកទិញដីមួយកន្លែងរបស់ គុលា និង ប្រពន្ធ ចង់ដឹងថាដីនោះជាទ្រព្យរួម ឬ ទ្រព្យដោយឡែក ហេតុនេះអាចដាក់ពាក្យសុំចេញលិខិតបញ្ជាក់ ។

[69] ចំណុចនេះ បុគ្គលដែលចង់ដឹងអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចសុំតាមតម្រូវដែលខ្លួនចង់បាន ។

[70] ប្រការ ៤៩ នៃប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឆ្នាំ ២០១៣ របស់ក្រសួងយុត្តិធម៌ ។

# ជំពូកទី២

# អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

បើភាគីបានបំពេញនូវលក្ខខណ្ឌគ្រឹះ លក្ខខណ្ឌទម្រង់ ព្រមទាំងលក្ខខណ្ឌតតាំងទៅនឹងតតិយជនបាន ត្រឹមត្រូវចប់សព្វគ្រប់នោះ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ព្រមអានុភាពនៃការចុះបញ្ជីនឹងត្រូវបាន កើតមានឡើង ។ អានុភាពកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នឹងមានឥទ្ធិពលលើទំនាក់ទំនងគតិយុត្តរបស់ភាគីនៃ កិច្ចសន្យា បង្កើតនូវសិទ្ធិ និង ករណីយកិច្ចរបស់ភាគី ក្នុងនាមប្ដីប្រពន្ធ ហើយអានុភាពនៃការចុះបញ្ជីលើកិច្ច សន្យានឹងនាំឱ្យមានអានុភាពទៅតតាំងនឹងតតិយជន ។ ប៉ុន្តែអានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែល ត្រូវបានធ្វើឡើងដោយបុគ្គលដែលនឹងរៀបអាពាហ៍ពិពាហ៍ ឬ គូភាគីនៃកំជាប់ពាក្យ គឺមិនទាន់កើតមាននូវ អានុភាពនោះ លុះត្រាតែគូភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ បានចុះសំបុត្រអាពាហ៍ពិពាហ៍រួចរាល់សិន ទើបអានុភាពនៃកិច្ចសន្យាបានកើតឡើង ។

## ផ្នែកទី១ អានុភាពគតិយុត្តចំពោះភាគីជាប្ដីប្រពន្ធ

កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នឹងកើតមានអានុភាពរបស់ខ្លួននៅពេលដែលភាគីជាសហព័ទ្ធ បានចុះ ហត្ថលេខា ឬ បានផ្ដិតស្នាមម្រាមដៃរបស់ខ្លួន យល់ព្រមលើទទួលស្គាល់លើកិច្ចសន្យាដែលបានព្រមព្រៀង ។ អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នឹងមានអានុភាពចំពោះភាគីជាសហព័ទ្ធ ដោយបង្កើតឱ្យមាននូវ សិទ្ធិ និង កាតព្វកិច្ចចំពោះភាគី ព្រមទាំងអានុភាពនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺអាចឱ្យសហ ព័ទ្ធធ្វើការតតាំងទៅតតិយជន ក្នុងករណីមានការបំពានកើតឡើង ។

### ១.សិទ្ធិ និង ករណីយកិច្ចរបស់ភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ពេលភាគីបានសម្រេចយកទ្រព្យដោយឡែករបស់ខ្លួន ទាំងសងខាងដាក់ជាកម្មវត្ថុនៃទ្រព្យសម្បត្តិរួម នោះភាគីម្ខាងៗ នៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធមានសិទ្ធិ និង ករណីយកិច្ច ក្នុងនាមជាកម្មសិទ្ធិករនៃទ្រព្យរួម នោះ ។

#### ១.១.សិទ្ធិប្រើប្រាស់ និង អាស្រ័យនៅ

អានុភាពដែលកើតអំពីការព្រមព្រៀងទៅលើទ្រព្យសម្បត្តិរួមនាំឱ្យ ភាគីអាចប្រើប្រាស់ និង អាស្រ័យនៅ លើទ្រព្យសម្បត្តិរួម ដោយស្មើភាពគ្នា និង សហការ ត្បិតថាបើក្លាយជាទ្រព្យសម្បត្តិរួមហើយ ភាគីទាំងសងខាង គឺជាម្ចាស់កម្មសិទ្ធិលើទ្រព្យនោះ ហេតុនេះតាមយោងតាមគោលការណ៍កម្មសិទ្ធិ កម្មសិទ្ធិករមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផល ព្រមទាំងការអាស្រ័យនៅ និងគ្រប់គ្រងទៅលើទ្រព្យសម្បត្តិនោះដោយសុចរិត[71] ។ ប៉ុន្តែនៅ

[71] សូមមើលមាត្រា ៩៧៤ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

ក្នុងស្ថានភាពខ្លះ ភាគីអាចធ្វើការអាស្រ័យនៅនឹងទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងទៀតដែលជាសហព័ទ្ធរបស់ខ្លួនបានផងដែរ ទៅតាមខ្លឹមសារនៃការព្រមព្រៀងក្នុងកិច្ចសន្យា ។ ការអនុញ្ញាតិឱ្យមាននូវខ្លឹមសារបែបក្នុងកិច្ចសន្យាបាន គឺដើម្បីសម្រួល ក៏ដូចជាធានាដល់សិទ្ធិអាស្រ័យនៅរបស់ប្តីប្រពន្ធ ព្រោះប្រសិនបើមិនធ្វើដូច្នេះទេលក្ខខណ្ឌអាពាហ៍ពិពាហ៍នឹងត្រូវបានបំពានយ៉ាងធ្ងន់ធ្ងរ ។[72] អាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធ តម្រូវឱ្យភាគីរស់នៅជុំគ្នាក្រោមដំបូលផ្ទះតែមួយ ប៉ុន្តែបើប្តីរស់នៅផ្សេង ហើយប្រពន្ធរស់នៅផ្សេង ដោយសារភាគីម្ខាងមិនព្រមឱ្យមិនភាគីម្ខាងទៀតរស់នៅក្នុងផ្ទះជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ក្រោមហេតុផលណាមួយ នោះនឹងនាំជីវិតអាពាហ៍ពិពាហ៍របស់ពួកគេជួបប្រទះទៅនឹងរស់នៅបែកគ្នា ។

**១.២.សិទ្ធិចាត់ចែងទ្រព្យសម្បត្តិរួម**

ខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បានផ្តល់ឱ្យភាគីនូវអានុភាពជាកម្មសិទ្ធិករ លើទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដែលបានយកទ្រព្យសម្បត្តិដោយឡែកនោះ មកធ្វើជាទ្រព្យសម្បត្តិរួមរវាងប្តីប្រពន្ធ [73] ។ ក្នុងន័យនេះចង់បង្ហាញថាភាគីម្ខាងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បានក្លាយជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀត ។ ហេតុនេះប្រសិនបើ ភាគីម្ខាង បានក្លាយកម្មសិទ្ធិករនៃទ្រព្យសម្បត្តិរបស់ភាគីម្ខាងទៀត ភាគីនោះមានសិទ្ធិក្នុងការចាត់ចែងទៅលើទ្រព្យសម្បត្តិរួមនោះ ប៉ុន្តែការចាត់ចែងនោះត្រូវមានការឯកភាពគ្នាពីភាគីទាំងសងខាង។ [74] ប៉ុន្តែស្ថានភាពខ្លះមិនបាច់មានការយល់ព្រមពីភាគីម្ខាងទៀតទេដូចជា ស្ថានភាពដែលមិនជៀសវាងបាន ឬ ស្ថានភាពដែលមិនអាចទទួលការឯកភាពពីភាគីម្ខាងទៀត (បាត់ខ្លួន ឬ ជម្ងឺធ្ងន់ធ្ងរ ជាដើម...) ប៉ុន្តែដើម្បីរក្សានូវជីវភាពគ្រួសារ ភាគីអាចធ្វើការចាត់ចែងបាន[75] ព្រោះថា នៅស្ថានភាពដែលភាគីម្ខាងមិនអាចរ៉ាប់រងនូវជីវភាពគ្រួសារបាន នោះជីវិតគ្រួសារនឹងជួបប្រទះការលំបាក ហើយបើករណីភាគីម្ខាងជាសហព័ទ្ធមានបញ្ហាជម្ងឺដល់អាយុជីវិតនោះ បានជួបប្រទះនឹងបញ្ហាសេដ្ឋកិច្ច ដើម្បីអាចរក្សាជីវិតរបស់សហព័ទ្ធម្ខាងទៀតបាន ភាគីម្ខាងទៀតអាចចាត់ចែងតាមការគួរបាន ។ លើសពីនេះទៅទៀត តាមក្រមរដ្ឋប្បវេណីត្រូវបានតម្រូវឱ្យការចាត់ចែងនេះត្រូវដាក់ពាក្យសុំពី តុលាការដើម្បីចេញដីកាសម្រេចអនុញ្ញាតឱ្យធ្វើការចាត់ចែងបាន ឬ មិនបាន[76] ។ តែការអនុវត្តបែបនេះ ប្រសិនបើដូចករណីខាងលើ ភាគីអាចនឹងមានបញ្ហាជាក់

[72] សេចក្តីកំណត់ក្រមរដ្ឋប្បវេណីត្រង់មាត្រា ៩៧៧ នៃក្រមរដ្ឋប្បវេណីកម្ពុជា ។

[73] មាត្រា ៩៧៣ "ទ្រព្យសម្បត្តិរួម" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។ ក្នុងន័យនេះ សូមសង្កេតថា ទ្រព្យរួម គឺជាទ្រព្យដែលប្តីប្រពន្ធ ទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ។ ករណីនេះតម្រូវឲ្យពិចារណាទៅលើប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធវិញ ប្រសិនបើភាគី បានបង្ហាញឆន្ទៈព្រមព្រៀងក្នុងការដាក់ទ្រព្យសម្បត្តិដោយឡែករបស់ខ្លួនជាទ្រព្យសម្បត្តិរួមនោះ ក៏អាចត្រូវសន្មតថា ទ្រព្យសម្បត្តិរួមផងដែរ ត្បិតភាគីម្ខាងទៀតបានផ្តល់សិទ្ធិឲ្យ ។

[74] មាត្រា ៩៦៧ កថាខណ្ឌទី១ "ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ" ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

[75] មាត្រា ៩៦៧ កថាខណ្ឌទី២ "ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ" ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ។

[76] មាត្រា ៩៦៧ កថាខណ្ឌទី២ "ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ" នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

ជាមិនខាន ហេតុនេះគួរធ្វើការចាត់ចែងរួចរាល់ចាំភាគី ដាក់ពាក្យសុំតាមក្រោយ ។ ការទាមទារឱ្យដាក់ពាក្យសុំចំពោះតុលាការបែបនេះ ក៏ជាការការពារចំពោះភាគីម្ខាងទៀតផងដែរ គឺធានាការពារសិទ្ធិជាកម្មសិទ្ធិកររបស់ភាគី ហើយមានសេចក្ដីបារម្ភថា ភាគីម្ខាងទៀតប្រើប្រាស់បញ្ហានេះ ជាប្រយោជន៍តែម្ខាង ព្រោះនៅពេលដាក់ពាក្យសុំបែបនេះ តុលាការនឹងការត្រួតពិនិត្យ តែបើភាគីមិនដាក់ពាក្យសុំទេនោះ តុលាការក៏មិនបានទទួលអំពីដំណឹងនោះដែរ ។

### ១.៣.ការទទួលខុសត្រូវដោយសាមគ្គីភាព

ភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ មានកាតព្វកិច្ចសាមគ្គីភាពក្នុងការអនុវត្តកាតព្វកិច្ចដែលជាបំណុលគ្រួសារ [77] ។ ការទទួលខុសត្រូវរួម គឺជាការបង្ហាញអំពីទំនួលខុសត្រូវរបស់ប្ដីប្រពន្ធ ក្នុងជីវិតអាពាហ៍ពិពាហ៍ ត្បិតនៅពេលរស់ជាមួយគ្នា ភាគីតែងតែត្រូវចំណាយហរិញ្ញវត្ថុក្នុងជីវភាពរួមប្ដីប្រពន្ធ ពិសេសទៅលើកូន ដែលត្រូវចំណាយសោហ៊ុយចិញ្ចឹមបីបាច់ថែរក្សា សោហ៊ុយអប់រំ ព្រមទាំងសោហ៊ុយលើការថែទាំសុខភាព និង ការព្យាបាល ។ មិនមែនមានតែប្ដីប្រពន្ធក្នុងប្រព័ន្ធទ្រព្យសម្បត្តិដោយកំណត់ច្បាប់ទេ ដែលត្រូវមានទំនួលខុសត្រូវ ប្ដីប្រពន្ធក្នុងប្រព័ន្ធកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក៏ត្រូវបានគោរពតាមកាតព្វកិច្ចនេះដែរ ព្រោះវាជួយទំនុកបម្រុង និង ធានារ៉ាប់រងដល់ជីវភាពគ្រួសារក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ត្បិតថាជីវិតរស់នៅសព្វថ្ងៃត្រូវចំណាយច្រើនសព្វមុខ ទាំងថ្លៃអាហារ ការស្នាក់នៅ និង រ៉ាប់រងនូវជីវភាពរួមផ្សេងទៀតនៃប្ដីប្រពន្ធ ។ ប៉ុន្តែគ្រាន់តែភាគីនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ បានបង្ហាញអំពីការទទួលខុសត្រូវនេះ ក្នុងកិច្ចសន្យា និងកំណត់ឱ្យបានច្បាស់លាស់ថា ភាគីម្ខាងៗ មានកាតព្វកិច្ចអ្វីខ្លះ ហើយរួចផុតពីកាតព្វកិច្ចអ្វីខ្លះ ។ ចំណុចនេះបង្ហាញថាភាគីអាចធ្វើការកំណត់ និង បែងចែកអំពីការទទួលខុសត្រូវរបស់ខ្លួនទៅតាមចំណែកដែលបានព្រមព្រៀងគ្នា ។[78]

## ២.ការតតាំងនឹងតតិយជនរបស់ភាគី

បើភាគីបានចុះបញ្ជីទៅលើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នឹងមានអានុភាពក្នុងការតតាំងទៅនឹងតតិយជន [79] ព្រោះពេលដែលភាគីចុះបញ្ជីទៅលើកិច្ចសន្យា នឹងបានត្រូវការទទួលស្គាល់អំពីស្ថាប័នមានសមត្ថកិច្ច ព្រមទាំងកំណត់បានយ៉ាងច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្ដីប្រពន្ធ លើសពីនេះទៅលើទៀតកិច្ចសន្យារបស់ភាគីនឹងមានសុវត្ថិភាព មិនអាចមានភាគីណាម្ខាងមកធ្វើកែប្រែលើកិច្ចសន្យានោះដោយមិនឲ្យភាគីម្ខាងទៀតបានដឹងនោះឡើយ ។ ហេតុនេះការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ បានផ្ដល់នូវសារៈប្រយោជន៍ដល់ភាគីយ៉ាងច្រើន ក៏ដូចជាបានការពារទៅលើតតិយជនផងដែរ ។ នៅពេលដែលមានតតិយ

---

[77] ឃ្លាផ្ដើមនៃមាត្រា ៩៧៥ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

[78] មាត្រា ៩៧៥ ចំណុចខ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

[79] មាត្រា ៩៧០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

ជនណាម្នាក់មកអះអាងអំពីសិទ្ធិរបស់ខ្លួននៅលើកម្មវត្ថុនៃកិច្ចសន្យា (ទ្រព្យសម្បត្តិរួម) របស់ភាគី ភាគីអាចធ្វើបង្ហាញអំពីការចុះបញ្ជីទៅលើកិច្ចសន្យារបស់ខ្លួន ដើម្បីការពារសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ ។

## ផ្នែកទី២ អានុភាពនៃកិច្ចសន្យាចំពោះតតិយជន

តតិយជន ជាជនទី៣ ក្នុងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែលមានទំនាក់ទំនងគតិយុត្តណាមួយផ្សេងជាមួយនឹងភាគីនៃកិច្ចសន្យានេះ ។ ប្រសិនបើគូភាគីជាសហព័ទ្ធ បានធ្វើការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិរួចរាល់ហើយ អានុភាពនៃការចុះបញ្ជីនេះ ក៏មានឥទ្ធិពលដល់តតិយជនផងដែរ មានន័យថា ប្រសិនបើមាន ភាគីណាម្ខាងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធមានភាពទុច្ចរិត យកកម្មវត្ថុដែលជាទ្រព្យរួមទៅប្រើប្រាស់ក្នុងន័យមិនត្រឹមត្រូវដូចជា ការដាក់បញ្ចាំ ការដាក់ជាប្រាតិភោគ ការលក់ ឬ ធ្វើជាការជួលអចិន្ត្រៃយ៍ ដោយមិនឱ្យភាគីម្ខាងទៀតបានដឹង នឹងនាំឱ្យកិច្ចសន្យាដែលភាគីម្ខាង និងតតិយជន បានបង្កើត គឺជាផលប៉ះពាល់ដល់ប្រយោជន៍របស់ភាគីម្ខាងទៀត នោះតតិយជននឹងមិនត្រូវបានការពារឡើយ ត្បិតថាតតិយជន គួរតែមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់ជាងនេះ ជៀសវាងការធ្វេសប្រហែសរបស់ខ្លួន ព្រោះថា តាមប្រកាសរបស់ក្រសួងយុត្តិធម៌ស្ដីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" បានអនុញ្ញាតិឲ្យតតិយជន ឬ បុគ្គលណាក៏ដោយ មានសិទ្ធិដឹងអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ព្រមទាំងកម្មវត្ថុនៃកិច្ចសន្យាផង ដោយត្រូវដាក់ពាក្យសុំចេញលិខិតបញ្ជាក់អំពីកិច្ចសន្យានោះ ។ ហេតុនេះតតិយជន គួរតែពិនិត្យមើលទៅលើទំនាក់ទំនងប្ដីប្រពន្ធជាមុនសិននឹងបង្កើតចំណងកាតព្វកិច្ចជាមួយភាគី ។

# ជំពូកទី៣

# ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

កិច្ចសន្យា គឺមានអានុភាពនៅពេលដែលគូភាគីបានបង្កើតកិច្ចសន្យា នោះគោរពទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ប៉ុន្តែកិច្ចសន្យាក៏អាចត្រូវបានបញ្ចប់អានុភាពរបស់ខ្លួនផងដែរ ក្នុងករណីដែលភាគីនៃកិច្ចសន្យាបានឆន្ទៈក្នុងការរំលាយកិច្ចសន្យានៅពេលមូលហេតុនៃការរំលាយនោះត្រូវបានច្បាប់ទទួលស្គាល់ ហើយកិច្ចសន្យា ក៏ត្រូវមោឃភាព និង លុបចោលក្នុងករណីដែលកិច្ចសន្យានោះមានភាពផ្ទុយច្បាប់ និងខ្លឹមសារនៃកិច្ចសន្យានោះផលប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ។ តួយ៉ាងករណីកិច្ចសន្យាទ្រព្យសម្បត្តិ នឹងត្រូវបញ្ចប់អានុភាព ក្នុងមូលហេតុពីរយ៉ាងធំនោះ គឺ ការរំលាយកិច្ចសន្យាតាមរយៈការទទួលស្គាល់របស់ច្បាប់ និង ការមោឃភាព និងលុបចោលទៅលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។ អានុភាពនៃការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏ត្រូវបានកើតមាននូវអានុភាពផងដែរ ចំពោះគូភាគីដែលជាសហព័ទ្ធ និង អានុភាពដែលនឹងកើតឡើងក៏ដូចជាការការពារទៅលើផលប្រយោជន៍តតិយជនក្នុងករណីកិច្ចសន្យានោះត្រូវបានរំលាយ ។

## ផ្នែកទី១ មូលហេតុដែលនាំឱ្យបញ្ចប់កិច្ចសន្យា

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នឹងត្រូវបញ្ចប់អានុភាពរបស់ខ្លួនទៅលើមូលហេតុធំៗ ចំនួន ២ ក្នុងនោះរួមមាន ការរំលាយអាពាហ៍ពិពាហ៍របស់គូភាគីជាសហព័ទ្ធ និង ករណីផ្សេងៗទៀតដែលសំដៅការមោឃភាព លុបចោល និង ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយឆន្ទៈរបស់ភាគី ។

### ១.ការរំលាយអាពាហ៍ពិពាហ៍

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបង្កើតឡើងដើម្បីបម្រើដល់ការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ហេតុនេះនៅពេលប្តីបានសម្រេចចិត្តធ្វើការលែងលះ នោះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក៏ត្រូវបានបញ្ចប់ទៅតាមរយៈនៃការបញ្ចប់អត្ថិភាពអាពាហ៍ពិពាហ៍នេះផងដែរ ។

#### ១.១. ការលែងលះ

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នឹងត្រូវបានរំលាយអានុភាពនៅពេលដែលមូលហេតុនៃការលែងលះត្រូវបានប្រកាសដោយដីកាសម្រេចរបស់តុលាការ ដោយការព្រមព្រៀងរបស់សហព័ទ្ធ ថានឹងលែងរស់នៅជាមួយគទៅ ដោយសារកត្តាជាច្រើនដូចជា ការរស់នៅមិនចុះសម្រុងជាមួយគ្នា សហព័ទ្ធទាំងសងខាងអស់សេចក្តីស្រលាញ់រវាងគ្នា នឹង គ្នា និងមានកត្តាជាច្រើនទៀតដែលបង្ហាញថា សហព័ទ្ធទាំងសងខាងមានបំណងក្នុងលែងលះដោយពិតប្រាកដ ។ ការរំលាយអាពាហ៍ពិពាហ៍ដោយឆន្ទៈរបស់សហព័ទ្ធនឹងនាំឱ្យកិច្ចសន្យាទ្រព្យសម្បត្តិត្រូវរំលាយទៅតាមអាពាហ៍ពិពាហ៍នោះដែរ ។ ហេតុនេះ សហព័ទ្ធត្រូវដាក់ពាក្យសុំទៅតុលាការដើម្បី

សេចក្ដីសម្រេចអំពីអនុញ្ញាតឱ្យភាគីលែងលះ ។ ម៉្យាងទៀតករណីដែលតុលាការបានចេញសេចក្ដីសម្រេចដែលជា សាលក្រម ឬ សាលដីកា អំពីការលែងលះ តាមរយៈបណ្ដឹងទាមទារលែងលះ ដែលប្ដឹងដោយសហព័ទ្ធណាម្ខាង នោះក្រោយការចូលជាធរមាននៃសេចក្ដីសម្រេច នាំឱ្យមានអានុភាពក្នុងការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ប៉ុន្តែសង្កេតឃើញថាតុលាការ អាចនឹងយកខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធរបស់ភាគីមកធ្វើជាកម្មវត្ថុនៃការបែងចែកទ្រព្យសម្បត្តិ (ក្នុងករណីដែលភាគីបានព្រមព្រៀងគ្នាអំពីការចែកទ្រព្យសម្បត្តិក្នុងកិច្ចសន្យា) ។ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយសេចក្ដីសម្រេចរបស់តុលាការ ក៏ត្រូវបានកើតឡើងចំពោះកំជាប់ពាក្យរបស់បុគ្គលដែលនឹងត្រូវអាពាហ៍ពិពាហ៍ផងដែរ ហេតុនេះប្រសិនបើមានភាគីម្ខាងនៃកំជាប់ពាក្យបានដាក់បណ្ដឹងទាមទារឱ្យរំលាយកំជាប់ពាក្យ

ការរំលាយកិច្ចសន្យាទ្រព្យតាមសម្បត្តិប្ដីប្រពន្ធតាមរយៈសេចក្ដីសម្រេចតុលាការ តម្រូវឱ្យភាគីដែលជាអតីតសហព័ទ្ធណាម្ខាងត្រូវទៅដាក់ពាក្យសុំលុបចោល ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

- **ខ្លឹមសារនៃពាក្យសុំ**

ពាក្យសុំត្រូវអនុលោមតាមទម្រង់នៃពាក្យសុំចុះបញ្ជីនៃប្រកាសរបស់ក្រសួងយុត្តិធម៌នឹងត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនក្នុងប្រការ ២៥ នៃប្រកាសដដែលដូចជា ៖

- អត្តសញ្ញាណភាគីនៃកិច្ចសន្យា (នាម-គោត្តនាម កាលបរិច្ឆេទកំណើត និងអាសយដ្ឋាន)
- ត្រូវបង្ហាញពីគោលបំណងនៃការចុះបញ្ជី ( ត្រង់ចំណុចនេះ ភាគីអាចបំពេញនៅក្នុងលិខិតគំរូដែលមានក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ដោយត្រូវបំពេញថា " លុបចោលនូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ" )
- ត្រូវបញ្ជាក់ពីមូលហេតុ និង កាលបរិច្ឆេទឱ្យបានច្បាស់លាស់ (ករណីមានសាលក្រម ឬ សាលដីកាត្រូវដាក់កាលបរិច្ឆេទនៃសាលក្រម ឬសាលដីកានោះវិញ )

- **ឯកសារភ្ជាប់នៃពាក្យសុំ**

ក្រៅអំពីការបំពេញនូវទម្រង់ពាក្យសុំចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធហើយ ភាគី ឬ អ្នកតំណាងដែលមកធ្វើការចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនទៀតដូចជា ៖

- សេចក្ដីសម្រេចរបស់តុលាការ អំពីការរំលាយអាពាហ៍ពិពាហ៍
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសេចក្ដីសម្រេចរបស់តុលារ
- លិខិតប្រគល់សិទ្ធិតំណាង (ករណីភាគីមានអ្នកតំណាង)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន ។

### ១.២.មរណៈភាព ឬ បាត់ខ្លួន

ចំពោះការមរណៈភាពភាគីនេះត្រូវអនុវត្តទាំងក្នុងករណីអាពាហ៍ពិពាហ៍ និង កំជាប់ពាក្យ ។ ពេលដែលមានភាគីម្ខាងណាបានទទួលមរណៈភាពនោះ កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ នឹងត្រូវរំលាយ ត្បិតថាកិច្ចសន្យានេះត្រូវបង្កើតឡើងដើម្បីឲ្យប្ដីប្រពន្ធ ធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួន ហើយកិច្ចសន្យានេះជាប្រភេទកិច្ចសន្យាអញ្ញមញ្ញ ដែលតម្រូវឱ្យភាគីមានករណីយកិច្ចចំពោះគ្នាទៅវិញទៅមក តែបើមានម្ខាងណាបានមរណៈភាពហើយនោះកិច្ចសន្យានេះ មិនអាចបន្តទៅមុខទៀតបានទេ ។ ម្យ៉ាងវិញទៀតនៅពេលដែលភាគីបានទទួលមរណៈភាព នោះសន្តតិកម្មនឹងចាប់ផ្ដើមឡើង[80] ។ នាពេលសន្តតិកម្មនឹងត្រូវផ្ដើម នោះទ្រព្យសម្បត្តិរបស់មត៌កជនត្រូវបានបែងចែក នេះក៏ជាហេតុផលដែលតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធនឹងត្រូវរំលាយ ព្រោះសន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចបន្តពីមតកជន។[81] ដូចគ្នានេះប្រសិនភាគីម្ខាងត្រូវបានបាត់ខ្លួនដោយមិនដឹងអំពីមូលហេតុដោយប្រការណាមួយ ហើយត្រូវបានតុលាការប្រកាសអំពី ការបាត់ខ្លួនរបស់ភាគីហើយនោះភាគីម្ខាងទៀតអាចធ្វើការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធបាន ដូចនឹងករណីមរណៈភាពភាគីដែរ ព្រោះថាក្នុងក្រមរដ្ឋប្បវេណីបានចាត់ទុក ការបាត់ខ្លួនដែលគ្រប់លក្ខខណ្ឌកំណត់នៅក្នុងក្រមនេះ គឺជាការទទួលមរណៈភាព[82] ។

- **ខ្លឹមសារនៃពាក្យសុំ**

ភាគីត្រូវសរសេរខ្លឹមនៃពាក្យសុំចុះបញ្ជីអំពីការលុបចោល ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយយោងតាមប្រការ ១៦ នៃប្រកាសរបស់ក្រសួងយុត្តិធម៌ ហើយត្រូវគោរពតាមខ្លឹមសារបន្ថែមនៃប្រការ ២៤ នៃប្រកាសដដែលនេះ ដោយត្រូវបន្ថែម ៖

- អត្តសញ្ញាណភាគី (នាម-គោត្តនាម កាលបរិច្ឆេទនៃកំណើតភាគី អាសយដ្ឋាន)
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ និង កាលបរិច្ឆេទ (ភាគីត្រូវបញ្ជាក់អំពីមូលហេតុដែលនាំឲ្យមរណភាពរបស់ភាគី[83] និងត្រូវបញ្ជាក់អំពីកាលបរិច្ឆេទនៃមរណៈភាព ឬ បាត់ខ្លួន របស់សហព័ទ្ធម្ខាង ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នា)

---

[80]មាត្រា ១១៤៥ "មូលហេតុនៃការចាប់ផ្ដើមធ្វើសន្តតិកម្ម" នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

[81] មាត្រា ១១៤៧ "ការទទួលបន្តនូវមត៌ក" កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

[82] មាត្រា ៤១ "ល័ក្ខខណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន" នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ។

[83] ភាគីអាចសរសេរបន្ថែមអំពីហេតុដែលនាំឱ្យមានការមរណៈភាពរបស់ភាគីម្ខាងទៀត ដូចជា បានទទួលមរណៈភាពដោយគ្រោះថ្នាក់ចរាចរណ៍ ឬ ជម្ងឺ ...ជាដើម ប្រសិនបើភាគីមិនចង់បង្ហាញអំពីមូលហេតុនៃការទទួលមរណៈភាពរបស់ភាគីទេ ភាគីគ្រាន់តែសរសេរបញ្ជាក់

- **ឯកសារភ្ជាប់នៃពាក្យសុំ**

អនុលោមតាមប្រកាសនៃក្រសួងយុត្តិធម៌ អំពីនីតិវិធីចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ភាគីត្រូវមកជាមួយនូវឯកសារភ្ជាប់មាន ៖

- លិខិតអត្រានុកូលដ្ឋានស្តីពី "មរណៈភាព" (សំបុត្រមរណៈភាព)
- សេចក្តីប្រកាសរបស់តុលាការស្តីពី "ការបាត់ខ្លួន" (ករណីបាត់ខ្លួន)
- លិខិតប្រគល់សិទ្ធិតំណាង (ករណីភាគីមានអ្នកតំណាង)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់ភាគីនៃអ្នកសុំ

## ២.ការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងករណីផ្សេងទៀត

### ២.១.មោឃភាព ឬ ការលុបចោលអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ ដែលកើតឡើងតាមរយៈការបង្ខិតបង្ខំ ការភាន់ច្រឡំ ការរៀបអាពាហ៍ពិពាហ៍ដែលផ្ទុយទៅនឹងបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី គឺ ភាគីមិនទាន់គ្រប់អាយុ អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬ ញាតិពន្ធ ឬ ទ្វេពន្ធភាព ឬ រៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ជាដើម....។ មូលហេតុខាងលើសុទ្ធតែនាំមានមោឃភាព ឬ លុបចោលទៅលើអាពាហ៍ពិពាហ៍ ដូច្នេះបើតុលាការបានដីកាសម្រេចអំពីមោឃភាព ឬ ការលុបចោល អតីតសហព័ទ្ធត្រូវទៅដាក់ពាក្យសុំលុបចោល ការចុះបញ្ជីលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

- **ខ្លឹមសារនៃពាក្យសុំ**

ចំពោះពាក្យសុំ ភាគីត្រូវគោរពតាមទម្រង់នៃពាក្យសុំដែលបានកំណត់ ហើយភាគីត្រូវសរសេរបន្ថែមតាមកំណត់នៃប្រការ ២៣ កថាខណ្ឌទី២ នៃប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ដូចខាងក្រោម ៖

- អត្តសញ្ញាណភាគី (នាម-គោត្តនាម កាលបរិច្ឆេទនៃកំណើតភាគី អាសយដ្ឋាន)
- គោលបំណងនៃការចុះបញ្ជី (ជាទូទៅនៅពេលចុះបញ្ជីលុបចោលការចុះបញ្ជីកិច្ចសន្យា ភាគីត្រូវបំពេញអំពី គោលបំណងនៃការចុះបញ្ជីនេះឲ្យបានច្បាស់លាស់)
- មូលហេតុ និង កាលបរិច្ឆេទ (ភាគីត្រូវបញ្ជាក់អំពីមូលហេតុដែលនាំឲ្យមានការមោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យា[84]នេះ ហើយភាគីត្រូវបញ្ជាក់អំពីកាលបរិច្ឆេទនៃការមោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យានេះ)

---

មូលហេតុថា ភាគីម្ខាងបានទទួលមរណភាព ហេតុនេះខ្លួនមានករណីយកិច្ចក្នុងការដាក់ពាក្យសុំចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធតែប៉ុណ្ណោះ...។

[84] ករណីរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចមកពីភាគីទាំងសងបានសម្រេចចិត្តផ្លាស់ប្តូររបៀបរបបនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដូចជាផ្លាស់ប្តូរពីការព្រមព្រៀងទ្រព្យដោយកិច្ចសន្យា មកជាការគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់វិញជាដើម...។

- **ឯកសារភ្ជាប់នៃពាក្យសុំ**

ភាគីត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា ៖

- សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់អំពី មោឃភាព ការលុបចោល
- លិខិតបញ្ជាក់អំពីការចូលស្ថាពរនៃសាលក្រម ឬ សាលដីកា
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹង ដែលបញ្ជាក់ពីការលុបចោល ឬ រំលាយកិច្ចសន្យា
- លិខិតប្រគល់សិទ្ធិតំណាង (ករណីភាគីមានអ្នកតំណាង)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់ភាគី

## ២.២.ការបញ្ចប់កិច្ចសន្យាដោយឆន្ទៈភាគី

ប្រសិនបើភាគីយល់ឃើញថា ការគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈកិច្ចសន្យាមានភាពលំបាក ឬ ធ្វើឲ្យមនោសញ្ចេតនារបស់ខ្លួនមានការបែងចែក ឬ មានគម្លាតពេក ភាគីក៏អាចធ្វើការសម្រេចធ្វើការរំលាយកិច្ចសន្យានេះបានដែរ ប៉ុន្តែការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុ ផ្លាស់ប្តូរប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិ មិនអាចធ្វើការរំលាយដោយឯកត្តោភាគីបានឡើយ ។

- **ខ្លឹមសារនៃពាក្យសុំ**

ចំពោះពាក្យសុំ ភាគីត្រូវគោរពតាមទម្រង់នៃពាក្យសុំដែលបានកំណត់ ហើយភាគីត្រូវសរសេរបន្ថែមតាមកំណត់នៃប្រការ ២៣ កថាខណ្ឌទី២ នៃប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ដូចខាងក្រោម ៖

- អត្តសញ្ញាណភាគី (នាម-គោត្តនាម កាលបរិច្ឆេទនៃកំណើតភាគី អាសយដ្ឋាន)
- គោលបំណងនៃការចុះបញ្ជី (ជាទូទៅនៅពេលចុះបញ្ជីលុបចោលការចុះបញ្ជីកិច្ចសន្យា ភាគីត្រូវបំពេញអំពី គោលបំណងនៃការចុះបញ្ជីនេះឲ្យបានច្បាស់លាស់)
- មូលហេតុ និង កាលបរិច្ឆេទ (ការរំលាយកិច្ចសន្យា[85]នេះ ហើយភាគីត្រូវបញ្ជាក់អំពីកាលបរិច្ឆេទនៃការមោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យានេះ)

- **ឯកសារភ្ជាប់នៃពាក្យសុំ**

ភាគីត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចជា ៖

- កិច្ចព្រមព្រៀងរបស់ភាគីអំពីការរំលាយកិច្ចសន្យា

[85] ករណីរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ អាចមកពីភាគីទាំងសងបានសម្រេចចិត្តផ្លាស់ប្តូររបៀបរបបនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដូចជាផ្លាស់ប្តូរពីការព្រមព្រៀងទ្រព្យដោយកិច្ចសន្យា មកជាការគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់វិញជាដើម...។

- លិខិតប្រគល់សិទ្ធិតំណាង (ករណីភាគីមានអ្នកតំណាង)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់ភាគី

## ផ្នែកទី២ អានុភាពនៃការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ក្រោយការបញ្ចប់នៃកិច្ចសន្យាជាទូទៅ នឹងកើតមាននូវអានុភាពនៃការបញ្ចប់កិច្ចសន្យាត្រឡប់ទៅវិញ ។ នៅក្នុងក្រមរដ្ឋប្បវេណី បានបង្ហាញអំពីអានុភាពនៃការរំលាយកិច្ចសន្យាថា គូភាគីនៃកិច្ចសន្យាត្រូវបានរួចផុតអំពីកាតព្វកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងសំណងនៃការខូចខាតចំពោះភាគី និង គូភាគីត្រូវបដិទានឡើងវិញនូវស្ថានដើមរបស់ភាគីម្ខាងទៀត ហើយទោះបីជាគូភាគីបានធ្វើការរំលាយកិច្ចសន្យាក៏ដោយ ក៏ត្រូវប្រាកដថាមិនមានផលប៉ះពាល់ដល់ប្រយោជន៍នៃតតិយជនឡើយ ។ តាមរយៈក្រមរដ្ឋប្បវេណី បានឱ្យដឹងថា នៅពេលកិច្ចសន្យាត្រូវបានរំលាយនោះ អានុភាពនៃការបញ្ចប់នឹងកើតមានចំពោះគូភាគី និង តតិយជន ។ ដូចគ្នានេះដែរ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក៏មានអានុភាពនៃការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធចំពោះគូភាគី និង តតិយជន ផងដែរ ។

### ១.អានុភាពបញ្ចប់កិច្ចសន្យាចំពោះគូភាគី

#### ១.១.អានុភាពមិនប្រតិសកម្ម

ក្រោយការបញ្ចប់អានុភាពនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធទៅ ទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានកម្រិតជាកម្មវត្ថុនៃកិច្ចសន្យាមិនមានអានុភាពប្រតិសកម្មទៅវិញឡើយ ។ ហេតុដែលមិននាំឱ្យមានអានុភាពប្រតិសកម្មត្រឡប់ទៅរកភាពដើមមុនពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបានកើតឡើង ព្រោះអានុភាពប្រតិសកម្មក្នុងទ្រព្យសម្បត្តិប្តីប្រពន្ធ នឹងមានផលប៉ះពាល់ យ៉ាងធ្ងន់ធ្ងរទៅលើតតិយជន (ករណី ដែលកម្មវត្ថុនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានអនុប្បទានដោយការលក់ទិញជាដើម...) ។ ប៉ុន្តែបើសង្កេតទៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ បានលើកឡើងថា ក្រោយការរំលាយកិច្ចសន្យាត្រូវមានអានុភាពធ្វើបដិទាននូវកម្មវត្ថុនៃកិច្ចសន្យានោះ ត្រឡប់ទៅស្ថានដើមវិញ[86] ករណីនេះមិនអាចមកធ្វើការដោះស្រាយបញ្ហាក្នុងករណីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលមានសុពលភាពយ៉ាងពេញលេញ[87]បានឡើយ ព្រោះនៅពេលដែលកិច្ចសន្យាមានអានុភាព នោះទ្រព្យសម្បត្តិរួម នឹងអាចកើតមាននូវតម្លៃតបដែលកើតចេញពីទ្រព្យនោះ ហេតុនេះប្រសិនបើធ្វើបដិទានតម្លៃតប

[86] មាត្រា ៤១១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ។

[87] ដកស្រង់គោលគំនិតទាំងស្រុងពីការបកស្រាយអំពីការមិនទទួលស្គាល់នូវអានុភាពប្រតិសកម្មចំពោះកិច្ចសន្យា របស់សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ ១ ជំពូកទី ៣ ផ្នែកទី ៦ កថាភាគទី ៤ ។

នោះនឹងត្រូវបាត់បង់ដូចគ្នា ។ ម៉្យាងវិញទៀតបើកិច្ចសន្យាបានអនុវត្តហើយជាច្រើនឆ្នាំកន្លងទៅ ការបដិទានក៏នឹងមិនកើតឡើងដែរ ព្រោះថា ស្ថានភាពនៃកម្មវត្ថុនៃកិច្ចសន្យានោះអាចត្រូវបានផ្លាស់ប្តូររួចទៅហើយ ។

**ឧទាហរណ៍៖** សុចិត្រា និង កណ្ណិកា ជាប្តីប្រពន្ធ បានបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយសុចិត្រា បាន ផ្ទះវីឡាមួយកន្លែងរបស់ខ្លួន ដាក់ជាទ្រព្យឡែកឱ្យកណ្ណិកា ហើយកណ្ណិកាបានលក់ផ្ទះនោះ បន្ទាប់ពី ៥ ឆ្នាំនៃការបង្កើតកិច្ចសន្យា ។ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ៣០ ឆ្នាំ អ្នកទាំងពីរបានសម្រេចចិត្តព្រមព្រៀងលែងលះ សុចិត្រា ទាមទារឱ្យកណ្ណិកាប្រគល់ផ្ទះវីឡានោះឱ្យខ្លួនវិញ ។ ក្នុងស្ថានភាពបែបនេះ សង្កេតឃើញថា ការបដិទាន ត្រឡប់មិនអាចកើតឡើងបានឡើយ ប្រសិនបើធ្វើបដិទានត្រឡប់នូវផ្ទះវីឡាដែលអ្នកនាង កណ្ណិកាបានលក់នោះ នឹងមានផលប៉ះដល់តតិយជនដែលបានទិញផ្ទះវិឡានោះ ។

### ១.២.ការបែងចែកទ្រព្យសម្បត្តិ

សហព័ទ្ធ នឹងត្រូវធ្វើការបែងចែកទ្រព្យសម្បត្តិនោះ ទៅតាមការព្រមព្រៀងដែលមាននៅក្នុងកិច្ចសន្យា ។[88] ទោះបីជាអាពាហ៍ពិពាហ៍បានបញ្ចប់ក៏ដោយ ក៏អាចសង្កេតឃើញថា កិច្ចសន្យានេះនៅតែបន្តមានអានុភាពរបស់ខ្លួនរហូតដល់វិវាទទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបញ្ចប់ នេះគឺជាគោលបំណងនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធឡើង ដើម្បីជួយដោះស្រាយ និង ធ្វើការទប់ស្កាត់ចំពោះវិវាទប្តីប្រពន្ធលើការបែងចែកទ្រព្យសម្បត្តិ ហើយស្ថានភាពខ្លះនឹងនាំឱ្យការលែងលះរបស់សហព័ទ្ធ ដែលព្រមព្រៀងគ្នាធ្វើការលែងលះមានងាយស្រួលជាងមុនផងដែរ ព្រោះពេលភាគីមានកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បានព្រមព្រៀងគ្នាអំពីខ្លឹមសារនៃការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះបានច្បាស់លាស់ហើយនោះ សហព័ទ្ធគ្រាន់តែដាក់ពាក្យសុំបណ្តឹងលែងលះទៅកាន់តុលាការដើម្បីចេញដីកាសម្រេច គឺតុលាការនឹងធ្វើការចេញដីកាសម្រេចដែលមាន ខ្លឹមសារតាមការស្នើសុំរបស់ភាគីដែលត្រូវអនុវត្តការបែងចែកទ្រព្យសម្បត្តិតាមកិច្ចសន្យាទ្រព្យសម្បត្តិដែលភាគីមាន ។

## ២.អានុភាពនៃការបញ្ចប់ក្នុងករណីរំលាយកិច្ចសន្យាដោយឆន្ទៈភាគី

### ២.១.សហព័ទ្ធផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រង

ការរំលាយកិច្ចសន្យានៅក្នុងករណីនេះ គឺបណ្តាលមកពីសហព័ទ្ធ មានក្នុងការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ពីការគ្រប់គ្រងតាមរយៈកិច្ចសន្យា មកជា ការគ្រប់គ្រងតាមកំណត់របស់ច្បាប់វិញ នៅក្នុងករណីនេះ អានុភាពនៃការបញ្ចប់កិច្ចសន្យា គឺធ្វើឱ្យទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានកំណត់ក្នុងកិច្ចសន្យាថាចំណែកណាមួយជាទ្រព្យសម្បត្តិរួម ទ្រព្យនោះ គឺនៅតែជាទ្រព្យរួមរវាង ហើយទ្រព្យណាដែលបានកំណត់ថា ជាទ្រព្យដោយឡែក ទ្រព្យនោះជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ មានន័យថា បើប្តីប្រពន្ធបានប្រើប្រាស់

[88] មាត្រា ៩៨០ កថាខណ្ឌទី ១ "ការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធផ្អែកតាមការពិភាក្សារបស់ភាគីប្តីប្រពន្ធ"នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ ។

អានុភាពកិច្ចសន្យានោះរួចហើយ គឺត្រូវអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យានោះ ទោះបីជាបានរំលាយក៏ដោយ គឺដោយសារទ្រព្យសម្បត្តិប្ដីប្រពន្ធ គ្មានអានុភាពប្រតិសកម្មឡើយ ហេតុនេះមិនអាចត្រឡប់ទៅមុនពេលដែលសហព័ទ្ធបានធ្វើការសន្យាគ្នានោះទេ ។

**២.២.ការបញ្ចប់កំជាប់ពាក្យ**

នៅពេលកំជាប់ពាក្យត្រូវបានបញ្ចប់តាមមូលហេតុអ្វីក៏ដោយ នោះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដែលភាគីបានព្រមព្រៀងចរចាគ្នាបង្កើតកាលពីពេលមុន ក៏នឹងត្រូវបញ្ចប់វត្តមានរបស់ខ្លួនផងដែរ ។ តាមពិតទៅកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក្នុងករណីបុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា គឺគ្មានអានុភាពទេ ព្រោះថាគោលការណ៍គ្រឹះដែលជា ការរៀបអាពាហ៍ពិពាហ៍មិនទាន់បានកើតឡើង ហេតុនេះអានុភាពនៃការបញ្ចប់ក៏មិនមានដែរ ប៉ុន្តែភាគីទាំងសងខាង ត្រូវតម្រូវឱ្យទៅដាក់ពាក្យសុំលុបចោល ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធវិញ ។

**៣.អានុភាពនៃការបញ្ចប់កិច្ចសន្យាចំពោះតតិយជន**

នៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវបានបញ្ចប់មើលឃើញថាមានអានុភាពនៃការបញ្ចប់កិច្ចសន្យានោះកើតឡើង តែមិនមែនមានអានុភាពនៃការបញ្ចប់ចំពោះតែគូភាគីជាសហព័ទ្ធ ឬ បុគ្គលដែលត្រូវរៀបអាពាហ៍ពិពាហ៍នឹងគ្នា ឬ គូកំជាប់ពាក្យ ប៉ុណ្ណោះទេ ។ អានុភាពនៃការបញ្ចប់កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក៏ត្រូវបានសង្កេតឃើញថា កើតឡើងចំពោះតតិយជនផងដែរ ។ តតិយជន នៅក្នុងករណីនេះអាចមាន ២ ស្ថានភាព ដែលទី១ សំដៅលើម្ចាស់បំណុលរបស់គូភាគី និង ទី២ សំដៅទៅលើសន្តតិជន ។

**៣.១.អានុភាពចំពោះម្ចាស់បំណុល**

ប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធត្រូវបានរំលាយដោយសារមូលហេតុអ្វីក៏ដោយ ហើយត្រូវបានប៉ះពាល់ដល់ផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជន នោះតតិយជននឹងត្រូវបានការពារ[89] ។ ព្រោះថា តតិយជនមិនបានស្ថិតក្នុងទំនាក់ទំនងរវាងប្ដីប្រពន្ធទាំងពីរឡើយ ប៉ុន្តែតតិយជនបែរជាត្រូវជួបប្រទះនឹងទៅហេតុលំបាកដែលកើតចេញអំពីទំនាក់ទំនងប្ដីប្រពន្ធទៅវិញ ហេតុនេះហាក់បីដូចជាមិនមានសមភាពចំពោះតតិយជនទាល់តែសោះ ។

**៣.២.អានុភាពចំពោះសន្តតិជន**

ក្រោយការបញ្ចប់អានុភាពកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដោយសារមូលហេតុនៃមរណៈភាព ឬ បាត់ខ្លួន នាំឱ្យសន្តតិជនអាចទទួលបាននូវចំណែកមត៌កពីមត៌កជនរបស់ខ្លួន ព្រោះខ្លឹមសារនៃក្រមរដ្ឋប្បវេណី គឺត្រូវ

[89] មាត្រា ៩១១ កថាខ័ណ្ឌទី៤ "អានុភាពនៃការរំលាយកិច្ចសន្យា" នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលលើកឡើងអំពីការពារទៅលើ តតិយជនត្រឹមត្រូវ ។

ប្រកាសអំពី ការចាប់ផ្តើមសន្តតិកម្ម ។[90] ហេតុនេះទ្រព្យសម្បត្តិទាំងអស់របស់សហព័ទ្ធជាមត៌កជន នឹងត្រូវយកមកធ្វើការបែងចែកទៅចំណែកដែលច្បាប់បានកំណត់ ព្រោះថា ច្បាប់មានបំណងឱ្យសន្តតិជននៃភាគីជាមត៌កជន អាចធ្វើការទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចរបស់ភាគី ។ ម្យ៉ាងវិញទៀតចំពោះ ការធ្វើបែបនេះអាចនឹងជួយដោះស្រាយដល់ជីវភាពរបស់ភាគីម្ខាងទៀត ឬ សន្តតិជន អោយមានភាពងាយស្រួលជាងមុន ត្បិតថាក្នុងស្ថានភាពភាគីម្ខាងទៀតនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្រោយការមរណៈភាព ឬ ការបាត់ខ្លួនរបស់ភាគីម្ខាងទៀត នឹងធ្វើឱ្យជីវភាពរបស់ពួកគាត់អាចមានការថយចុះ ហើយបើចំពោះតតិយជន អាចជាម្ចាស់បំណុល ក៏អាចទទួលនូវសំណងរបស់ខ្លួនត្រឡប់មកវិញដែរ ។

[90] មាត្រា ១១៥៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ បង្ហាញអំពី ការចាប់ផ្តើមនៃសន្តតិកម្មនៅពេលមរណភាពរបស់មតកជន និង មាត្រា ៤៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ ២០០៧ បង្ហាញពី អានុភាពនៃការប្រកាសបាត់ខ្លួន ដែលការបាត់ខ្លួននៅក្នុងប្រកាសរបស់តុលាការត្រូវសន្មតថាជាការទទួលមរណភាព ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ដែលផ្តោតសំខាន់ទៅលើលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលរួមមានទាំងលក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ ។ ចំពោះលក្ខខណ្ឌទម្រង់ក្នុងការចុះបញ្ជី សង្កេតឃើញថានៅកម្ពុជាបច្ចុប្បន្នពុំទាន់មានដំណោះស្រាយអំពីការចុះបញ្ជីដែលអចលទ្រព្យស្ថិតនៅក្នុងទឹកដីនៃរដ្ឋបរទេសនៅឡើយទេ ហេតុនេះវាអាចជាបញ្ហាមួយនៃការរារាំងដល់ការសម្រេចចិត្តរបស់សហព័ទ្ធក្នុងការចុះបញ្ជី និង បង្កើតកិច្ចសន្យា ម្យ៉ាងទៀតការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ មានតែមួយកន្លែងទេក្នុងព្រះរាជាណាចក្រកម្ពុជា គឺអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ហេតុនេះទីតាំងនៃការចុះបញ្ជី ត្រូវតម្រូវឱ្យភាគី ត្រូវចំណាយពេលវេលាច្រើន និងចំណាយថវិកាច្រើនក្នុងការចុះបញ្ជី ។

ក្រៅពីនេះ សង្កេតឃើញថាការផ្សព្វផ្សាយអំពី កិច្ចសន្យាទ្រព្យសម្បត្តិហាក់បីដូចជាពុំទាន់ទូលាយនៅឡើយទេ ហេតុនេះអាចប្រជាពលរដ្ឋ អាចមិនទាន់យល់អំពីការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនៅឡើយទេ ពោលឱ្យចំ គឺពលរដ្ឋមួយចំនួនក្រៅតែអំពីអ្នកសិក្សាផ្នែកនីតិវិទ្យា មិនដឹងអំពីវត្តមានរបស់ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈកិច្ចសន្យានេះផងក៏ថាបាន ។ ម៉្យាងវិញទៀតក៏ផ្សព្វផ្សាយកន្លងមក ដូចជាមិនបានបង្ហាញឱ្យច្បាស់អំពីផលប្រយោជន៍ចំពោះកិច្ចសន្យានេះទៅលើប្តីប្រពន្ធទេ បែរជាសំដៅទៅរកអត្ថន័យនៃការបង្កើតកិច្ចសន្យាតែម្តង ។ ជាមតិយោបល់របស់ស្មេរ យល់ឃើញថា៖

- ស្ថាប័នទទួលបន្ទុកអំពីការផ្សព្វផ្សាយទៅលើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ គួរបង្ហាញអំពីផលប្រយោជន៍នៃប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមរយៈកិច្ចសន្យា ទៅកាន់ពលរដ្ឋឱ្យបានច្រើន និង តាមគ្រប់មធ្យោបាយ ជាពិសេស ការសរសេរអត្ថបទនៅលើបណ្តាញសង្គម មិនថាជាភាសាជាតិ ឬ ភាសាបរទេស ព្រោះថា សព្វថ្ងៃកម្ពុជាបានអនុវត្តគោលការណ៍សហរណកម្ម ដែលអាចឱ្យជនបរទេសមានសិទ្ធិក្នុងការរស់ និង ប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចកម្ពុជាកាន់តែច្រើនឡើង ។ ដូច្នេះការសរសេរជាភាសាបរទេស ក៏អាចជួយជំរុញដល់ការបង្កើតកិច្ចសន្យាផងដែរ ហើយក៏ដូចជាការជួយជ្រោមជ្រែងដល់ពលរដ្ឋខ្មែររៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ដើម្បីការពារសិទ្ធិទ្រព្យសម្បត្តិដែលសហព័ទ្ធអាចទទួលបាន ។
- ការរៀបចំស្ថាប័នដែលអាចមានសមត្ថកិច្ចក្នុងការចុះបញ្ជីទៅតាមបណ្តាលខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីងាយស្រួលដល់ពលរដ្ឋក្នុងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរបស់ពលរដ្ឋឱ្យកាន់តែងាយស្រួល ។

# ឯកសារយោង

## ១.ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

1. ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ។
2. ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រ កម្ពុជា ។
3. ប្រកាសស្តីពី "នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" លេខ ៨១កយ/ប្រក/១៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣ ។
4. ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី លេខ៣០កយ.ជនស.ប្រក/១៣ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ ។
5. ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ ៥៥១ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០ ។

## ២.បទដ្ឋានគតិយុត្តបរទេស

1. ច្បាប់ស្តីពី អាពាហ៍ពិពាហ៍ និង គ្រួសារ លេខ ៥២/២០១៤/QH១៣ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។
2. ក្រមរដ្ឋប្បវេណី នៃសាធារណៈរដ្ឋបារាំង ឆ្នាំ ១៨០៤ ។
3. ក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម នៃព្រះរាជាណាចក្រថៃ ឆ្នាំ ១៩២៥ ។

## ៣.សៀវភៅ

1. លោកសាស្ត្រាចារ្យ ណូមីរ៉ា តូយ៉ូហ៊ីរ៉ូ "សេចក្តីផ្តើមនីតិរដ្ឋប្បវេណី" បកប្រែដោយ លោក សរ សិនិរ៉ា និង លោក ស៊ឹម វិរៈ បោះពុម្ពផ្សាយខែមេសា ឆ្នាំ ២០១៤ ។
2. លោកសាស្ត្រាចារ្យ ទីស៊ូជី យ៉ាស៊ូហ៊ីកូ (Tsuji Yasuhiko) ឯកសារមេរៀន និង បទបង្ហាញ ស្តីពី "ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ" ស្ថិតនៅក្នុងសៀវភៅកម្រងមេរៀនរបស់វិភាគទានច្បាប់ ឆ្នាំ ២០១៧ (កាលបរិច្ឆេទធ្វើបទបង្ហាញ ៖ ថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០១៧ ) ។
3. បណ្ឌិត ព្រុំ រិទ្ធី សៀវភៅជំនួយស្មារតីស្តីពី "នីតិបេតិកភណ្ឌ និង គ្រួសារ" បោះពុម្ពផ្សាយលើកទី១ ឆ្នាំ ២០១៩ ។
4. លោកសាស្ត្រាចារ្យ ម៉ាសាយូគី តាណាម៉ារ៉ា (Masayuki Tanamura) ឯកសារមេរៀន និង បទបង្ហាញ ស្តីពី "ការបកស្រាយអំពីប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ" (កាលបរិច្ឆេទធ្វើបទបង្ហាញ ៖ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៨ ទីកន្លែង សាសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ) ។

6. លោកស្រីសាស្ត្រាចារ្យ ស្រី វណ្ណធី សៀវភៅសិក្សាស្រាវជ្រាវ "នីតិអន្តរជាតិឯកជន" បោះពុម្ពលើកទី១ ឆ្នាំ ២០១១ ។
7. សៀវភៅមេរៀន ក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ រៀបរៀងដោយ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធនិង តុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច បោះពុម្ពលើកទី ១ ធ្វើនៅភ្នំពេញ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ។
8. សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី រៀបចំដោយ គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និង ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ឆ្នាំ ២០០៩-២០១០ ។
9. សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃច្បាប់ស្តីពី "ការអនុវត្តក្រមរដ្ឋប្បវេណី" រៀបចំដោយ គណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណីកម្ពុជា និង ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ឆ្នាំ ២០១១ ។
10. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី រៀបរៀងដោយ ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ធ្វើនៅរាជធានីភ្នំពេញ ខែ មីនា ឆ្នាំ ២០១៧ ។

## ៤.គេហទំព័រ

1. Unicef, ការអប់រំប្រកបដោយគុណភាព និងបំណិនជីវិតសម្រាប់កុមារគ្រប់រូប ៖ https://www.unicef.org/cambodia/education.com (ចូលមើលថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០២២ )
2. Rimcy Keshri និង Saakshi Tibrewal, ភាពខុសគ្នានៃប្រព័ន្ធទ្រព្យសម្បត្តិអាពាហ៍អាពាហ៍នៅលើពិភពលោក , https://thecolumnofcurae.wordpress.com/2020/05/20/different-models-of-matrimonial-property-followed-across-the-world/ . (ចូលមើលថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០២២) ។
3. Chaninat និង Leeds, កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនអាពាហ៍ពិពាហ៍នៅប្រទេសថៃ,
4. http://thailawforum.com/international-prenuptial-agreement-europe%20-prenup-part6.html (ចូលមើលថ្ងៃទី ៤ មិថុនា ឆ្នាំ ២០២២) ។ ការិយាល័យមេធាវី DB LEGAL ការណែនាំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនអាពាហ៍ពិពាហ៍នៅប្រទេសវៀតណាម https://dblegal.vn/news/news/prenuptial-agreement-in-vietnam-957.html (ចូលមើលថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០២២) ។

5. ការិយាល័យ Divorce online, ការណែនាំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនអាពាហ៍ពិពាហ៍នៅប្រទេសអង់គ្លេស, https://www.divorce-online.co.uk/family-law/prenuptial-agreements/#:~:text=case%20of%20divorce.-,What%20is%20the%20difference%20between%20prenups%20and%20postnups%3F,the%20couple%20is%20still%20married. (ចូលមើលថ្ងៃទី ៤ ខែ មិថុនា និងថ្ងៃបន្តបន្ទាប់ក្នុងឆ្នាំ ២០២២) ។
6. Amy Bell, ភាពខុសគ្នារវាងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនអាពាហ៍ពិពាហ៍ និង កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្រោយអាពាហ៍ពិពាហ៍, https://www.investopedia.com/articles/personal-finance/070815/postnup-vs-prenup-how-they-differ.asp (ចូលមើលថ្ងៃទី២០ ខែ មិថុនា ឆ្នាំ ២០២២) ។
7. JULIA KAGAN, ការណែនាំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្រោយអាពាហ៍ពិពាហ៍ https://www.investopedia.com/terms/p/postnuptial_agreement.asp (ចូលមើលថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០២២) ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

1. ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ (ឆ្នាំ ២០១៤) នៃសាធារណៈរដ្ឋសង្គមនិយម វៀតណាម ។
2. ក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម ព្រះរាជាណាចក្រថៃ (ឆ្នាំ ១៩២៥) ។
3. ក្រមរដ្ឋប្បវេណី សាធារណៈរដ្ឋបារាំង ឆ្នាំ ១៨០៤ ។
4. ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ ៨កយ.ប្រក/១៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣ ។
5. ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ ៥៥១ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០ ។

# ឧបសម្ព័ន្ធទី ១

# ច្បាប់ស្តីពី

# អាពាហ៍ពិពាហ៍ និង គ្រួសារ

# លេខ ៥២/២០១៤/QH១៣ ចុះថ្ងៃទី ១៩ ខែ មិថុនា

# ឆ្នាំ ២០១៤ នៃ

# សាធារណរដ្ឋសង្គមនិយមវៀតណាម

| THE NATIONAL ASSEMBLY | THE S OCIALI S T RE P UBLIC OF VIETNAM |
| --- | --- |
| ------- | I n d e p e nd e n c e - Freedom- Ha pp ienss |
| | --------------- |
| No. 52/2014/QH13 | *Hanoi, June 26, 2014* |

# LAW

## ON MARRIAGE AND FAMILY

Section 3. MATRIMONIAL PROPERTY REGIME

**Article 46.** Merger of separate property into common property

1. Separate property of a spouse shall be merged into common property according to the agreement between the husband and wife.

2. For property merged into common property whose transactions are required by law to be under a certain form, the merger agreement must ensure that form.

3. Unless otherwise agreed by husband and wife or prescribed by law, obligations related to separate property already merged into common property shall be performed with common property.

**Article 47.** Agreement on establishment of the matrimonial property regime For a married couple that selects the agreed property regime, this agreement shall be made in writing before their marriage and be notarized or certified. The agreed matrimonial property regime shall be established on the date of marriage registration.

**Article 48.** Basic contents of an agreement on the matrimonial property regime

1. The basic contents of an agreement on the property regime include

a/ Property determined as common property and separate property of the husband and wife;
b/ Rights and obligations of the husband and wife toward common property, separate property and related transactions; property to meet the family's essential needs;
c/ Conditions, procedures and principles of property division upon termination of the property regime;
d/ Other related contents.
2. For matters arising in the implementation of the agreed property regime which have not been agreed or unclearly agreed by husband and wife, Articles 29, 30, 31 and 32 of this Law and corresponding provisions of the statutory property regime shall apply.

**Article 49.** Modification of the agreement on the matrimonial property regime

1. Husband and wife have the right to modify their agreement on the property regime.
2. The form of modification of the agreement on the property regime must comply with Article 47 of this Law.

**Article 50.** Invalidated agreement on the matrimonial property regime

1. An agreement on the matrimonial property regime shall be declared to be invalid by a court when:
a/ It fails to meet the conditions on effect of transactions prescribed the Civil Code and other relevant laws;
b/ It violates Article 29, 30, 31 or 32 of this Law;
c/ Its contents seriously infringe upon the rights to be supported and inherit and other lawful rights and interests of parents, children and other family members.
2. The Supreme People's Court shall assume the prime responsibility for, and coordinate with the Supreme People's Procuracy and the Ministry of Justice in, guiding Clause 1 of this Article.

# ឧបសម្ព័ន្ធទី ២

# ក្រមរដ្ឋប្បវេណី និង ពាណិជ្ជកម្ម

# ព្រះរាជាណាចក្រថៃ

( ឆ្នាំ ១៩២៥ )

# CHAPTER IV

## PROPERTY OF HUSBAND AND WIFE

**Section 1465** . Where the husband and wife have not, previous to their marriage, concluded a special agreement concerning their properties, the relations between them as regards to their properties shall be governed by the provisions of this Chapter.

Any clause in the anti-nuptial (also called prenuptial) agreement contrary to public order or good morals, or provided that the relations between them as regards such properties are to be governed by foreign law shall be void.

**Section 1466** . The ante-nuptial agreement is void if not entered in the Marriage Register at the time of marriage registration terms of the ante-nuptial; or if not made in writing and signed by both spouses and by at least two witnesses and entered in the Marriage Register at the time of marriage registration stating that the ante-nuptial is thereto annexed.

**Section 1467** . After marriage the ante-nuptial agreement cannot be altered except by authorization of the Court.

When there is a final order of the Court to effect the alteration of cancellation of the ante-nuptial agreement, the Court shall notify the Marriage Registrar of the matter in order to have it entered in the Marriage Register.

**Section 1468** . Clauses in the ante-prenuptial agreement shall have no effect as regards the rights of third persons acting in good faith irrespective of whether they be altered or canceled by the order of the Court.

**Section 1469** . Any agreement concluded between husband and wife during marriage may be avoided by either of them at any time during marriage or within one year from the day of dissolution of marriage; provided that the right of third persons acting in good faith are not affected thereby.

# ឧបសម្ព័ន្ធទី ៣

# ក្រមរដ្ឋប្បវេណី

# សាធារណៈរដ្ឋបារាំង

# ឆ្នាំ ១៨០៤

## TITLE V
## OF ANTE-NUPTIAL AGREEMENTS AND OF MATRIMONIAL REGIMES
### CHAPTER I
### General Provisions Articles

Art. 1387

Legislation regulates conjugal association, with respect to property, only in default of special agreements, which the spouses may enter into as they deem proper, provided they are not contrary to public morals and to the following provisions.

Art. 1388

Spouses may derogate neither to the duties and rights which result for them from marriage, nor to the rules of parental authority, statutory administration and guardianship.

Art. 1389

Without prejudice to gratuitous transfers which may take place according to the forms and in the cases provided for by this Code, spouses may not make any agreement or waiver whose object would be to change the statutory order of successions.

Art. 1390

They may, however, stipulate that, at the dissolution of the marriage by the death of one of them, the survivor will have the power to acquire or, should the occasion arise, to have allotted to him or her certain personal property of the first to die, on condition that he or she accounts for it to the succession, according to the value which they have on the day when that power is exercised.

Art. 1391

An ante-nuptial agreement shall determine the property to which the power granted to the survivor will relate. It may fix methods of appraisal and terms of payment, except abatement in favour of beneficiary heirs where there is an indirect advantage. Taking into account those clauses and failing an agreement between the parties, the value of the property shall be fixed by the tribunal de grande instance.

Art. 1394

All matrimonial agreements shall be drawn up in an instrument before notaire, in the presence and with the simultaneous consent of all the persons who are parties thereto or of their agents. At the time of the signature of the agreement, the notaire shall deliver to the parties a certificate on unstamped paper and without costs, stating his name and place of residence, the names, first names, occupations and residences of the future spouses, as well as the date of the ante-nuptial agreement . That certificate shall state that it must be lodged with the officer of civil status before the celebration of the marriage. Where the record of marriage mentions that an ante-nuptial agreement was not made, the spouses shall be, with regard to third parties, deemed married under the regime of general law, unless, in the transactions

entered into with those third parties, they have declared that they made an ante-nuptial agreement.

[repealed by Ord. no 2005-428 of 6 May 2005]

Art. 1395

An ante-nuptial agreement must be drawn up before the celebration of the marriage and may take effect only on the day of that celebration.

Art. 1396

Amendments made in ante-nuptial agreements before the celebration of the marriage must be established by an instrument drawn up in the same forms. Furthermore, no change or counter-letter is valid without the presence and the simultaneous consent of all the persons who were parties to the ante-nuptial agreement, or of their agents. Any amendments or counter-letters, even provided with the forms prescribed by the preceding Article, shall be without effect with respect to third parties, unless they were drawn up at the end of the original of the ante-nuptial agreement; and a notaire may deliver neither an executory nor an office copy of the ante-nuptial agreement without

transcribing the amendment or counter-letter at the end. After the celebration of the marriage, there may be no amendment to the matrimonial regime except by the effect o a judgment, either on the application of one of the spouses, in the case of separation of property or of other judicial protective measures, or on joint petition of both spouses, in the case of the following article.

Art. 1397

After two years of application of a matrimonial regime, either conventional or statutory, the spouses may agree in the interest of the family to amend it or even to change it entirely, by a notarial instrument, which shall be submitted to the approval of the court of their domicile. All persons who were parties to the modified agreement shall be summoned in the proceedings in approval; but not their heirs, if they have died. An approved change has effect between the parties from the judgment and, with regard to third parties, three months after mention of it has been entered in the margin of both copies of the record of marriage. However, even failing that mention, an amendment is effective against third parties where, in the transactions entered into with them, the spouses have declared that they have amended their matrimonial regime; Mention of the judgment of approval shall be made on the original of the amended ante-nuptial agreement. The application and the decision of approval shall be published on the terms and subject to the penalties provided for in the Code of Civil Procedure [...]. Where there has been a fraud on their rights, creditors may resort to a third party application for revocation of the judgment of approval in the way provided for in the Code of Civil Procedure.

Art. 1397-1

(Act no 75-617 of 11 July 1975).-The provisions of the preceding Article shall not apply to the agreements entered into by spouses in the course of divorce proceedings with the view of liquidating their matrimonial regime.

Articles 1450 and"265-2" (Act no 2004-439 of 26 May 2004) shall apply to those agreements.

Art. 1397-2

(Act no 97-987 of 28 Oct. 1997)

Where spouses specify the law applicable to their matrimonial regime under the Convention on the law applicable to matrimonial regimes, made in The Hague on 14 March 1978, Articles 1397-3 and 1397-4 shall apply.

Art. 1397-3

(Act no 97-987 of 28 Oct. 1997)

Where the specification of the applicable law is made before the marriage, the future spouses shall present to the officer of civil status either the instrument through which they have operated that specification, or a certificate delivered by the competent person to establish that instrument. A certificate shall state the names and first names of the future spouses, the place where they are living, the date of the instrument of specification, as well as the names, qualifications and residence of the person who has established it. Where the specification of the applicable law is made in the course of a marriage, the spouses shall have the measures or public notice relating to the specification of the applicable law made subject to the conditions and forms provided for in the new Code of Civil Procedure. On the occasion of the specification of the applicable law, before the marriage or in its course, the spouses may specify the nature of the matrimonial regime they choose.

[repealed by Ord. no 2005-428 of 6 May 2005]

Art. 1397-4

(Act no 97-987 of 28 Oct. 1997)

Where the specification of the applicable law is made in the course of a marriage, that specification takes effect between the parties from the establishment of the instrument of specification and, with respect to third parties, three months after the formalities of public notice provided for in Article 1397-3 have been fulfilled. However, even failing fulfilment of those formalities, the specification of the applicable law is effective against third parties where, in the transactions entered into with them, the spouses have declared which law is applicable to their matrimonial regime.

Art. 1397-5

(Act no 97-987 of 28 Oct. 1997)

Where a change in the matrimonial regime takes place in accordance with a foreign law which governs the effects of the marriage, the spouses shall have public notice made as provided for in the new Code of Civil Procedure.

Art. 1397-6

(Act no 97-987 of 28 Oct. 1997)

A change of matrimonial regime takes effect between the parties from the judgment or from the instrument which provides for it and, with respect to third parties, three months after the formalities of notice provided for in Article 1397-5 have been fulfilled. However, even failing fulfilment of those formalities, the change of matrimonial regime is effective against third parties where, in the transactions entered into with them, the spouses have declared that they have amended their matrimonial regime.

Art. 1398

A minor having capacity to contract marriage has capacity to consent to all the agreements of which that contract is susceptible and the agreements and gifts he has made therein are valid, provided he had, in making the agreement, the assistance of all the persons whose consent is necessary for the validity of the marriage. Where matrimonial conventions minor or by the persons whose consent was required, but only up to the expiry of the year following the coming of age.

Art. 1399

An adult in guardianship or curatorship may not enter into matrimonial conventions unless assisted, at the contract, by those who must consent to his marriage. Failing that assistance, annulment of the agreements may be sought within the year of the marriage, either by the person under a disability himself, or by those whose consent was required, or by the guardian or the curator.

# ឧបសម្ព័ន្ធទី៤

# ប្រកាសស្តីពី នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ ៨កយ.ប្រក/១៣ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ( JICA )
ប្រចាំក្រសួងយុត្តិធម៌

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

# ប្រកាស

# ស្តីពី

# នីតិវិធីនៃការចុះបញ្ជី

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រៀបចំដោយ
ក្រុមការងារក្រសួងយុត្តិធម៌
និង
ទីប្រឹក្សាផ្នែកច្បាប់របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
ប្រចាំក្រសួងយុត្តិធម៌
p

ក្រសួងយុត្តិធម៌
បោះពុម្ពលើកទីមួយ ចំនួន ៥០០ ក្បាល
នៅរាជធានីភ្នំពេញ ខែ កុម្ភៈ ឆ្នាំ ២០១៤

ប្រកាស ស្ដីពី
នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ
ដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ (ដំណាក់កាលទី ៤)
នៅក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ ២០១៤

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ
គឺជាគម្រោងសហប្រតិបត្តិការបច្ចេកទេស
រវាង
ក្រសួងយុត្តិធម៌
និង
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

### ចំណាប់អារម្មណ៍របស់
### ឯកឧត្តម អង្គ វង្សវឌ្ឍនា
### រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង និងមោទនភាពខ្ពស់ដោយក្រសួងយុត្តិធម៌ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលជាច្រើនជាបន្តបន្ទាប់រួមមានៈ បញ្ញត្តិមូលដ្ឋាន បញ្ញត្តិបន្ទាប់បន្សំ និងបញ្ញត្តិពិសេស ដែលបទប្បញ្ញត្តិទាំងនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងការរស់នៅក្នុងសង្គម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

ជាមួយគ្នានេះដែរ នៅក្នុងទំនាក់ទំនងរវាង បុគ្គល និងបុគ្គល ដែលបានរៀបអាពាហ៍ពិពាហ៍ និងបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមាននូវធនធានទ្រព្យសម្បត្តិជាចលនវត្ថុក្តី ជាអចលនវត្ថុក្តី គប្បីបញ្ជាក់ឲ្យបានច្បាស់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិនោះ ថាតើធនធានទ្រព្យសម្បត្តិណាខ្លះជាសិទ្ធិរួម ? ហើយធនធានទ្រព្យសម្បត្តិណាខ្លះ ជាសិទ្ធិផ្តាច់មុខរបស់ភាគីណាមួយ ?

ករណីនេះ នៅប្រទេសជឿនលឿនមួយចំនួន ដើម្បីបើកឱកាសឲ្យភាគីអាចកំណត់ឲ្យបានច្បាស់លាស់នូវទំនាក់ទំនងទ្រព្យសម្បត្តិទាំងនោះ និងងាយស្រួលដល់ការដោះស្រាយវិវាទទៅលើទំនាក់ទំនងទ្រព្យសម្បត្តិ គេបានរៀបចំឲ្យមានបទប្បញ្ញត្តិ ដែលទាក់ទងទៅនឹង ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ។

ទស្សនៈនៃគោលគំនិត ក្នុងការកំណត់នូវទំនាក់ទំនងនៃទ្រព្យសម្បត្តិនេះ ក៏ត្រូវបានយកមកបញ្ចូលនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយបានអនុវត្តកាលពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ កន្លងមកនេះ ។

នៅក្នុងមាត្រា ៩៦៩ នៃក្រមរដ្ឋប្បវេណីបានចែងថា ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ឲ្យតែមិនផ្ទុយនឹងសិទ្ធិទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង ។ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាពិសេស ចំពោះទ្រព្យសម្បត្តិនោះទេ នោះត្រូវអនុលោមតាមប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។ p

រីឯមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានប្រគល់សមត្ថកិច្ចឲ្យក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយក្រសួងត្រូវរៀបចំកំណត់អំពី បែបបទ និងទម្រង់ នៃការចុះបញ្ជីតាមរយៈប្រកាសរបស់ក្រសួង ។

ផ្អែកតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌បានបង្កើតក្រុមការងារមួយ ដោយសហការ ជាមួយជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ដើម្បីរៀបចំ បែបបទ និងទម្រង់ នៃការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយប្រើប្រព័ន្ធចុះបញ្ជីដែលរៀបចំឡើងដោយប្រើក្រដាសដាក់ក្នុងក្រេណូ ។

ជាមួយនឹងការអបអរសាទរនៃភាពជោគជ័យ របស់ក្រុមការងារក្នុងការរៀបចំប្រកាសនេះ ខ្ញុំក៏សូមធ្វើការវាយតម្លៃខ្ពស់ កោតសរសើរ និងសូមថ្លែងអំណរគុណ ដោយស្មោះអស់ពីចិត្ត ចំពោះស្មារតីទទួលខុសត្រូវខ្ពស់បំផុត និងការខិតខំប្រឹងប្រែង ការព្យាយាម យកអស់ពីកំលាំងកាយ និងបញ្ញាស្មារតី របស់ក្រុមការងារ និងជំនាញការជប៉ុននៃអង្គការ JICA ប្រចាំក្រសួងយុត្តិធម៌ ។ ជាពិសេស ក្រុមការងារសាស្ត្រាចារ្យជប៉ុន ដែលបានចូលរួម ប្រឹក្សាយោបល់ នៅក្នុងការរៀបចំ បទប្បញ្ញត្តិគតិយុត្តដ៏មានសារៈសំខាន់នេះ ហើយក៏ជាផ្នែកមួយនៃការអភិវឌ្ឍន៍វិស័យច្បាប់ ស្របតាមគោលនយោបាយ ស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ជំហានបន្ទាប់ ក្រសួងយុត្តិធម៌ក៏បានកំណត់ទិសដៅឱ្យ ក្រុមការងារដែលបានរៀបចំប្រកាសនេះ ត្រូវធ្វើការបណ្តុះបណ្តាល និង ផ្សព្វផ្សាយប្រកាសនេះ ឱ្យបានទូលំទូលាយទៅដល់មន្ត្រីអនុវត្តច្បាប់និងប្រជាពលរដ្ឋទូទៅ ។

ក្រសួងយុត្តិធម៌មានជំនឿយ៉ាងមុតមាំថា ប្រកាសនេះនឹងក្លាយជាឧបករណ៍គតិយុត្តដ៏សំខាន់ ដែលផ្តល់សិទ្ធិ និងបើកឱកាស ឱ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមានបំណងចង់ធ្វើការចុះបញ្ជី អាចធ្វើការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ហើយឈានទៅដល់ការបង្កើតទំនាក់ទំនងរវាង បុរស និងស្ត្រី ឱ្យមានភាពច្បាស់លាស់ និងតម្លាភាព ពាក់ព័ន្ធនឹងបញ្ហាទ្រព្យសម្បត្តិ និងចូលរួមចំណែកក្នុងការពង្រឹងគោលការណ៍សមភាពយេនឌ័រនៅក្នុងសង្គម ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

p

**អង្គ វង្សវឌ្ឍនា**

## ប្រធានក្រុមការងារតាក់តែងច្បាប់

ឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សមាសភាពក្រុមការងារក្រសួងយុត្តិធម៌ដែលទទួលបន្ទុកតាក់តែងប្រកាសស្តីពី "ការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ"

| | | |
|---|---|---|
| លោកជំទាវ | **ចាន់ សុទ្ធាវី** | រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ (ប្រធាន) |
| ឯកឧត្តម | **ឃាន ស៊ីណា** | អតីតអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ |
| លោក | **និត្យ ឬទ្ធី** | ចៅក្រមនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ម៉ៅ តិរុណា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| លោកស្រី | **សួរ ដានី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងយុត្តិធម៌ |
| លោក | **ទូច ថារិទ្ធ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **កែវ សេដ្ឋា** | អតីតអនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **ហុក ច័ន្ទសុវណ្ណារ៉ា** | អនុប្រធានការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | **អុល ធីរៈ** | អនុប្រធានការិយាល័យកិច្ចការអយ្យការនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **ឡាយ លីនណា** | អនុប្រធានការិយាល័យបច្ចេកទេសនៃក្រសួងយុត្តិធម៌ |
| កញ្ញា | **សួន ណារី** | មន្ត្រីគ្រប់គ្រងរដ្ឋបាលនៃក្រសួងយុត្តិធម៌ |

## ជំនាញការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំក្រសួងយុត្តិធម៌

| | | |
|---|---|---|
| លោក | Issei SAKANO | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Hiroshi KIYOHARA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | Masayoshi HARADA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Emiko KANETAKE | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Ayako TAMIYA | អតីតទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោកស្រី | Miha ISOI | ទីប្រឹក្សាច្បាប់នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

## សមាសភាពសាស្ត្រាចារ្យជប៉ុនដែលបានប្រឹក្សាយោបល់ក្នុងការរៀបចំប្រកាស

| | | |
|---|---|---|
| លោក | Akio MORISHIMA | សាស្ត្រាចារ្យកិត្តិយសនៃសាកលវិទ្យាល័យ Nagoya (ប្រធាន) |
| លោក | Ikufumi NIIMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Meiji |
| លោក | Michitaro URAKAWA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Kaoru KAMATA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Yutaka YAMAMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Kyoto |
| លោក | Tsuneo MATSUMOTO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Hitotsubashi |
| លោក | Yoshihisa NOMI | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushuin |

| | | |
|---|---|---|
| លោក | Toshifumi MINAMI | អតីតចៅក្រមសាលាឧទ្ធរណ៍នៃទីក្រុងតូក្យូ |
| លោក | Toyohiro NOMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Gakushu-in |
| លោក | Masayuki TANAMURA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Waseda |
| លោក | Keita SATO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Chuo |
| លោក | Atsushi MOTOYAMA | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Ritsumeikan |
| លោក | Hiroshi MATSUO | សាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Keio |
| លោក | Hisaya HATANAKA | ជំនួយការសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ Fukuoka |
| លោក | Keisuke ENDO | មន្ត្រីនៃការិយាល័យកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ |
| លោក | Kazuo UESAKA | សាស្ត្រាចារ្យនៃនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិនៃក្រសួងយុត្តិធម៌ |

## សមាសភាពលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាយោបល់

| | | |
|---|---|---|
| លោក | Atsuhito YOSHIMOTO | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |
| លោក | Hisashi NAGAYA | អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលច្បាប់រដ្ឋប្បវេណី និងពាណិជ្ជកម្មអន្តរជាតិ |

**អ្នកបកប្រែ** :

| | | |
|---|---|---|
| លោក | **គឹម ពេជ្រជា** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែវ ពិសី** | អតីតជំនួយការ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **កែវ ម៉ាន្នី** | អតីតមន្ត្រីច្បាប់ជាន់ខ្ពស់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ឡៀប សុខសិរីយស** | អតីតជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **ខែម ណារ័ត្ន** | មន្ត្រីច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| លោក | **សោម រតនា** | ជំនួយការផ្នែកច្បាប់ នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |
| កញ្ញា | **ស៊ី ច័ន្ទជីវ៉ា** | ជំនួយការរដ្ឋបាល នៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ |

## ប្រកាស
## ស្តីពី
## នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ជំពូកទី ១- បទប្បញ្ញត្តិទូទៅ**

ប្រការ ១ - គោលដៅ ........ ២

ប្រការ ២ - គោលបំណង ........ ២

ប្រការ ៣ - វិសាលភាព ........ ២

**ជំពូកទី ២- សមត្ថកិច្ចចុះបញ្ជី**

ប្រការ ៤ - ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី ........ ២

**ជំពូកទី ៣- ការបង្កើត ការគ្រប់គ្រងក្រូណូ និងអំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូ**

**ផ្នែកទី ១- ការបង្កើតក្រូណូ**

ប្រការ ៥ - ការបង្កើតក្រូណូ ........ ៣

ប្រការ ៦ - ក្រូណូទទួលពាក្យសុំ ........ ៣

ប្រការ ៧ - ក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៤

ប្រការ ៨ - ក្រូណូសម្រាក់ដាក់ឯកសារពាក្យសុំ ........ ៤

ប្រការ ៩ - ក្រូណូលើកចោល ........ ៤

ប្រការ ១០ - ក្រូណូសម្រាក់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ........ ៤

ប្រការ ១១ - ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ........ ៤

**ផ្នែកទី ២- ការគ្រប់គ្រងក្រូណូ**

ប្រការ ១២ - ការគ្រប់គ្រងក្រូណូ ........ ៥

**ផ្នែកទី ៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូ**

ប្រការ ១៣ - ការរក្សាទុកឯកសារក្នុងក្រូណូទទួលពាក្យសុំ និងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ........ ៥

ប្រការ ១៤ - អំឡុងពេលរក្សាទុកឯកសារក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំ ក្រូណូលើកចោល ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ........ ៥

**ជំពូកទី ៤- បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី**

ប្រការ ១៥ - ពាក្យសុំចុះបញ្ជី ........ ៥

ប្រការ ១៦ - ទម្រង់នៃពាក្យសុំចុះបញ្ជី ........ ៦

ប្រការ ១៧ - ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី ........ ៦

ប្រការ ១៨ - ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ ..... ៧

**ជំពូកទី ៥- ពាក្យសុំចុះបញ្ជី**

ប្រការ ១៩ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..... ៧
ប្រការ ២០ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..... ៨
ប្រការ ២១ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..... ៨
ប្រការ ២២ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ រំលាយអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ ..... ៩
ប្រការ ២៣ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..... ១០
ប្រការ ២៤ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ សហព័ទ្ធណាម្នាក់បានស្លាប់ ..... ១០
ប្រការ ២៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើ សាលក្រម ឬ សាលដីកាស្ថាពរ រំលាយអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ ..... ១១
ប្រការ ២៦ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តី សម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែល មិនមែនជាបណ្តឹង ..... ១១
ប្រការ ២៧ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាម សាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្ត ក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ..... ១២
ប្រការ ២៨ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ..... ១២

**ជំពូកទី ៦- ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឱ្យពិនិត្យឡើងវិញ**

ប្រការ ២៩ - ការទទួលពាក្យសុំចុះបញ្ជី ..... ១៣
ប្រការ ៣០ - ការដកពាក្យសុំចុះបញ្ជី ..... ១៣
ប្រការ ៣១ - ការពិនិត្យពាក្យសុំចុះបញ្ជី ..... ១៣
ប្រការ ៣២ - ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី ..... ១៣
ប្រការ ៣៣ - ការប្រគល់ឯកសារភ្ជាប់ឲ្យវិញ ..... ១៤
ប្រការ ៣៤ - ពាក្យសុំឲ្យពិនិត្យឡើងវិញចំពោះការលើកចោលរបស់មន្ត្រីចុះបញ្ជី ..... ១៤
ប្រការ ៣៥ - ចំណុចដែលត្រូវចុះបញ្ជីក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ..... ១៤
ប្រការ ៣៦ - អានុភាពនៃការចុះបញ្ជី ..... ១៤

**ជំពូកទី ៧- របៀបចុះបញ្ជី និងចងក្រងទុកក្នុងក្រុណា**

ប្រការ ៣៧ - របៀបចុះបញ្ជីក្នុងក្រណ្ឌទទួលពាក្យសុំ ..... ១៥

ប្រការ ៣៨ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......១៥
ប្រការ ៣៩ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......១៥
ប្រការ ៤០ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......១៦
ប្រការ ៤១ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ.១៦
ប្រការ ៤២ - របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍......១៦
ប្រការ ៤៣ - វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......១៧
ប្រការ ៤៤ - របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ......១៧
ប្រការ ៤៥ - របៀបចងក្រងរក្សាទុកក្នុងក្រូណូលើកចោល......១៧
ប្រការ ៤៦ - របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ......១៧
ប្រការ ៤៧ - របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី....១៨

**ជំពូកទី ៨- នីតិវិធីនៃការចេញលិខិតបញ្ជាក់**

ប្រការ ៤៨ - របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់......១៨
ប្រការ ៤៩ - ការចេញលិខិតបញ្ជាក់......១៨

**ជំពូកទី ៩- អវសានប្បញ្ញត្តិ**

ប្រការ ៥០ - កាលបរិច្ឆេទ នៃការអនុវត្ត......១៩

ឧបសម្ព័ន្ធទី ១ - ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......២០
ឧបសម្ព័ន្ធទី ២ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......២១
ឧបសម្ព័ន្ធទី ៣ - ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋាន......២២
ឧបសម្ព័ន្ធទី ៤ - ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......២៣
ឧបសម្ព័ន្ធទី ៥ - ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......២៤
ឧបសម្ព័ន្ធទី ៦ - ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍......២៥
ឧបសម្ព័ន្ធទី ៧ - ពាក្យសុំឲ្យចេញលិខិតបញ្ជាក់......២៦
ឧបសម្ព័ន្ធទី ៨ - សន្លឹកក្រដាសទទួលពាក្យសុំ......២៧
ឧបសម្ព័ន្ធទី ៩ - សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......២៨
ឧបសម្ព័ន្ធទី ១០ - សន្លឹកចុះបញ្ជីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ......២៩
គំរូចុះបញ្ជី ១ - សន្លឹកក្រដាសទទួលពាក្យសុំ......៣០
គំរូចុះបញ្ជី ២ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី)......៣១
គំរូចុះបញ្ជី ៣ - ការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា)......៣២
គំរូចុះបញ្ជី ៤ - ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី)......៣៤
គំរូចុះបញ្ជី ៥ - ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា)......៣៥
គំរូចុះបញ្ជី ៦ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី)......៣៧

គំរូចុះបញ្ជី ៧ - ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (សន្លឹកចុះបញ្ជី) (វិធីកត់ត្រា) ........ ៣៨
គំរូចុះបញ្ជី ៨ - ការផ្លាស់ប្ដូរឈ្មោះ ឬ អាសយដ្ឋានជាអាទិ៍ (សន្លឹកចុះបញ្ជី)........................................ ៣៩


p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ៤៧.ភ.ឃ.ប្រក/១៣

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 023 2 7 841

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការចុះបញ្ជី កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ : គោលដៅ**

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដែលបង្កើតអានុភាពរវាងបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ឲ្យបានត្រឹមត្រូវតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

**ប្រការ ២ : គោលបំណង**

គោលបំណងនៃប្រកាសនេះ គឺអនុញ្ញាតឲ្យប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចធ្វើការចុះបញ្ជីកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយការរៀបអាពាហ៍ពិពាហ៍បាន ដើម្បីកំណត់ឲ្យបានច្បាស់លាស់ អំពីទំនាក់ទំនងទ្រព្យសម្បត្តិប្តីប្រពន្ធ។

**ប្រការ ៣ : វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តទៅលើចំណុច ដូចខាងក្រោម ៖

- ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- នីតិវិធីនៃការចេញលិខិតបញ្ជាក់។

## ជំពូកទី ២
## សមត្ថកិច្ចចុះបញ្ជី

**ប្រការ ៤ : ស្ថាប័នមានសមត្ថកិច្ចលើការចុះបញ្ជី**

១- នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ មានសមត្ថកិច្ចលើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

២- មន្ត្រីដែលទទួលបន្ទុកកិច្ចការដែលទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ (មន្ត្រីចុះបញ្ជី) ត្រូវនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

៣- ក្រណ្ឌទាក់ទងនឹងការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវរក្សាទុកនៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ។

## ជំពូកទី ៣
## ការបង្កើត ការគ្រប់គ្រងក្រណ្ឌ និងរយៈពេលរក្សាទុកឯកសារក្នុងក្រណ្ឌ
### ផ្នែកទី ១
### ការបង្កើតក្រណ្ឌ

**ប្រការ ៥ : ការបង្កើតក្រណ្ឌ**

នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ត្រូវបង្កើតក្រណ្ឌ ដូចខាងក្រោម ៖

១. ក្រណ្ឌទទួលពាក្យសុំ

២. ក្រណ្ឌចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

៣. ក្រណ្ឌសម្រាប់ដាក់ឯកសារពាក្យសុំ

៤. ក្រណ្ឌលើកចោល

៥. ក្រណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ

៦. ក្រណ្ឌសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

**ប្រការ ៦ : ក្រណ្ឌទទួលពាក្យសុំ**

១- ក្រណ្ឌទទួលពាក្យសុំ គឺជាក្រណ្ឌសម្រាប់ចុះព័ត៌មាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ និងចុះលេខទទួលពាក្យសុំនៅលើពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ និងពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

២- សន្លឹកក្រដាសទទួលពាក្យសុំ ដែលដាក់ក្នុងក្រណ្ឌ ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខរៀងទទួលពាក្យ
- កាលបរិច្ឆេទ នៃការទទួលពាក្យ
- ប្រភេទ នៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ
- ជាប្តីប្រពន្ធ
- បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន)
- ផ្សេងៗ

## ប្រការ ៧ : ក្រុណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១- ក្រុណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ គឺជាក្រុណាសម្រាប់ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

២- សន្លឹកចុះបញ្ជី ដែលដាក់ក្នុងក្រុណា ត្រូវមានតារាងបែងចែកខ្ទង់ ដូចខាងក្រោមនេះ ៖

- លេខចុះបញ្ជី និង លេខទទួលពាក្យសុំ
- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណង និងមូលហេតុនៃការចុះបញ្ជី
- ខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- ការលុបការចុះបញ្ជី អំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

## ប្រការ ៨ : ក្រុណាសម្រាប់ដាក់ឯកសារពាក្យសុំ

ក្រុណាសម្រាប់ដាក់ឯកសារពាក្យសុំ គឺជាក្រុណាសម្រាប់ដាក់ពាក្យសុំចុះបញ្ជី និងឯកសារភ្ជាប់ដែលមន្ត្រីចុះបញ្ជីបានទទួលពីអ្នកដាក់ពាក្យសុំ ។

## ប្រការ ៩ : ក្រុណាលើកចោល

ក្រុណាលើកចោល គឺជាក្រុណាសម្រាប់ដាក់លិខិតលើកចោលពាក្យសុំចុះបញ្ជីរបស់មន្ត្រីចុះបញ្ជី។

## ប្រការ ១០ : ក្រុណាសម្រាប់ដាក់ពាក្យសុំឱ្យពិនិត្យឡើងវិញ

ក្រុណាសម្រាប់ដាក់ពាក្យសុំឱ្យពិនិត្យឡើងវិញ គឺជាក្រុណាសម្រាប់ដាក់ពាក្យសុំឱ្យពិនិត្យឡើងវិញ ព្រមទាំងដាក់សេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកសារដែលភ្ជាប់មកជាមួយ ។

## ប្រការ ១១ : ក្រុណាសម្រាប់ដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី

ក្រុណាសម្រាប់ដាក់ពាក្យសុំឱ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី គឺជាក្រុណាសម្រាប់ដាក់ពាក្យសុំឱ្យធ្វើការបញ្ជាក់ ចំពោះចំណុចដែលបានចុះ ឬ មិនបានចុះនៅក្នុងបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ។

p

## ផ្នែកទី ២
## ការគ្រប់គ្រងក្រុណា

ប្រការ ១២ : ការគ្រប់គ្រងក្រុណា

ក្រុណា គឺត្រូវគ្រប់គ្រង និងរក្សាទុកនៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ ។

## ផ្នែកទី ៣
## អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណា

ប្រការ ១៣ : **ការរក្សាទុកឯកសារក្នុងក្រុណាទទួលពាក្យសុំ និងក្រុណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ**

ឯកសារក្នុងក្រុណាទទួលពាក្យសុំ និងក្រុណាចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវរក្សាទុកជានិរន្តរ៍ ។

ប្រការ ១៤ : **អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ឯកសារពាក្យសុំ ក្រុណាលើកចោល ក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

១- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ឯកសារពាក្យសុំ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំ ។

២- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាលើកចោល មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតលើកចោល ។

៣- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ។

៤- អំឡុងពេលរក្សាទុកឯកសារក្នុងក្រុណាសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មានរយៈពេល ១០ ឆ្នាំ គិតចាប់ពីថ្ងៃដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ។

## ជំពូកទី ៤
## បទប្បញ្ញត្តិទូទៅ នៃពាក្យសុំចុះបញ្ជី

ប្រការ ១៥ : **ពាក្យសុំចុះបញ្ជី**

១- រាល់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ពាក្យសុំច្បាប់ដើម ត្រូវមានហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ដោយភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងនៃច្បាប់ដើមនោះ ។

២- ជាគោលការណ៍ ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវធ្វើឡើងរួមគ្នា។ លើកលែងតែករណីដូចខាងក្រោម អាចដាក់ពាក្យសុំតែម្នាក់ឯងបាន ៖

ក. ការផ្លាស់ប្ដូរ ឬ ការកែតម្រូវតែ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

ខ. ការចុះបញ្ជី ដោយផ្អែកលើសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចស្ថាពរ ប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ដូចមានចែងនៅក្នុងមាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ខ, គ, ឃ នៃច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី។

៣- រាល់ពាក្យសុំចុះបញ្ជីខាងលើ អ្នកតំណាងក៏អាចកាន់យកមកដាក់នៅ ចំពោះមុខមន្ត្រីចុះបញ្ជីជំនួសប្ដីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានដែរ ។

៤- បុគ្គល ឬ អ្នកតំណាង ដែលដាក់ពាក្យសុំចុះបញ្ជី ត្រូវយកពាក្យសុំនោះ មកដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី នៃក្រសួងយុត្តិធម៌ដោយផ្ទាល់ ។

## ប្រការ ១៦ : ទម្រង់នៃពាក្យសុំចុះបញ្ជី

១- ទម្រង់នៃពាក្យសុំចុះបញ្ជី ត្រូវសរសេរជាភាសានៃព្រះរាជាណាចក្រកម្ពុជា ពាក្យសុំចុះបញ្ជី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង (ប្រសិនបើមាន) ហើយត្រូវគោរពចូលមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ព្រមទាំងមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬ ស្នាមម្រាមដៃរបស់អ្នកដាក់ពាក្យសុំ ។

២- ក្រៅពីនេះ ត្រូវសរសេរបន្ថែមនូវចំណុចមួយចំនួនទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ។

## ប្រការ ១៧ : ឯកសារភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី

១- នៅពេលដាក់ពាក្យសុំចុះបញ្ជី អ្នកដាក់ពាក្យសុំចុះបញ្ជីទាក់ទងនឹងកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ជាអាទិ៍) ដូចមានចែងក្នុងជំពូកទី ៥ (ពាក្យសុំចុះបញ្ជី) នៃប្រកាសនេះ ត្រូវផ្ដល់ឯកសារចាំបាច់មួយចំនួនទៅឲ្យនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ទៅតាមប្រភេទនៃពាក្យសុំចុះបញ្ជីនោះ ។

២- ចំពោះពាក្យសុំចុះបញ្ជី ដែលអ្នកតំណាងយកមកដាក់ ដូចមានចែងក្នុងប្រការ ១៥ កថាខណ្ឌទី៣ ត្រូវភ្ជាប់លិខិតប្រគល់សិទ្ធិតំណាងផងដែរ ។

**ប្រការ ១៨ : ការប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់**

១- ចំពោះឯកសារដែលភ្ជាប់ជាមួយនឹងពាក្យសុំ អ្នកដាក់ពាក្យសុំអាចទាមទារឲ្យប្រគល់វិញនៅពេលដាក់ពាក្យសុំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្ត ចំពោះលិខិតប្រគល់សិទ្ធិតំណាង ។

២- ដើម្បីទាមទារឲ្យប្រគល់ឯកសារភ្ជាប់ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំនោះ នូវឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ថា ការសរសេរនៅក្នុងឯកសារនោះគ្មានភាពខុសពីច្បាប់ដើម ។

៣- ក្នុងករណីដែលប្រគល់ច្បាប់ដើមនៃឯកសារភ្ជាប់ មន្ត្រីចុះបញ្ជីត្រូវឲ្យអ្នកទទួលការប្រគល់សរសេរនៅក្នុងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នូវករណី ដែលខ្លួនបានទទួលការប្រគល់ឯកសារនោះ និងចុះហត្ថលេខា ។

## ជំពូកទី ៥
## ពាក្យសុំចុះបញ្ជី

**ប្រការ ១៩ : ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើមានការបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា អាចដាក់ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធបាន ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទបង្កើតកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឃ- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ង- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍។

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍ ក្នុងករណីដែលអ្នកដាក់ពាក្យសុំបានរៀបអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ហាដីធ្លី
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២០ ៖ ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើមានការផ្លាស់ប្តូរនូវចំណុចដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃការផ្លាស់ប្តូរ)

ឃ- ចំណុចដែលត្រូវផ្លាស់ប្តូរ

- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- ឈ្មោះ ឬ អាសយដ្ឋានថ្មី

ឯកសារភ្ជាប់៖

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធថ្មី
- សាលក្រម ឬ ដីកាសម្រេចផ្លាស់ប្តូរ
- លិខិតបញ្ជាក់អំពីការផ្លាស់ប្តូរអាសយដ្ឋាន
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះពាក់ព័ន្ធនឹងបញ្ជាដីធ្លីក្រោយពេលមានការផ្លាស់ប្តូរ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២១ ៖ ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវ ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- នៅពេលកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានចុះបញ្ជីរួចហើយ បើពិនិត្យឃើញថាមានកំហុស ឬ ខកខានមិនបានចុះបញ្ជី ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ត្រូវដាក់ពាក្យសុំចុះបញ្ជីកែតម្រូវ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- គោលបំណង

p

ខ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទដែលបានកែតម្រូវ)

គ- ចំណុចដែលត្រូវកែតម្រូវ

- ឈ្មោះ
- អាសយដ្ឋាន

- ថ្ងៃ ខែ ឆ្នាំកំណើត
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឯកសារភ្ជាប់:

- កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- សំបុត្រអាពាហ៍ពិពាហ៍
- វិញ្ញាបនបត្របញ្ជាក់អំពីព័ត៌មានដែលបានចុះនៅក្នុងសៀវភៅចុះបញ្ជី (សៀវភៅចុះបញ្ជីអចលនវត្ថុ សៀវភៅគោលបញ្ជីដីធ្លី សៀវភៅចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍ សៀវភៅចុះបញ្ជីផលុបភោគ) ក្នុងករណីដែលកិច្ចសន្យានេះ ពាក់ព័ន្ធនឹងបញ្ជាដីធ្លីក្រោយពេលមានការកែតម្រូវ
- លិខិតបញ្ជាក់អាសយដ្ឋាន
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២២ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុលែងលះអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ**

១- ប្រសិនបើប្តីប្រពន្ធបានលែងលះអាពាហ៍ពិពាហ៍ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានលែងលះកំជាប់ពាក្យ ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទលែងលះអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ)

ឯកសារភ្ជាប់:

- ដីកាសម្រេច ដែលលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹងពីការលែងលះកំជាប់ពាក្យ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៣ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុមោឃភាព ការលុបចោល ឬ ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ប្រសិនបើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានចុះបញ្ជីរួច ត្រូវបានមោឃៈ រំលាយ ឬ លុបចោល ប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមោឃភាព, ការលុបចោល, ការរំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាស្ថាពរ ដែលបញ្ជាក់ថាកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវបានមោឃៈ លុបចោល ឬ រំលាយ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- កិច្ចព្រមព្រៀង ឬ ការជូនដំណឹង ដែលបញ្ជាក់ពីការលុបចោល ឬ រំលាយកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៤ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់**

១- ប្រសិនបើសហព័ទ្ធណាម្នាក់បានស្លាប់ ឬ ប្រសិនបើបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបានស្លាប់ សហព័ទ្ធដែលនៅរស់ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាដែលនៅរស់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី p

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃមរណភាព)

ឯកសារភ្ជាប់:

- សំបុត្រមរណភាព
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)

- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៥ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ លែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ**

១- ប្រសិនបើមានសេចក្តីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិក្នុងសាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ដែលបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ ត្រូវដាក់ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់:

- សាលក្រម ឬ សាលដីកាលែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៦ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**

១- ប្រសិនបើតុលាការសម្រេចសេចក្តី អំពីការបែងចែកទ្រព្យសម្បត្តិ ដោយការលែងលះអាពាហ៍ពិពាហ៍ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ អតីតសហព័ទ្ធណាម្នាក់ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក– ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ– គោលបំណងនៃការចុះបញ្ជី

គ– មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការ)

ឯកសារភ្ជាប់:

- ដីកាសម្រេចការបែងចែកទ្រព្យសម្បត្តិដោយការលែងលះអាពាហ៍ពិពាហ៍ ដែលបានចូលជាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃដីកាសម្រេច
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៧ : ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ**

១- នៅពេលមានសាលក្រម ឬ សាលដីកាស្ថាពរដែលកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំនុច ឃ ភាគីណាម្នាក់ ត្រូវដាក់ពាក្យសុំលុបការចុះបញ្ជី។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃសាលក្រម ឬ សាលដីកាស្ថាពរ)

ឯកសារភ្ជាប់៖

- សាលក្រម ឬ សាលដីកាស្ថាពរ
- លិខិតបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

**ប្រការ ២៨: ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

១- នៅពេលដែលបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា បានរៀបអាពាហ៍ពិពាហ៍ក្រោយពីបានធ្វើការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ បុគ្គលនោះត្រូវដាក់ពាក្យសុំចុះបញ្ជីបន្ថែមអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

២- ក្រៅពីចំណុចដូចមានចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ ១៦ (ទម្រង់នៃពាក្យសុំចុះបញ្ជី) ត្រូវសរសេរបន្ថែមនូវចំណុច ដូចខាងក្រោម ៖

ក- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា

ខ- គោលបំណងនៃការចុះបញ្ជី

គ- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឯកសារភ្ជាប់៖

- សំបុត្រអាពាហ៍ពិពាហ៍
- លិខិតប្រគល់សិទ្ធិតំណាង (ប្រសិនបើមាន)
- អត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន

## ជំពូកទី ៦
## ការទទួល ការពិនិត្យពាក្យសុំចុះបញ្ជី និងពាក្យសុំឲ្យពិនិត្យឡើងវិញ

### ប្រការ ២៩ : ការទទួលពាក្យសុំចុះបញ្ជី

នៅពេលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចុះនិទ្ទេសនៅលើពាក្យសុំនោះ នូវលេខរៀងទទួលពាក្យសុំ កាលបរិច្ឆេទ និងឈ្មោះនាយកដ្ឋានកិច្ចការផ្លូវរដ្ឋប្បវេណី ព្រមទាំងហត្ថលេខាបំពេញ និងឈ្មោះមន្ត្រីចុះបញ្ជីនោះ ។

### ប្រការ ៣០ : ការដកពាក្យសុំចុះបញ្ជី

ពាក្យសុំចុះបញ្ជីអាចដកបានមុនពេលការចុះបញ្ជីត្រូវបានបញ្ចប់ ដោយត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

### ប្រការ ៣១ : ការពិនិត្យពាក្យសុំចុះបញ្ជី

១- មន្ត្រីចុះបញ្ជី ត្រូវពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ ។

២- នៅពេលពិនិត្យពាក្យសុំ ដែលមានចែងនៅក្នុងកថាខណ្ឌទី១ ខាងលើនេះ បើមន្ត្រីចុះបញ្ជីមានវិមតិសង្ស័យនោះ មន្ត្រីចុះបញ្ជីអាចធ្វើការសាកសួរបន្ថែមទៅអ្នកដាក់ពាក្យសុំ ឬ អ្នកតំណាងនោះបាន ។

### ប្រការ ៣២ : ការកែតម្រូវ និងការលើកចោលពាក្យសុំចុះបញ្ជី

១- មន្ត្រីចុះបញ្ជី ត្រូវចេញលិខិតបង្គាប់ឲ្យកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំ ក្នុងករណីដែលមន្ត្រីចុះបញ្ជីពិនិត្យឃើញថា ពាក្យសុំចុះបញ្ជីធ្វើឡើងពុំត្រឹមត្រូវ ដោយមានមូលហេតុ ដូចខាងក្រោម ៖

- ព័ត៌មាន និងបែបបទក្នុងពាក្យសុំចុះបញ្ជីមិនស្របតាមប្រកាសនេះ
- ពុំបានផ្តល់ឯកសារដែលចាំបាច់
- ខ្លឹមសារនៅក្នុងពាក្យសុំ និងឯកសារភ្ជាប់មិនស្របគ្នា
- ពាក្យសុំចុះបញ្ជីនោះធ្លាប់បានដាក់ និងចុះបញ្ជីម្តងរួចមកហើយ
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំ មិនស្របគ្នាជាមួយនឹងការចុះបញ្ជី

# ជំពូកទី ៧
# របៀបចុះបញ្ជី និងរក្សាទុកក្នុងក្រូណូ

**ប្រការ ៣៧ : របៀបចុះបញ្ជីក្នុងក្រូណូទទួលពាក្យសុំ**

នៅពេលដែលមន្ត្រីចុះបញ្ជី បានទទួលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកក្រដាសទទួលពាក្យសុំនូវព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌទី២ ប្រការ ៦ នៃប្រកាសនេះ ។

**ប្រការ ៣៨ : របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីមន្ត្រីចុះបញ្ជីបានពិនិត្យពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ១៩ (ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) រួច មន្ត្រីចុះបញ្ជីត្រូវសរសេរចូលក្នុងសន្លឹកចុះបញ្ជីនូវចំណុចដូចខាងក្រោមនេះ ៖

- ឈ្មោះ អាសយដ្ឋាន និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ភាគីនៃកិច្ចសន្យា
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ បុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍
- គោលបំណងនៃការចុះបញ្ជី
- មូលហេតុ និងកាលបរិច្ឆេទ (កាលបរិច្ឆេទនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ)

២- ចំពោះសន្លឹកចុះបញ្ជីនៅក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះលេខចុះបញ្ជីផ្អែកលើលេខរៀងទទួលពាក្យសុំ ហើយចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណូ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៣៩ : របៀបចុះបញ្ជីក្នុងក្រូណូចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ ដែលបានកំណត់ក្នុងប្រការ ២០ (ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរ គោលបំណងនៃការចុះបញ្ជី មូលហេតុ និងកាលបរិច្ឆេទ ព្រមទាំងខ្លឹមសារនៃកិច្ចសន្យាទាំងអស់ឡើងវិញ នៅក្នុងសន្លឹក **"ផ្លាស់ប្តូរ"** ។

២- ចំពោះការផ្លាស់ប្តូរខ្លឹមសារកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា **"បានពិនិត្យរួច"** រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រូណូ ទៅតាមលំដាប់លេខចុះបញ្ជី។

៤- ចំពោះការផ្លាស់ប្តូរឈ្មោះ ឬ អាសយដ្ឋាន មន្ត្រីចុះបញ្ជីត្រូវសរសេរឈ្មោះ ឬ អាសយដ្ឋានថ្មី មូលហេតុនៃការផ្លាស់ប្តូរ និងកាលបរិច្ឆេទនៃការផ្លាស់ប្តូរ ចូលក្នុងសន្លឹកដែលបានចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចហើយ នៅក្នុងខ្ទង់ពាក់ព័ន្ធនឹង "ការផ្លាស់ប្តូរឈ្មោះ និង អាសយដ្ឋាន" រួចមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជីនោះ។

**ប្រការ ៤០ : របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

បញ្ញត្តិនៃប្រការ ៣៩ (របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) នៃប្រកាសនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការចុះបញ្ជីអំពីការកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ។

**ប្រការ ៤១ : របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២២ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយមូលហេតុ លែងលះអាពាហ៍ពិពាហ៍ ឬ កំជាប់ពាក្យ) ប្រការ ២៣ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុ មោឃភាព ការលុបចោល ឬ ការលែងកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ) ប្រការ ២៤ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយមូលហេតុសហព័ទ្ធណាម្នាក់បានស្លាប់) ប្រការ ២៥ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកលើសាលក្រម ឬ សាលដីកាស្ថាពរ លែងលះអាពាហ៍ពិពាហ៍ និងការបែងចែកទ្រព្យសម្បត្តិ) ប្រការ ២៦ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ តាមសេចក្តីសម្រេចរបស់តុលាការ ដោយផ្អែកលើបញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង) និងប្រការ ២៧ (ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ដោយផ្អែកតាមសាលក្រម ឬ សាលដីកាស្ថាពរ ដែលបានកំណត់ក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី មាត្រា ៣០ កថាខណ្ឌទី ៣ ចំណុច ឃ) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពីគោលបំណង មូលហេតុ និងកាលបរិច្ឆេទ នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រង់ខ្ទង់ "ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ។

២- ចំពោះសន្លឹកចុះបញ្ជីក្នុងកថាខណ្ឌទី១ នៃប្រការនេះ មន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញ ដើម្បីបញ្ជាក់ថា "**បានពិនិត្យរួច**" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសម្រេច។

៣- បន្ទាប់ពីទទួលបានហត្ថលេខា និងត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវរក្សាទុកសន្លឹកចុះបញ្ជីនៅក្នុងក្រុណ្ឌ ទៅតាមលំដាប់លេខចុះបញ្ជី។

**ប្រការ ៤២ : របៀបចុះបញ្ជីក្នុងក្រុណ្ឌចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍**

បន្ទាប់ពីពាក្យសុំ និងឯកសារភ្ជាប់ដែលបានកំណត់ក្នុងប្រការ ២៨ (ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍) ត្រូវបានពិនិត្យដោយមន្ត្រីចុះបញ្ជីរួច មន្ត្រីចុះបញ្ជីត្រូវសរសេរអំពី

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍នៅខ្ទង់ "កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍" នៅក្នុងសន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខា កាលបរិច្ឆេទ និងឈ្មោះរបស់មន្ត្រីចុះបញ្ជី។

**ប្រការ ៤៣ : វិធីកត់ត្រាការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ**

១- ពាក់ព័ន្ធនឹងការចុះបញ្ជីអំពីខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ នៅត្រង់ខ្ទង់ "ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ" ឬ ខ្ទង់ "ការផ្លាស់ប្តូរទ្រព្យសម្បត្តិប្តីប្រពន្ធ" មន្ត្រីចុះបញ្ជីក៏អាចចុះថា **"ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ"** រួចភ្ជាប់នូវលិខិតថតចម្លងនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនោះជាមួយគ្នាក្នុងសន្លឹកចុះបញ្ជីនៃក្រូណូបាន។ ក្នុងករណីនេះ មន្ត្រីចុះបញ្ជីត្រូវកត់ត្រានូវលេខចុះបញ្ជី និង លេខទទួល នៅក្នុងលិខិតថតចម្លងនៃកិច្ចសន្យា ដែលបានភ្ជាប់មកជាមួយនោះ ហើយមន្ត្រីចុះបញ្ជីត្រូវចុះហត្ថលេខាបំព្រួញដើម្បីបញ្ជាក់ថា "បានពិនិត្យរួច" រួចបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និង សម្រេច។

២- ក្រោយពេលពិនិត្យ និងសម្រេចរួច រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងចុះហត្ថលេខា និងប្រថាប់ត្រានៅគ្រប់សន្លឹកនៃលិខិតថតចម្លងដែលបានភ្ជាប់មកជាមួយ។

**ប្រការ ៤៤ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ**

ក្រោយពេលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចុះហត្ថលេខា និងប្រថាប់ត្រារួច មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំចុះបញ្ជី និង ឯកសារភ្ជាប់ក្នុងក្រូណូសម្រាប់ដាក់ឯកសារពាក្យសុំ ទៅតាមលំដាប់លេខរៀង និងកាលបរិច្ឆេទទទួលពាក្យសុំ ។

**ប្រការ ៤៥ : របៀបចងក្រងរក្សាទុកក្នុងក្រូណូលើកចោល**

នៅពេលដែលមន្ត្រីចុះបញ្ជី បានលើកចោលពាក្យសុំចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកលិខិតលើកចោលក្នុងក្រូណូលើកចោល ទៅតាមលំដាប់លេខលិខិតលើកចោល និងកាលបរិច្ឆេទ ។

**ប្រការ ៤៦ : របៀបចងក្រងរក្សាទុកក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ**

ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពាក្យសុំឲ្យពិនិត្យឡើងវិញ និងឯកសារភ្ជាប់ ក្នុងក្រូណូសម្រាប់ដាក់ពាក្យសុំឲ្យពិនិត្យឡើងវិញ ទៅតាមលំដាប់លេខពាក្យសុំឲ្យពិនិត្យឡើងវិញ និងកាលបរិច្ឆេទ ។

p

**ប្រការ ៤៧ : របៀបចងក្រងរក្សាទុកក្នុងក្រួណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី**

រាល់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី មន្ត្រីចុះបញ្ជីត្រូវចងក្រងរក្សាទុកពាក្យសុំនោះ នៅក្នុងក្រួណូសម្រាប់ដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី ទៅតាមលំដាប់លេខនៃការទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ការចុះបញ្ជី និងកាលបរិច្ឆេទ ។

## ជំពូកទី ៨
## នីតិវិធីនៃការចេញលិខិតបញ្ជាក់

**ប្រការ ៤៨ : របៀបដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់**

១- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

២- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋប្បវេណីនៃក្រសួងយុត្តិធម៌ ។

៣- ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ត្រូវសរសេរនូវចំណុច ដូចខាងក្រោម ៖

- គោលបំណងនៃពាក្យសុំ ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់
- ឈ្មោះរបស់អ្នកតំណាងនីតិបុគ្គល ក្នុងករណីដែលអ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ជានីតិបុគ្គល
- ចំណុចដែលត្រូវធ្វើការបញ្ជាក់
- ចំនួនលិខិតបញ្ជាក់
- កាលបរិច្ឆេទនៃការដាក់ពាក្យសុំ និងហត្ថលេខា ឬ ស្នាមម្រាមដៃ ។

៤- អ្នកដាក់ពាក្យសុំឲ្យចេញលិខិតបញ្ជាក់ត្រូវបង់សោហ៊ុយសេវា ដូចបានកំណត់តាមបទប្បញ្ញត្តិ ឬ ប្រកាសរួម របស់ក្រសួងយុត្តិធម៌ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤៩ : ការចេញលិខិតបញ្ជាក់**

១- នៅពេលបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ មន្ត្រីចុះបញ្ជីត្រូវថតចម្លងចេញពីសន្លឹកចុះបញ្ជីក្នុងក្រួណូចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ទៅឲ្យអ្នកដាក់ពាក្យសុំ ដោយត្រូវសរសេរនៅលើឯកសារថតចម្លងថា ៖

- បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កាលបរិច្ឆេទ (ថ្ងៃទី...........ខែ..........ឆ្នាំ.........)
- ហត្ថលេខាបំព្រួញរបស់មន្ត្រីចុះបញ្ជី និង ហត្ថលេខា និង ត្រាប្រថាប់ត្រារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏អាចឲ្យរដ្ឋលេខាធិការទទួលបន្ទុកកិច្ចការរដ្ឋប្បវេណី ចុះហត្ថលេខាជំនួសបានដែរ។

២- ក្រោយពីបានទទួលពាក្យសុំឲ្យចេញលិខិតបញ្ជាក់ ក្រសួងយុត្តិធម៌ត្រូវចេញលិខិតបញ្ជាក់ឲ្យអ្នកដាក់ពាក្យសុំនោះ ដោយពុំមានការយឺតយ៉ាវ យ៉ាងយូរបំផុតមិនឲ្យលើសពីរយៈពេល ៣ ថ្ងៃ ។

# ជំពូកទី ៩
# អវសានប្បញ្ញត្តិ

**ប្រការ ៥០ : កាលបរិច្ឆេទ នៃការអនុវត្ត**

ប្រកាសនេះ ត្រូវអនុវត្តក្រោយពេលប្រាំមួយខែបានកន្លងហួស គិតចាប់ពីថ្ងៃចុះហត្ថលេខា ។

ថ្ងៃទី០៩.....ខែមីនា.ឆ្នាំ ២០១៣

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍានៈ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| ឧបសម្ព័ន្ធទី ១ |
|---|
| ប្រការ ១៩ |

## ពាក្យសុំចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ឈ្មោះ.......................ភេទ ប្រុស អាយុ.................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្ដី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត............ ។

ឈ្មោះ.......................ភេទ ស្រី អាយុ.............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត............... អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:....................(ចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)...... ។
- មូលហេតុ:.....................(កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)......... ។
- ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ:.......(សរសេរខ្លឹមសារកិច្ចសន្យាទាំងអស់)......... ................................................................................................................ ................................................................................................................ ................................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

p ស្នាមម្រាមដៃ

ប្ដីឈ្មោះ ប្រពន្ធឈ្មោះ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី ២
ប្រការ ២០

## ពាក្យសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

ឈ្មោះ........................ភេទ ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្ដី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត............ ។

ឈ្មោះ........................ភេទ ស្រី អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង..........................ភេទ.......អាយុ.........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ....................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ.........(ចុះបញ្ជីផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ)...... ។
- មូលហេតុៈ...........(ការផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ព្រមទាំងកាលបរិច្ឆេទ)... ។
- ចំណុចដែលត្រូវផ្លាស់ប្ដូរៈ.......(សរសេរទាំងអស់នូវខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ក្រោយពីការផ្លាស់ប្ដូររួច)..........................................................................
..............................................................................................................
..............................................................................................................
..............................................................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្ដមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ប្ដីឈ្មោះ** **ប្រពន្ធឈ្មោះ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៤
ប្រការ ២១

## ពាក្យសុំចុះបញ្ជីអំពីការកែតម្រូវការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ឈ្មោះ.......................ភេទ ប្រុស អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត........... ជាប្តី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ..........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះ.......................ភេទ ស្រី អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត.............. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ...........ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

### សូមគោរពជូន
### ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការការកែតម្រូវការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជី:..........(កែតម្រូវកំហុស ឬ ការខកខានមិនបានចុះបញ្ជី).... ។
- មូលហេតុ:.....................(មានកំហុស ឬ ការខកខានមិនបានចុះបញ្ជី)..................... ។
- ចំណុចដែលត្រូវកែតម្រូវ:
  - ឈ្មោះ.......................................................................................................
  - អាសយដ្ឋាន................................................................................................
  - ថ្ងៃខែឆ្នាំកំណើត.........................................................................................
  - ខ្លឹមសារនៃទ្រព្យសម្បត្តិប្តីប្រពន្ធ.........................................................................

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ប្តីឈ្មោះ** **ប្រពន្ធឈ្មោះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី ៥
ប្រការ ២២ - ២៧

## ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ [1]

ឈ្មោះ........................ភេទ ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្ដី ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះ........................ភេទ ស្រី អាយុ..............ថ្ងៃ ខែ ឆ្នាំកំណើត.......... ជាប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់...............ក្រុង ស្រុក ខណ្ឌ.................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត.................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ។

- គោលបំណងនៃការចុះបញ្ជីៈ...........(លុបការចុះបញ្ជីទ្រព្យសម្បត្តិប្ដីប្រពន្ធ)................ ។
- មូលហេតុៈ.....................(ការលែងលះអាពាហ៍ពិពាហ៍ ព្រមទាំងកាលបរិច្ឆេទ ឬ លែងលះកំជាប់ពាក្យ ព្រមទាំងកាលបរិច្ឆេទ)..........................................................................។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

p

**ប្ដីឈ្មោះ** **ប្រពន្ធឈ្មោះ**

[1] ក្នុងករណីមោឃភាព ការលុបចោល ឬការលែងលះកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ឬ លែងលះអាពាហ៍ពិពាហ៍ ឬកំជាប់ពាក្យ ដោយផ្អែកលើសេចក្ដីសម្រេចរបស់តុលាការ អ្នកដាក់ពាក្យសុំអាចដាក់ពាក្យសុំតែម្នាក់ឯងបាន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៦
ប្រការ ២៨

## ពាក្យសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

ឈ្មោះ........................ភេទ ប្រុស អាយុ................ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្ដី ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត............ ។

ឈ្មោះ........................ភេទ ស្រី អាយុ............ថ្ងៃ ខែ ឆ្នាំកំណើត......... ជាប្រពន្ធ ☐ ឬជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............... ផ្លូវលេខ...........ភូមិ......... ឃុំ សង្កាត់..............ក្រុង ស្រុក ខណ្ឌ................រាជធានី ខេត្ត........... ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ..........ភូមិ.......... ឃុំ សង្កាត់............ ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត..................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍។

- គោលបំណងនៃការចុះបញ្ជី ៖ ការចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ។
- មូលហេតុៈ ការរៀបអាពាហ៍ពិពាហ៍ ។
- កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ ៖........................................................ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតឲ្យចុះបញ្ជីតាមសំណើខាងលើ ដោយក្ដីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០.........

**ស្នាមម្រាមដៃ**

**ប្ដីឈ្មោះ** **ប្រពន្ធឈ្មោះ**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៧
ប្រការ ៤៨

## ពាក្យសុំឲ្យចេញលិខិតបញ្ជាក់

ឈ្មោះ......................ភេទ ....... អាយុ...............ថ្ងៃ ខែ ឆ្នាំកំណើត............ ជាប្តី ☐ ឬ ប្រពន្ធ ☐ ឬ ជាបុគ្គលដែលនឹងត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ☐ ឬ ជាបុគ្គលផ្សេងទៀត អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ................ ផ្លូវលេខ..............ភូមិ.............. ឃុំ សង្កាត់.................. ក្រុង ស្រុក ខណ្ឌ...................រាជធានី ខេត្ត............ ។

ឈ្មោះរបស់អ្នកតំណាង.........................ភេទ.......អាយុ........ថ្ងៃខែឆ្នាំកំណើត................ អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ............ផ្លូវលេខ.........ភូមិ.......... ឃុំ សង្កាត់............. ក្រុង ស្រុក ខណ្ឌ...................... រាជធានី ខេត្ត...................... ។

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កម្មវត្ថុ ៖ សំណើសុំឲ្យចេញលិខិតបញ្ជាក់។

- គោលបំណងនៃពាក្យសុំ ៖ ការសុំឲ្យចេញលិខិតបញ្ជាក់
- ចំណុចដែលត្រូវធ្វើការបញ្ជាក់ ៖ ............................
- ចំនួនលិខិតបញ្ជាក់ ៖.......................ច្បាប់

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចអនុញ្ញាតតាមសំណើខាងលើ ដោយក្តីអនុគ្រោះ។

ធ្វើនៅ.................ថ្ងៃទី.......ខែ.........ឆ្នាំ ២០........
**ស្នាមម្រាមដៃ**

**ឈ្មោះ**

p

ឧបសម្ព័ន្ធទី ៨

# សន្លឹកត្រាជាសនទទួលពាក្យសុំ

| លេខរៀងទទួលពាក្យ | កាលបរិច្ឆេទនៃការទទួលពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកតំណាង (ប្រសិនបើមាន) | ប្រភេទនៃការចុះបញ្ជីកិច្ចសន្យា ម៉្ញីប្រពន្ធ | ជាប្តីប្រពន្ធ | ជាបុគ្គលដែលត្រូវរៀបការជាមួយគ្នា | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | p | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ៩

ឥស្សិការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ...........ឆ្នាំ..........

| លេខចុះបញ្ជី [2] : | ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្ដូរ | កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : <br> ថ្ងៃខែឆ្នាំកំណើត : <br> អាសយដ្ឋាន : | | | | |
| ឈ្មោះ : <br> ថ្ងៃខែឆ្នាំកំណើត : <br> អាសយដ្ឋាន : | | | | |

កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍

គោលបំណងនៃការចុះបញ្ជី :
មូលហេតុ និងកាលបរិច្ឆេទ :

ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ :

[2] លេខចុះបញ្ជី ៖ សំដៅទៅលើលេខដែលបានចុះនៅក្នុងសន្លឹកក្រដាសទទួលពាក្យសុំ ( ឧបសម្ព័ន្ធទី ៨ ) ត្រង់ខ្ទង់ "ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ" ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១០

ឱស្ថការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី.........ខែ... ... ...ឆ្នាំ.........

| លេខចុះបញ្ជី [3] | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖ | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖ |
|---|---|---|
| | | |

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : | |
| មូលហេតុ និងកាលបរិច្ឆេទ : | |

ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

p

[3] លេខចុះបញ្ជី ៖ សំដៅទៅលើលេខដែលបានចុះនៅក្នុងសន្លឹកក្រដាសទទួលពាក្យសុំ ( ឧបសម្ព័ន្ធទី ៨ ) ត្រង់ខ្ទង់ "ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ" ។

គំរូចុះបញ្ជី ១
ការទទួលពាក្យសុំ

# សន្លឹកក្រដាសទទួលពាក្យសុំ

| លេខរៀងទទួលពាក្យ | កាលបរិច្ឆេទនៃការទទួលពាក្យសុំ | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកដាក់ពាក្យសុំ | | ឈ្មោះ និងអាសយដ្ឋាន របស់អ្នកតំណាង (ប្រសិនបើមាន) | ប្រភេទនៃការចុះបញ្ជីកិច្ចសន្យា ប្តីប្រពន្ធ | ជាប្តីប្រពន្ធ | ជាបុគ្គលដែលត្រូវរៀបការជាមួយគ្នា | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ០១ | ២០.០៣.២០១៣ | - ហុក ច័ន្ទសុវណ្ណារ៉ា<br>#១៨២B, St. ៩ ......<br>- លី សាមឌី<br>#១៨៣A, St. ៩ ...... | ១ | | កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | -ប្តី<br>-ប្រពន្ធ | | |
| ០២ | d | - ហុក ច័ន្ទសុវណ្ណារ៉ា<br>#១៨២B, St. ៩ ......<br>- លី សាមឌី<br>#១៨៣A, St. ៩ ... .. | ១ | | ផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | | | |
| ០៣ | | ធីរ: | ២ | | | | | |
| ០៤ | | យស | ៣ | | | | | |
| ០៥ | | រតនា | ៤ | | | | | |
| ០៦ | | ឫទ្ធី | ៥ | | | | | |
| ០៧ | | Emiko | ៦ | | | | | |
| ០៨ | | ធីរ: | ២ | | លុបកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

| គំរូចុះបញ្ជី ២<br>ការបង្កើត |
|---|

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៩ . .. | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៩ ..... | | | | |

| | | |
|---|---|---|
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : បង្កើត<br>មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣ | ហត្ថលេខាបំព្រួញ |

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងភាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

p

ហត្ថលេខា
រដ្ឋមន្ត្រី

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៣
ការបង្កើត

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៥.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៥ ...... | | | | |
| ឈ្មោះ : សី សាមនី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៥ ...... | | | | |

| | |
|---|---|
| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ |

គោលបំណងនៃការចុះបញ្ជី : បង្កើត

មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

(ហត្ថលេខាបំព្រួញ)

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខរៀងទទួលពាក្យសុំ ៖ ០១

លេខរៀងចុះបញ្ជី ៖ ០១

# កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្តីឈ្មោះ ហុក ច័ន្ទសុវណ្ណារ៉ា ភេទ ប្រុស សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ

ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៨១

អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ប្រពន្ធឈ្មោះ លី សាមឌី ភេទ ស្រី សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ

ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៨១

អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ក្នុងនាមជាប្តីប្រពន្ធ យើងបានព្រមព្រៀងគ្នាទៅលើទ្រព្យសម្បត្តិរបស់ភាគីទាំងសងខាង ដូចខាងក្រោម ៖

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងភាគពកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១៣

p ស្នាមម្រាមដៃ ស្នាមម្រាមដៃ

ឈ្មោះប្តី ឈ្មោះប្រពន្ធ

ហុក ច័ន្ទសុវណ្ណារ៉ា លី សាមឌី

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| គំរូចុះបញ្ជី ៤ ការផ្លាស់ប្តូរកិច្ចសន្យា |
|---|

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖ ហុក ច័ន្ទសុវណ្ណារ៉ា | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖ លី សាមឌី |
|---|---|---|

គោលបំណងនៃការចុះបញ្ជី : ការផ្លាស់ប្តូរ

មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១ ០៤ ២០១៣

(ហត្ថលេខាបំព្រួញ)

## ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។

ដី

ទីតាំង៖ ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខក្បាលដី ៖ លេខ ០០១

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣

(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។

វីឡា

ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ

លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។

Lexus 570

ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងកាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។

៥. ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ទីស្តីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| គំរូចុះបញ្ជី ៥ |
|---|
| ការផ្លាស់ប្តូរកិច្ចសន្យា |

# សន្លឹកចុះបញ្ជីការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

| លេខចុះបញ្ជី : ០១ | ឈ្មោះប្តី ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា ៖ ហុក ច័ន្ទសុវណ្ណារ៉ា | ឈ្មោះប្រពន្ធ ឬ បុគ្គលដែលត្រូវរៀបការជាមួយគ្នា៖ លី សាមឌី |
|---|---|---|

| | |
|---|---|
| គោលបំណងនៃការចុះបញ្ជី : ការផ្លាស់ប្តូរ<br>មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០៤.២០១៣ | ហត្ថលេខាចាំហ្វ្រូញ |

## ការផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

ហត្ថលេខា
រដ្ឋមន្ត្រី

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខរៀងទទួលពាក្យសុំ ៖ ០២
លេខរៀងចុះបញ្ជី ៖ ០១

# កិច្ចសន្យាផ្លាស់ប្តូរកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

ប្តីឈ្មោះ ហុក ច័ន្ទសុវណ្ណារ៉ា ភេទ ប្រុស សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ប្រពន្ធឈ្មោះ លី សាមឌី ភេទ ស្រី សញ្ជាតិ ខ្មែរ អាយុ ៣១ឆ្នាំ
ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៨១
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨២បេ ផ្លូវលេខ ៩......

ក្នុងនាមជាប្តីប្រពន្ធ យើងបានព្រមព្រៀងគ្នាធ្វើការផ្លាស់ប្តូរទៅលើទ្រព្យសម្បត្តិចំនួន ២ ក្នុង ចំនោមទ្រព្យសម្បត្តិដែលបានព្រមព្រៀងពីមុន ដូចខាងក្រោម ៖

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។
ដី
ទីតាំង៖ ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ
លេខក្បាលដី ៖ លេខ ០០១
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣
(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។
វីឡា
ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៣

| | |
|---|---|
| ស្នាមម្រាមដៃ | ស្នាមម្រាមដៃ |
| p | |
| ឈ្មោះប្តី | ឈ្មោះប្រពន្ធ |
| ហុក ច័ន្ទសុវណ្ណារ៉ា | លី សាមឌី |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| គំរូចុះបញ្ជី ៦<br>ការលុបការចុះបញ្ជី |
|---|

នីតិការគ្រួសារ
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

## សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្តូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្តូរ | កាលបរិច្ឆេទនៃការផ្លាស់ប្តូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៩ ...... | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៩ .... | | | | |

| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |
|---|---|---|

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

(ហត្ថលេខាបំព្រួញ)

### ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្តី។
ដី
ទីតាំង៖ ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ
លេខក្បាលដី ៖ លេខ ០០១
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣
(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកានកាប់ និងប្រើប្រាស់ដី)

២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្រពន្ធ។
វីឡា
ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខណ្ឌ ភ្នំពេញ
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥

៣. រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្តី។
Lexus 570
ផ្លាកលេខ ៖ 2A 8844

៤. ទាក់ទងភាតព្វកិច្ចដែលប្តីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។
៥ ទ្រព្យសម្បត្តិដែលប្តី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ។

(ហត្ថលេខា រដ្ឋមន្ត្រី)

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ :
លុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធដោយផ្អែកលើដីកាសម្រេចលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង លេខ ០១ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០២០

(ហត្ថលេខាបំព្រួញ) (ហត្ថលេខា រដ្ឋមន្ត្រី)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូចុះបញ្ជី ៧
ការលុបការចុះបញ្ជី

ទីស្ដីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្ដូរ | កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៤.០៩.១៩៨១<br>អាសយដ្ឋាន : #១៨២B, St. ៩ ...... | | | | |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥ ១០.១៩៨១<br>អាសយដ្ឋាន : #១៨៣A, St. ៩ ..... | | | | |

| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ | |
|---|---|---|

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះថ្ងៃទី ០១.០១.២០១៣

ហត្ថលេខាប់ព្រួញ

ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

-ដូចខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដែលបានភ្ជាប់មកជាមួយ-

ហត្ថលេខា
រដ្ឋមន្ត្រី

p

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ :
លុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធដោយផ្អែកលើដីកាសម្រេចលែងលះអាពាហ៍ពិពាហ៍តាមការព្រមព្រៀង លេខ ០១
ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០២០

ហត្ថលេខាប់ព្រួញ

ហត្ថលេខា
រដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
នាយកដ្ឋានកិច្ចការរដ្ឋប្បវេណី

| គំរូចុះបញ្ជី ៨ |
|---|
| ការផ្លាស់ប្ដូរអាសយដ្ឋាន |

# សន្លឹកចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៥

| លេខចុះបញ្ជី : ០១ | ការផ្លាស់ប្ដូរឈ្មោះ និងអាសយដ្ឋាន | មូលហេតុនៃការផ្លាស់ប្ដូរ | កាលបរិច្ឆេទនៃការផ្លាស់ប្ដូរ | មន្ត្រីចុះបញ្ជីចុះហត្ថលេខា និងកាលបរិច្ឆេទនៃការចុះបញ្ជី |
|---|---|---|---|---|
| ឈ្មោះ : ហុក ច័ន្ទសុវណ្ណារ៉ា<br>ថ្ងៃខែឆ្នាំកំណើត : ២៨.០៩.១៩៨១<br>អាសយដ្ឋាន : ផ្ទះលេខ ១៨២B, ផ្លូវលេខ ៩ សង្កាត់មានជ័យខណ្ឌមានជ័យ រាជធានីភ្នំពេញ. | ផ្ទះលេខ ៣០E០ ផ្លូវ ១៦៣ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ | ផ្លាស់ប្ដូរអាសយដ្ឋាន | ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៥ | ហត្ថលេខា |
| ឈ្មោះ : លី សាមឌី<br>ថ្ងៃខែឆ្នាំកំណើត : ២៥.១០.១៩៨១<br>អាសយដ្ឋាន : ផ្ទះលេខ ១៨៣A, ផ្លូវលេខ ៩ សង្កាត់មានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | | | | |

| កាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ២៥.១២.២០១២ |
|---|---|

គោលបំណងនៃការចុះបញ្ជី : បង្កើត
មូលហេតុ និងកាលបរិច្ឆេទ : កិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ចុះថ្ងៃទី ០១ ០១.២០១៣

ហត្ថលេខាបំព្រួញ

## ខ្លឹមសារនៃកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ

១. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបស់ប្ដី។
ដី
ទីតាំង៖ ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខក្បាលដី ៖ លេខ ០០១
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៣
(លេខវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ, ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ, ប័ណ្ណសម្គាលសិទ្ធិកាន់កាប់ និងប្រើប្រាស់ដី)
២. អចលនវត្ថុខាងក្រោម គឺជាទ្រព្យសម្បត្តិរបសប្រពន្ធ។
វីឡា
ទីតាំង ៖ លេខ ១១អា ភូមិ សង្កាត់ ខ័ណ្ឌ ភ្នំពេញ
លេខប័ណ្ណសម្គាល់សិទ្ធិ ៖ លេខ ៥
៣ រថយន្តខាងក្រោម ជាទ្រព្យសម្បត្តិរបស់ប្ដី។
Lexus 570
ផ្លាកលេខ ៖ 2A 8844
៤. ទាក់ទងភាតព្វកិច្ចដែលប្ដីត្រូវទទួលបន្ទុកមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រពន្ធមិនទទួលខុសត្រូវទេ។
៥. ទ្រព្យសម្បត្តិដែលប្ដី ឬប្រពន្ធទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ គឺជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ។
p

ហត្ថលេខា
រដ្ឋមន្ត្រី

ការលុបការចុះបញ្ជីអំពីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ :

បោះពុម្ពផ្សាយដោយ

ក្រសួងយុត្តិធម៌

ឧបត្ថម្ភដោយ

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ
នៃប្រទេសជប៉ុន (JICA)

ហាមលក់

# ឧបសម្ព័ន្ធទី៥

# ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់សេវាសាធារណៈនៃកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ លេខ ៥៥១ សហវ.ប្រក ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..៤៤៤១.....សហវ....ប្រក

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.moj.gov.kh
ទូរស័ព្ទៈ (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ៨១ កយ.ប្រក/១៣ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣ ស្ដីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ
- បានឃើញប្រកាសលេខ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._ ការប្រមូលចំណូល**

ត្រូវបានអនុញ្ញាតឱ្យក្រសួងយុត្តិធម៌ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ ._ កម្រងសេវាសាធារណៈ**

សេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្ដល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចខាងក្រោម ÷

| លេខរៀងសេវា | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ១ | ការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ | ៣០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | ការចុះបញ្ជីផ្លាស់ប្ដូរកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣ | ការចុះបញ្ជីកែតម្រូវកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៤ | ការចុះបញ្ជីអំពីការលុបកិច្ចសន្យាទ្រព្យសម្បត្តិប្ដីប្រពន្ធ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៥ | ការចុះបញ្ជីអំពីកាលបរិច្ឆេទនៃថ្ងៃរៀបអាពាហ៍ពិពាហ៍ | ១០០.០០០ | ១៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦ | ការចេញលិខិតបញ្ជាក់ | ៤០.០០០ | ៣ថ្ងៃ | ៦ខែ |

**ប្រការ៣ ._ ការចិនផ្សាយព័ត៌មាន**

ក្រសួងយុត្តិធម៌ត្រូវបិទផ្សាយជាសាធារណៈនូវព័ត៌មានមួយចំនួនដូចខាងក្រោម៖

- ទម្រង់ឯកសារនៃពាក្យសុំទៅតាមប្រភេទនីមួយៗ
- តារាងតម្លៃសេវាសាធារណៈ ដូចមានចែងនៅក្នុងប្រការ២ (កម្រៃសេវាសាធារណៈ) នៃប្រកាសអន្តរក្រសួងនេះ
- នីតិវិធីនៃការផ្តល់សេវា។

**ប្រការ៤ ._ ការទទួលមតិរិះគន់**

នៅកន្លែងផ្តល់សេវាសាធារណៈ ក្រសួងយុត្តិធម៌ត្រូវរៀបចំឱ្យមានកន្លែងទទួលមតិរិះគន់ ចំពោះការចាត់ចែងរបស់មន្ត្រីចុះបញ្ជី ដែលបានអនុវត្តផ្ទុយពីខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះ ដូចជា ការអនុវត្តខុសពីស្តង់ដាសេវា ឬមានការយកកម្រៃលើសការកំណត់ ឬការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវ ហួសរយៈពេលអតិបរមាដែលបានកំណត់ ជាអាទិ៍។

មតិរិះគន់នេះ អ្នកទទួលសេវាអាចធ្វើតាមរយៈសារអេឡិចត្រូនិក ឬដាក់លិខិតរិះគន់នៅប្រអប់សំបុត្ររបស់ក្រសួងយុត្តិធម៌ ឬដាក់នៅប្រអប់សំបុត្ររបស់អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៥ ._ យន្តការនៃការផ្តល់សេវាសាធារណៈ**

ក្រសួងយុត្តិធម៌ គប្បីរៀបចំយន្តការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅក្រសួងយុត្តិធម៌ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា។ ទន្ទឹមនឹងនេះ ក្រសួងយុត្តិធម៌ក៏ត្រូវពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online System) សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

**ប្រការ៦ ._ ការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ដែលជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ពនិងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៧ ._ ការរៀបចំគម្រោង និងការអនុវត្តចំណូល**

ក្រសួងយុត្តិធម៌ ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

នៅពេលអនុវត្តចំណូល ក្រសួងយុត្តិធម៌ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

### ប្រការ៨ .- ការរៀបចំរបាយការណ៍

ក្រសួងយុត្តិធម៌ ត្រូវធ្វើរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ ស្តីពីការអនុវត្តចំណូលពីកម្រៃសេវាសាធារណៈនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

### ប្រការ៩ .- ការកែប្រែកម្រងសេវាសាធារណៈ

កម្រងសេវាសាធារណៈដែលចែងក្នុងប្រការ២ (កម្រងសេវាសាធារណៈ) នៃប្រកាសអន្តរក្រសួងនេះ អាចធ្វើការកែប្រែបាន តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រសិនបើមានការចាំបាច់។

### ប្រការ១០ .- កាលបរិច្ឆេទនៃការអនុវត្តប្រកាសអន្តរក្រសួង

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២០ តទៅ។

ថ្ងៃចន្ទ ១ រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ